ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-May-2013, 15:30
CMS/CFO: Krystal THOMPSON

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**បណ្តឹងសាទុក្ខឆ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រ៊ីម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele NUMBA

**ចម្លងជូន:**
សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
សុន អរុណ
Michiel PESTMAN
Victor Koppe
គង់ សំអុន
Anta GUISSÉ
Arthur VERCKEN
Jacques VERGES

## I. **សេចក្តីផ្តើម**

១- អនុលោមតាមវិធាន១០៤, ១០៥, ១០៦(២) និង ១០៧[1] សហព្រះរាជអាជ្ញាដាក់បណ្តឹងសាទុក្ខភ្លាមៗនេះ (“បណ្តឹងសាទុក្ខ”) ជូនអង្គជំនុំជម្រះតុលាការកំពូល ប្រឆាំងនឹងសេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ (“សេចក្តីសម្រេចដែលរងការជំទាស់”)[2]។ សហព្រះរាជអាជ្ញាប្តឹងសាទុក្ខនេះ ដោយសារតែ៖

(ក) សេចក្តីសម្រេចដែលរងការជំទាស់ មានអានុភាពបញ្ចប់ការចោទប្រកាន់យ៉ាងមានប្រសិទ្ធភាពប្រឆាំងនឹងជនជាប់ចោទចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមមាន ការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ ពលរដ្ឋកម្ពុជារាប់សែននាក់ តាមរយៈបណ្តាញមន្ទីរសន្តិសុខទូទាំងកម្ពុជាប្រជាធិបតេយ្យ។

(ខ) អង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានអនុវត្តតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល ដោយបានច្រានចោលថា “គ្មានន័យ” នូវលក្ខខណ្ឌតម្រូវសម្រាប់អង្គជំនុំជម្រះសាលាដំបូង ធ្វើការពិចារណាពីវិសាលភាពនៃសវនាការក្នុងសំណុំរឿង ០០២/០១ តំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង០០២ ទាំងមូល។

(គ) មន្ទីរសន្តិសុខស-២១ គឺជាទីតាំងឧក្រិដ្ឋកម្មតំណាងតែមួយគត់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង០០២ និងជាមន្ទីរសន្តិសុខមួយ និងតែមួយគត់ ដែលបានរាយការណ៍ជូនមេដឹកនាំនៃ បកក ហើយ

---

[1] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៨) កែសម្រួលនៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១ (“វិធាន”)។

[2] E284 សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែកុម្ភៈ, ២៦ មេសា ២០១៣ (“សេចក្តីសម្រេចដែលរងការជំទាស់”)។

(ឃ) គ្មានមូលដ្ឋានបែបសនិទានកម្មចំពោះការសន្និដ្ឋានថា រយៈពេលខ្លីនៃពេលវេលាសម្រាប់សវនាការបន្ថែម ដែលចាំបាច់ដាក់បញ្ចូលស-២១ ទៅក្នុងសំណុំរឿង ០០២/០១ នឹងបង្កើនយ៉ាងជាក់ស្តែងនូវហានិភ័យនាំឱ្យសាលក្រមមិនអាចចេញបាននៅមុនពេលមរណភាព ឬអលទ្ធភាពរបស់ជនជាប់ចោទ។

២- នៅពេលដែលបណ្តឹងសាទុក្ខនេះមានមូលដ្ឋានរឹងមាំផ្អែកច្បាប់ និងអង្គហេតុនៅក្នុងរឿងក្តីនេះ គឺជាមូលហេតុនាំឱ្យមានអ្វីមួយ ដែលមានមូលដ្ឋានគ្រឹះច្រើន។ ដំណោះស្រាយនៃបណ្តឹងឧទ្ធរណ៍សមស្រប និងត្រឹមត្រូវគឺជាឱកាសចុងក្រោយសម្រាប់ អវតក ស្វែងរកឱ្យជនជាប់ចោទទទួលខុសត្រូវ ចំពោះបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ស្ថិតនៅក្រោមច្បាប់មនុស្សធម៌អន្តរជាតិ។ នេះគឺជាការសន្យាចំពោះប្រជាជនកម្ពុជាក្នុងជំនាន់មួយ បន្ទាប់ពីព្រឹត្តការណ៍បំផ្លិចបំផ្លាញ និងដោយចេតនា បានកើតឡើង ដែលតុលាការ នេះត្រូវបានបង្កើតឡើងដើម្បីដោះស្រាយ។ សហព្រះរាជអាជ្ញា មិនអាចស្វែងរកការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលបានប្រព្រឹត្តក្នុងអម្លុងពេលកម្ពុជាប្រជាធិបតេយ្យ។ ទោះបីជាយ៉ាងណាក៏ដោយ គេជឿជាក់យ៉ាងមុតមាំថា នេះគឺជាកាតព្វកិច្ចរបស់ខ្លួនដើម្បីធានាថានៅក្នុងសំណុំរឿង ០០២ មានចេតនា សមហេតុសមផល និងប្រាកដប្រជា ដើម្បីបង្ហាញឱ្យកាន់តែមានសុក្រឹតភាពឡើងនូវបទល្មើសទាំងអស់ដែលជាគោលនយោបាយរបស់ខ្មែរក្រហម។ ឱកាសដើម្បីទទួលបានយុត្តិធម៌ច្រើនគឺត្រូវបិទសំណុំរឿងឱ្យបានឆាប់។ ចំពោះហេតុផលនេះ សហព្រះរាជអាជ្ញាស្នើថា អង្គជំនុំជម្រះតុលាការកំពូល ត្រូវធ្វើការសម្រេចចិត្ត និងកំណត់ថា យុត្តិធម៌ដ៏ពិតប្រាកដត្រូវតែធ្វើការជំនុំជម្រះ។

៣- ដូចសម្អាងហេតុដែលបានជម្រាបជូនខាងក្រោម សហព្រះរាជអាជ្ញាសន្និដ្ឋានថា៖ (១) បណ្តឹងសាទុក្ខអាចទទួលយកបាន (២) សេចក្តីសម្រេចដែលរងការជំទាស់មានកំហុសខាងអង្គច្បាប់ កំហុសខាងអង្គហេតុ និងកំហុសនៃការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង និង(៣) សេចក្តីសម្រេចដែលរងការជំទាស់ គួរបានផ្លាស់ប្តូរដោយដាក់បញ្ចូល **មន្ទីរសន្តិសុខស-២១**[3] ទៅក្នុងវិសាលភាពនៃសវនាការជំនុំជម្រះក្នុងសំណុំរឿង០០២/០១។

---

[3] D427 ដីកាដំណោះស្រាយ, កថាខណ្ឌទី៨១៥-៨៣៥។

## II. ប្រវត្តិនីតិវិធី

៤- សហព្រះរាជអាជ្ញាបានកំណត់អំពីប្រវត្តិនីតិវិធីរួចហើយកន្លងមក ដែលពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយនៃសំណុំរឿង០០២ ចាប់ពីកថាខណ្ឌទីបួន ដល់ទីប្រាំបួននៃបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ[4] ហើយបង្រួមកថាខណ្ឌទាំងនោះជាសេចក្តីយោង។ ក្នុងបណ្តឹងសាទុក្ខលើកទីមួយ សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស *ក្នុងចំណោមបញ្ហាផ្សេងទៀត* ដោយខកខានមិនបានអនុវត្តតាមបទដ្ឋានស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីដែលត្រឹមត្រូវ[5]។ ជនជាប់ចោទម្នាក់ៗបានឆ្លើយតបដោយជំទាស់នឹងបណ្តឹងសាទុក្ខនេះ[6] ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សារណាមួយដោយគាំទ្រចំពោះបណ្តឹងសាទុក្ខ[7]។ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងចម្លើយតបរបស់មេធាវីការពារក្តីម្នាក់ៗ[8]។

---

[4] E163/5/1/1 បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ ០០២/០១, ៧ វិច្ឆិកា ២០១២, កថាខណ្ឌទី៤-៩។

[5] E163/5/1/1 បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ ០០២/០១, ៧ វិច្ឆិកា ២០១២។

[6] E163/5/1/3 ចម្លើយតបរបស់លោក អៀង សារី ទៅនឹងបណ្តឹងសាទុក្ខបន្ទាន់របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង ០០២/០១, ១៩ វិច្ឆិកា ២០១២។ E163/5/1/4 សារណាឆ្លើយតប [របស់ នួន ជា] ទៅនឹងបណ្តឹងឧទ្ធរណ៍ភ្លាមៗរបស់សហព្រះរាជអាជ្ញាទាក់ទិនទៅនឹងវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១, ១៩ វិច្ឆិកា ២០១២។ E163/5/1/9 ចម្លើយតប [របស់ ខៀវ សំផន] ទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០១, ៣០ វិច្ឆិកា ២០១២។

[7] E163/5/1/5 សារណាគាំទ្ររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះបណ្តឹងសាទុក្ខភ្លាមៗ របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះ នៅក្នុងសំណុំរឿង០០២/០១, ២១ វិច្ឆិកា ២០១២។

[8] E163/5/1/8 ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ អៀង សារី អំពីបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ០០២/០១, ២៦ វិច្ឆិកា ២០១២។ E163/5/1/10 ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ នួន ជា អំពីបណ្តឹងសាទុក្ខពាក់ព័ន្ធ នឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ០០២/០១, ៣ ធ្នូ ២០១២។ E163/5/1/11 ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ ខៀវ សំផន ចំពោះបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿងលេខ០០២/០១, ៧ ធ្នូ ២០១២។

៥- នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី[9]។ អង្គជំនុំជម្រះបានរកឃើញថា បណ្តឹងសាទុក្ខអាចទទួលយកបាន ដោយឈរលើទឡ្ហីករណ៍ថា ដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីតាមវិធាន១០៤(៤)(ក)។ អង្គជំនុំជម្រះតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងថា បើសិនជាខ្លួនពិចារណាបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ឡើងវិញ ដោយសារមូលហេតុនៃភាពអាចគ្រប់គ្រងរបស់តុលាការ ត្រូវផ្តល់ "ផែនការជាក់ស្តែងច្បាស់លាស់សម្រាប់ការជំនុំជម្រះលើបទចោទទាំងមូល ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[10]។ ម្យ៉ាងវិញទៀត បើសិនជា "ប្រឈមមុខនឹងសុខភាពដែលកាន់តែចុះខ្សោយរបស់ជនជាប់ចោទ យុត្តិធម៌គួរបានធ្វើឡើងដោយការបញ្ចប់ [សំណុំរឿង០០២] តាមរយៈសាលក្រមមួយដែលយ៉ាងហោចណាស់ តាមសវនាការតូចមួយលើផ្នែកខ្លះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ"។ អង្គជំនុំជម្រះសាលាដំបូងត្រូវបានបង្គាប់ឲ្យ "ថ្លែងពីចំណុចនេះឲ្យបានច្បាស់ និងផ្តល់ការពិចារណាឲ្យបានត្រឹមត្រូវ អំពីតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងសវនាការតូចៗ"[11]។

៦- នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយ ដោយកំណត់ពីទស្សនៈយល់ឃើញរបស់ខ្លួនពីអានុភាពនៃសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធី ដូច្នេះថា៖ "ផលវិបាកជាបន្ទាន់ភ្លាមៗនៃសេចក្តីសម្រេចរបស់ អជតក គឺថាសំណុំរឿង០០២ មិនមានការកម្រិតទៅលើវិសាលភាពទៀតទេ ហើយអង្គជំនុំជម្រះសាលាដំបូងមិនអាចចេញសាលក្រមណាមួយក្នុងសំណុំរឿង០០២បានឡើយ ទាល់តែការចោទប្រកាន់ផ្នែកអង្គហេតុ និងបទចោទទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង០០២ ត្រូវបានជម្រះរួចសិន"[12]។ អង្គជំនុំជម្រះសាលាដំបូងបានថ្លែងបន្ថែមទៀតថាខ្លួន "នឹងចេញសេចក្តីសម្រេចដែលមាន

---

[9] E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១, ៨ កុម្ភៈ ២០១៣ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី")។

[10] E163/5/1/13 *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី៥០។

[11] EI63/5/1/13 *ដដែលដូចខាងលើ*។.

[12] E163/5/1/13/1 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការណែនាំដល់ភាគីនានា ដោយសារតែមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា

សម្អាងហេតុពេញលេញទាក់ទងនឹងវិសាលភាពនៃសំណុំរឿង០០២/០១ ក្នុងពេលឆាប់ៗតាមដែលអាចធ្វើបានបន្ទាប់ពីសវនាការផ្ទាល់មាត់ដែលបានកំណត់ពេលរួចហើយ ដោយមានការគិតគូ ទាំងសារណារបស់ភាគី និងគោលការណ៍ដែលមានចែងនៅក្នុងសេចក្តីសម្រេចរបស់ អជតក"[13]។

៧- នៅថ្ងៃទី១៨ ទី២០ និងទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកធ្វើសវនាការផ្ទាល់មួយលើបញ្ហាអំពីការបំបែកកិច្ចដំណើរការនីតិវិធី ដោយបានបង្គាប់ឲ្យភាគីឆ្លើយតបទៅនឹងសំណួរមួយឈុតនៃអនុស្សរណៈរបស់ខ្លួន ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣[14] និងអនុស្សរណៈជាបន្តបន្ទាប់មួយទៀត ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣[15]។

៨- នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ជនជាប់ចោទ អៀង សារី បានស្លាប់ ហើយអង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់[16]។ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ អ្នកជំនាញផ្នែកសុខភាពដែលបានចាត់តាំងដោយតុលាការ បានផ្តល់សក្ខីកម្មថា នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ[17]។ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ[18]។

---

ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ (ឯកសារ E163/5/1/13), ១២ កុម្ភៈ ២០១៣, កថាខណ្ឌទី២។

[13] **E163/5/1/13/1** *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌទី៥។

[14] **E163/5/1/13/1** *ដដែលដូចខាងលើ*។.

[15] **E264** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា៖ "សំណួរបន្ថែមទៅភាគីក្រោយសវនាការថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល លើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ (ឯកសារលេខ E163/5/1/13)", ១៩ កុម្ភៈ ២០១៣។

[16] **E270/1** សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី, ១៤ មីនា ២០១៣។

[17] **E1/175.1** ប្រតិចារឹកសវនាការ, ២៥ មីនា ២០១៣។

[18] **E1/176.1** ប្រតិចារឹកសវនាការ, ២៩ មីនា ២០១៣, ទំព័រទី២។ **E256/5** សេចក្តីសម្រេចលើកទី២ លើកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ, ២ មេសា ២០១៣។

៩- នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ ប្រធានអង្គជំនុំជម្រះសាលាដំបូង ក៏បានធ្វើការប្រកាសនៅក្នុងសាលសវនាការផងដែរថា៖ "ចំពោះសម្អាងហេតុដែលនឹងបញ្ជាក់ក្នុងសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សររបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសម្រេចដោយបំបែកសំណុំរឿង០០២ អនុលោមតាមវិធាន៨៩*ស្ទួនពីរ* ដោយការកម្រិតទៅលើវិសាលភាពនៃសំណុំរឿង០០២/០១ ចំពោះបទចោទនៃការជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី១ និងទី២ និងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ"[19]។ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា សម្អាងហេតុសម្រាប់ការសម្រេចនោះ នឹងមានជាលាយលក្ខណ៍អក្សរ "ក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន"[20]។ នៅថ្ងៃដដែល សហព្រះរាជអាជ្ញាបានធ្វើការប្រាស្រ័យទាក់ទងទៅកាន់មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ ដោយស្នើសុំឱ្យបញ្ជាក់ថា តើនៅពេលណាទើបអង្គជំនុំជម្រះសាលាដំបូង ចេញសម្អាងហេតុជាលាយលក្ខណ៍អក្សរស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២[21]។ ក្នុងនាមអង្គជំនុំជម្រះសាលាដំបូង មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់រូបនោះបានឆ្លើយតបថា សម្អាងហេតុនឹងផ្ដល់ជូន "ក្នុងពេលឆាប់ៗតាមដែលអាចធ្វើបាន" ដោយធ្វើការសង្កេតថា ដំណើរការបកប្រែ និងកែសម្រួល និងការមិនអាចរកបានជាសក្ដានុពលនៃបុគ្គលិកជាតិ ធ្វើឱ្យមានការលំបាក ដើម្បីប៉ាន់ស្មានថាតើពេលណាទើបសេចក្ដីសម្រេចដែលមានសម្អាងហេតុអាចមាន[22]។

១០- នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានដាក់សំណើមួយ ដោយស្នើសុំការបញ្ជាក់អះអាងពីអង្គជំនុំជម្រះសាលាដំបូង អំពីភាពអាចមាននៃសម្អាងហេតុជាលាយលក្ខណ៍អក្សរនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលបានកែសម្រួលឡើងវិញ ត្រឹមថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៣ ឬ - ដោយមានការរំពឹងទុកអំពីភាពមិនអាចរកបាននៃធនធានបកប្រែ អាស្រ័យដោយរយៈពេលនេះជារយៈពេលនៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ - ស្នើផ្ដល់ជូនភាគីនូវសម្អាងហេតុជាលាយលក្ខណ៍

---

[19] E1/176.1 ប្រតិចារឹកសវនាការ, ២៩ មីនា ២០១៣, ទំព័រទី៤ បន្ទាត់ទី១៣-១៧។

[20] E1/176.1 *ដដែលដូចខាងលើ* ត្រង់ទំព័រទី២ បន្ទាត់ទី២៣ ដល់ទំព័រទី២៤។

[21] E163/5/1/13/2.2.1 អ៊ីម៉េលពីសហព្រះរាជអាជ្ញារង ២៩ មីនា ២០១៣។

[22] E163/5/1/13/2.2.1 អ៊ីម៉េលពីមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ ជូនគូភាគី, ២៩ មីនា ២០១៣។

អក្សរតែមួយភាសាផ្លូវការសិនត្រឹមថ្ងៃនោះ[23]។ អង្គជំនុំជម្រះសាលាដំបូងមិនបានឆ្លើយតបទៅនឹងសំណើនេះទេ។

១១- នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៣ មុនពេលចាប់ផ្តើមឡើងវិញនៃការផ្តល់សក្ខីកម្មរបស់សាក្សី សហព្រះរាជអាជ្ញាបានសុំការបញ្ជាក់ពីអង្គជំនុំជម្រះសាលាដំបូង ពីកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ជាលទ្ធផលនៃការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មីឡើងវិញ ថាតើដូចគ្នានឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីពីមុនដែរ ឬទេ[24]។ មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់បានឆ្លើយបតនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ ដោយអះអាងថា វិសាលភាពនៃការបំបែកកិច្ចដំណើរការនីតិវិធី គឺនៅដដែលដូចបានកំណត់ពីមុន[25]។

១២- នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញារង បានស្នើជាថ្មីម្តងទៀតអំពីបច្ចុប្បន្នភាពនៃសេចក្តីសម្រេចដែលមានសម្អាងហេតុថាតើនៅពេលណាទើបដាក់ទៅក្នុងសំណុំរឿង[26]។ មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់បានឆ្លើយតបនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៣ ដោយបញ្ជាក់ថា បច្ចុប្បន្នភាព "មិនអាច" ផ្តល់ជូនបានទេ "ក្រៅពីនិយាយថា វាមិនយូរប៉ុន្មានឡើយ"[27]។

១៣- នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានប្តឹងទៅអង្គជំនុំជម្រះនេះ ដោយបានដាក់សំណើជាបន្ទាន់មួយសុំឱ្យបង្គាប់ទៅអង្គជំនុំជម្រះសាលាដំបូង ឱ្យចេញនូវសម្អាងហេតុជាលាយលក្ខណ៍អក្សរចំពោះសេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួន ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២/០១ តែមួយភាសាផ្លូវការរបស់ អ.វ.ត.ក ក្នុងករណីចាំបាច់ ដើម្បីទប់ស្កាត់ការបដិសេធជាបន្តទៀតចំពោះសិទ្ធិរបស់ភាគីទាំងអស់[28]។ សំណើនេះក្រោយមកត្រូវបានបដិសេធថាមិនចាំបាច់[29]។

---

[23] E264/4 សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យបញ្ជាក់អំពី ភាពអាចទទួលបាននៃសម្អាងហេតុជាលាយល័ក្ខណ៍អក្សរចំពោះដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលបានកែសម្រួលឡើងវិញ, ៥ មេសា ២០១៣។

[24] ឧបសម្ពន្ធទី១, អ៊ីម៉ែលពីសហព្រះរាជអាជ្ញារង ៧ មេសា ២០១៣។

[25] ឧបសម្ពន្ធទី១, អ៊ីម៉ែលពីមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ ជូនគូភាគី, ៨ មេសា ២០១៣។

[26] E163/5/1/13/2.2.1 អ៊ីម៉ែលពីសហព្រះរាជអាជ្ញារង, ១៨ មេសា ២០១៣។

[27] E163/5/1/13/2.2.1 អ៊ីម៉ែលពីមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ ជូនគូភាគី, ១៨ មេសា ២០១៣។

[28] E163/5/1/13/2 សំណើរបស់សហព្រះរាជអាជ្ញាសុំសេចក្តីសម្រេចជាបន្ទាន់ពីអង្គជំនុំជម្រះសាលាដំបូងឱ្យចេញសេចក្តីសម្រេចមានសម្អាងហេតុ ពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធី សំណុំរឿងលេខ០០២ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣។

១៤- នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូង បានបញ្ចេញសេចក្តីសម្រេចដែលរងការជំទាស់[30]។ នៅថ្ងៃដដែល អង្គជំនុំជម្រះនេះក៏បានចេញសេចក្តីប្រកាសព័ត៌មានមួយផងដែរទាក់ទងនឹងសេចក្តីសម្រេចដែលរងការជំទាស់[31]។

## III. **ភាពអាចទទួលយកបាន**

១៥- សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងសាទុក្ខនេះធ្វើឡើងទាន់ពេល អនុលោមតាមវិធាន១០៧(១) ដែលបង្គាប់ថា បណ្តឹងសាទុក្ខអនុលោមតាមវិធាន១០៤(៤)(ក) ត្រូវដាក់ក្នុងអំឡុងពេល៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីសេចក្តីសម្រេច។ សេចក្តីសម្រេចដែលរងការជំទាស់ត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ និងថាបើដូច្នេះ បណ្តឹងសាទុក្ខត្រូវបានដាក់យ៉ាងត្រឹមត្រូវនៅក្នុងរយៈពេលកំណត់៣០ ថ្ងៃ។

១៦- សេចក្តីសម្រេចដែលរងការជំទាស់ គឺជាកម្មវត្ថុនៃបណ្តឹងសាទុក្ខភ្លាមៗ អនុលោមតាមវិធាន១០៤(៤)(ក) និង១០៤(១)។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "សិទ្ធិប្តឹងសាទុក្ខដែលមានចែងក្នុងវិធាន១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ធានាឲ្យមានប្តឹងសាទុក្ខ បើសិនជាកិច្ចដំណើរការនីតិវិធីនឹងត្រូវបានបញ្ចប់ដោយពុំមានសាលក្រម និងបើដូច្នេះ ពុំមានឱកាសប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេច" ការណ៍នេះរួមទាំង សេចក្តីសម្រេចណាដែលនាំឲ្យផ្អាកដល់ដំណើរការនីតិវិធីដែលពុំមានការសន្យាជាក់ស្តែងច្បាស់លាស់នៃការបន្តឡើងវិញ និងថា "នៅក្នុងបរិបទនៃ អ.វ.ត.ក ដែលមានអង្គជំនុំជម្រះសាលាដំបូងតែមួយ ហើយមានសវនាការជំនុំជម្រះតែមួយ ការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ ទៅជាការជំនុំជម្រះដាច់ៗពីគ្នា បង្កើតឲ្យមានស្ថានភាពមិនអាចជៀសរួចដែលកិច្ចដំណើរការនីតិវិធីទាក់ទងនឹងបទចោទនានា ចេញក្រៅពីវិសាលភាពនៃសំណុំរឿង០០២/០១

---

[29] E163/5/1/13/3 សំណើរបស់សហព្រះរាជអាជ្ញាសុំសេចក្តីសម្រេចជាបន្ទាន់ពីអង្គជំនុំជម្រះសាលាដំបូងឲ្យចេញសេចក្តីសម្រេចមានសម្អាងហេតុ ពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធី សំណុំរឿងលេខ០០២ ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌទី៥។

[30] E284 សេចក្តីសម្រេចដែលរងការជំទាស់។

[31] ឧបសម្ពន្ធទី២ សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះសាលាដំបូង៖ "អង្គជំនុំជម្រះសាលាដំបូង ចេញសេចក្តីសម្រេចដែលមានសំអាងហេតុស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២", ២៦ មេសា ២០១៣។

នោះគឺមានអានុភាពនាំដល់ការផ្អាក[32]។ បើសិនជា *“មានការផ្អាកតាមព្រឹត្តន័យ*នៃកិច្ចដំណើរការនីតិវិធី ទាក់ទងនឹងបទចោទទាំងអស់ ដែលបានដាក់ឲ្យស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ហើយ ការផ្អាកនេះ មិនបានសន្យាច្បាស់លាស់គ្រប់គ្រាន់នៃការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីឡើងវិញ ដែលអាចចេញសាលក្រមលើអង្គសេចក្តីនោះទេ” បណ្តឹងសាទុក្ខនេះ អាចទទួលយកបានតាមវិធាន១០៤(៤)(ក)[33]។

១៧- ជាលទ្ធផលនៃសេចក្តីសម្រេចដែលរងការជំទាស់ មន្ទីរស-២១ គឺស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១។ អាស្រ័យហេតុនេះ បទចោទទាក់ទងនឹងស-២១ ត្រូវបានផ្អាកនៅក្រោមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនេះ។ ទាក់ទងនឹងថាតើការផ្អាកនេះ មានការសន្យាច្បាស់លាស់គ្រប់គ្រាន់នៃការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីឡើងវិញ ឬអត់ អង្គជំនុំជម្រះនេះបានសម្រេចថា “ការគ្រាន់តែដាក់បញ្ចូលស-២១ ទៅក្នុងផែនការមួយ សម្រាប់ការជំនុំជម្រះក្តីពេលខាងមុខ មិនបានដោះស្រាយបញ្ហា “ថាតើអាចចេញសាលក្រមលើអង្គសេចក្តី ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅស-២១ ដែរ ឬអត់ គឺបានរារាំងយ៉ាងមានប្រសិទ្ធភាព តាមរយៈការលើកពេលទៅជំនុំជម្រះនាពេលខាងមុខរបស់ខ្លួនរួចទៅហើយ[34]។

១៨- អង្គជំនុំជម្រះនេះថែមទាំងបានសម្រេចទៀតថា មានភស្តុតាងហេតុគ្រប់គ្រាន់ដែលថា បទចោទទាំងឡាយដែលបានលើកពេលទៅធ្វើនៅក្នុងសវនាការជំនុំជម្រះក្តីនាពេលអនាគតវិញនោះ នឹងមិនអាចឈានទៅដល់ការចេញសាលក្រមឡើយ ដែលហេតុនេះអាចឲ្យប្តឹងសាទុក្ខបាន ដោយអនុលោមតាមវិធាន ១០៤(៤)(ក)នៃវិធានផ្ទៃក្នុង។ ករណីបើសិនជាមានកត្តារួមផ្សំនានាបង្ហាញថាការជំនុំជម្រះនាពេលអនាគតមិនទំនងជានឹងកើតឡើង ឬមិនទំនងជានឹងឈានទៅដល់ការបញ្ចប់នោះ[35]។ កត្តាដែលទាំងនេះដែលអង្គជំនុំជម្រះសាលាដំបូងបានពឹងផ្អែកនៅក្នុងការសម្រេចថា ការបំបែកកិច្ចដំណើរការនីតិវិធីលើកដំបូង អាចឲ្យប្តឹងសាទុក្ខបាន ថាជាការបញ្ចប់មួយដ៏មានប្រសិទ្ធភាពដែលនៅតែអាចអនុវត្តបានជាដដែលនៅពេលបច្ចុប្បន្ននេះ ដែលក្នុងនោះរួមបញ្ចូលទាំង៖ វ័យដែលកាន់តែចាស់ជរា

---

[32] E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌទី២២។

[33] E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌទី២៥។

[34] E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌទី២៣។

[35] E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌទី២៤។

និងសុខភាពដែលកាន់តែទ្រុឌទ្រោមរបស់សហជនជាប់ចោទ ដូចដែលអង្គជំនុំជម្រះបានលើកយោង នៅក្នុងសេចក្តីសម្រេចដែលរងនូវការជំទាស់[36], ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការ មិនបានផ្តល់នូវគំរោងផែនការជាក់លាក់ណាមួយ ដែលតាមគំរោងសវនាការជំនុំជម្រះក្នុងពេល អនាគតអាចនឹងចាប់ផ្តើមបាននៅមុនពេលចេញសាលដីកាលើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿងលេខ ០០២/០១ ហើយអង្គហេតុដែលពាក់ព័ន្ធដែលសាលក្រមលើអង្គសេចក្តីមិនទាន់ចូលជាស្ថាពរនៅឡើយ រហូតដល់ពេលឆ្លងកាត់ដំណាក់កាលប្តឹងសាទុក្ខរួច[37]។ ហើយយោបល់យល់ឃើញផ្សេងៗដែលបាន លើកដោយភាគីនានា និងដោយអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់ថា សំណុំរឿងលេខ០០២/០១ គឺទំនងជាសំណុំរឿងតែមួយគត់ប៉ុណ្ណោះដែលឈានទៅដល់ការចេញសាលក្រម[38]។ "ភាពមិនប្រាកដ ប្រជាអំពីរយៈពេល និងការបន្តជាប់លាប់ក្នុងការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ អវតក" ដែលបានលើក យោងនៅក្នុងសេក្តីសម្រេចដែលរងការជំទាស់[39]បានគាំទ្របន្ថែមទៀតដល់សេចក្តីសន្និដ្ឋានថា ពុំមាន លទ្ធភាពជាក់ស្តែងស្តីពីការជំនុំជម្រះសំណុំរឿងលេខ០០២ជាបន្តទៅទៀតសម្រាប់អនាគត ហើយ អង្គជំនុំជម្រះកំពុងតែបញ្ចប់ដោយប្រសិទ្ធភាពនូវរាល់បទចោទប្រកាន់ទាំងអស់ដែលមិនស្ថិតនៅក្នុង វិសាលភាពនៃសំណុំរឿងលេខ០០២/០១។

១៩- ចំពោះមូលហេតុទាំងអស់នេះ សហព្រះរាជអាជ្ញាជូនយោបល់ថា ការដកចេញនូវមន្ទីរសន្តិសុខស-២១ ពីក្នុងសំណុំរឿងលេខ០០២/០១ ក្រោមលក្ខខណ្ឌនៃសេចក្តីសម្រេចដែលរងការជំទាស់ គឺជាការធ្វើ ឲ្យផ្អាកដល់កិច្ចដំណើរការនីតិវិធីទាក់ទងនឹងបទចោទប្រកាន់នានាដែលពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋ កម្មស-២១ ដំណោះស្រាយអំពីរឿងនេះនៅក្នុងសាលក្រមលើអង្គសេចក្តីគឺគ្មានទេ ព្រោះនៅឆ្ងាយ ណាស់។ អាស្រ័យហេតុនេះ សេចក្តីសម្រេចដែលរងការជំទាស់អាចឲ្យប្តឹងសាទុក្ខភ្លាមៗបាន ដោយ អនុលោមតាមវិធាន១០៤(៤)(ក)នៃវិធានផ្ទៃក្នុង។

---

[36] E284 សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១២១ (អាយុ និងការសម្បទាចាស់ជរារបស់ជនជាប់ចោទ), កថាខណ្ឌ១២៦-១៣៤។

[37] E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌទី២៤។

[38] E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌទី២៤។ E284 សេចក្តី សម្រេចដែលរងការជំទាស់, កថាខណ្ឌទី៨៧. ៩៣. ១២១។

[39] E284 សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១៤៥-១៤៦។

## IV. ការដាក់សារណាដើម្បីគាំទ្រដល់ការប្តឹងសាទុក្ខ

### ក. អង្គជំនុំជម្រះសាលាដំបូងមានកំហុសខាងអង្គច្បាប់ ដោយសារអង្គជំនុំជម្រះខកខានមិនបានយកបទដ្ឋានច្បាប់សម្រាប់ការបំបែកកិច្ចដំណើរការនីតិវិធីមកអនុវត្ត

២០- នៅក្នុងកថាខណ្ឌទី៥០ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល បានណែនាំដល់អង្គជំនុំជម្រះសាលាដំបូងដូចខាងក្រោម៖ "ជាការចាំបាច់ អង្គជំនុំជម្រះសាលាដំបូងត្រូវកំណត់ ដោយផ្អែកលើមូលដ្ឋាននៃការផ្តាប់បានដឹងយ៉ាងច្បាស់ផ្នែកសវីរាងដែលទាក់ទងទៅនឹងសំណុំរឿងលេខ០០២" ថាតើសារៈសំខាន់នៃការបំបែកកិច្ចដំណើរការនីតិវិធីបែបនេះ ដែលនៅក្នុងសំណុំរឿងនោះចាំបាច់គឺត្រូវមានផែនការច្បាស់លាស់មួយសម្រាប់ការជំនុំជម្រះរាល់បទចោទប្រកាន់ទាំងអស់ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយមិនមែនគ្រាន់តែបទចោទប្រកាន់មួយផ្នែកនៅក្នុងនោះដែរឬទេ។ ប៉ុន្តែបើសិនជាមានការដែលប្រឈមនឹងស្ថានភាពសុខភាពរបស់សហជនជាប់ចោទ ចុះទ្រុឌទ្រោម ហេតុផលជាសំខាន់នោះគឺថា យុត្តិធម៌ត្រូវបានផ្តល់ ហើយជាការល្អប្រសើរ ដោយការបញ្ចប់មានសាលក្រមមួយ ដែលទោះបីជាសម្រេចថាត្រូវមានទោស ឬក៏ត្រូវលើកលែងក៏ដោយ យ៉ាងហោចណាស់ក៏មានការជំនុំជម្រះមួយតូចជាងនៅលើផ្នែកណាមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរ បន្ទាប់មកទៀត អង្គជំនុំជម្រះគួរលើករឿងនេះ ឱ្យបានច្បាស់ ហើយឱ្យផ្តល់នូវការពិចារណាឱ្យបានត្រឹមត្រូវទៅលើភាពសមហេតុសមផលនៃភាពតំណាងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលស្ថិតនៅក្នុងវិសាលភាពសវនាការជំនុំជម្រះដែលមានលក្ខណៈតូចជាងនេះ"[40]។

២១- នៅក្នុងផ្នែកទី៤.១.១ នៃសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថាការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មីឡើងវិញថា ជាចាំបាច់ត្រូវផ្អែកលើមូលដ្ឋាននៃ "វ័យកាន់តែចាស់ជរា និងសុខភាពកាន់តែទន់ខ្សោយរបស់សហជនជាប់ចោទនៅក្នុងសំណុំរឿងលេខ០០២ និងភាពមិនទំនងដែលថារាល់ការចោទប្រកាន់ទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿងលេខ០០២ដែលអាចធ្វើសវនាការបាននៅក្នុងអម្លុងពេលពីកើត ដល់ស្លាប់របស់ជនជាប់ចោទ ឬនៅក្នុង

---

[40] E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌទី៥០។

ខណៈដែលជនជាប់ចោទនៅមានសតិស្មារតីរឹងមាំដែលអាចធ្វើការកាត់ទោសបាន”[41]។ ប៉ុន្តែ ដោយសារការសន្និដ្ឋាននេះដែលថា ភាពចាំបាច់នៃការបំបែកកិច្ចដំណើរការនីតិវិធី កើតចេញមកពីសុខភាពទ្រុឌទ្រោមរបស់ជនជាប់ចោទក្តី ក៏អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានផ្តល់ឲ្យបានត្រឹមត្រូវទៅដល់ភាពតំណាងសមហេតុសមផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងវិសាលភាពសវនាការដែលតូចជាងនេះ ការកំណត់ចរិតលក្ខណៈនៃការសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលថា “គ្មានន័យ”[42]។ នៅក្នុងសេចក្តីប្រកាសព័ត៌មានមួយដែលអមជាមួយនឹងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់អំពី “ភាពតំណាងសមហេតុសមផល”ថាជា “សញ្ញាណមួយដែលបានដាក់ដោយសហព្រះរាជអាជ្ញា”[43] ជាជាងថាជា “ការសម្រេចតាមផ្លូវច្បាប់ ដោយតុលាការជាន់ខ្ពស់ណាមួយ ដែលអង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុវត្តតាម។

២២- ជាជំនួសឲ្យការវាយតម្លៃអំពីថាតើការជំនុំជម្រះក្នុងលក្ខណៈតូចជាងនេះ ដែលត្រូវធ្វើនៅក្នុងសំណុំរឿងលេខ០០២/០១ គឺជាភាពតំណាងសមហេតុសមផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូលដែរ ឬទេ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលនូវអាណត្តិរបស់អង្គជំនុំជម្រះនេះ ហើយបង្កើតនូវការសាកល្បងរបស់ខ្លួនផ្ទាល់៖ ថាតើទីតាំងឧក្រិដ្ឋកម្មស-២១ ដែលបានស្នើសុំឲ្យដាក់បញ្ចូលដោយសហព្រះរាជអាជ្ញា គឺតំណាងឲ្យការជំនុំជម្រះលើការជម្លៀសចេញដោយបង្ខំ នៅក្នុងសំណុំរឿងលេខ ០០២/០១ ដែលអង្គជំនុំជម្រះសាលាដំបូងបានដាក់ចេញនៅក្នុងសេចក្តីសម្រេចដើមស្តីពីការបំបែកកិច្ចដំណើការនីតិវិធីនោះដែរ ឬទេ។ នៅក្នុងកថាខណ្ឌទី៩៩ នៃសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីសន្និដ្ឋានដោយខុសថា គឺជាការមិនត្រឹមត្រូវទេ “ក្នុងការកំណត់ថាបើសិនជាផ្នែកដំបូងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវជំនុំជម្រះ គឺតំណាងសមហេតុសមផលអោយការចោទប្រកាន់ទាំងអស់ ដែលមាននៅក្នុងដីកាដំណោះស្រាយទាំងមូល” ព្រោះការបញ្ចប់ជាផ្លូវការនៃកិច្ចដំណើរការនីតិវិធី គឺមិនអាចឲ្យធ្វើទៅបានឡើយក្រោមក្របខណ្ឌនៃ អវតក ហើយហេតុដូចនេះបានកំណត់ថា “តាមការនិយមចូលចិត្តយោងទៅលើភាពតំណាងឲ្យវិសាលភាពនៃសំណុំ

[41] **E284** Impugned ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ៨៧ ៩០ ផ្នែក ៤.១.១ មានចំណងជើងថា “ ថាតើអង្គជំនុំជម្រះសាលាដំបូងគួរតែធ្វើការកែប្រែដីកាបំបែកកិច្ចដំណើរការនីតិវិធី នៃសំណុំរឿងលេខ០០២?”។

[42] **E284** សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី៩៩ (“ហេតុដូច្នេះ ដរាបណាអង្គជំនុំជម្រះសាលាដំបូងមិនគោរពតាមក្របខណ្ឌពេលវេលាបច្ចុប្បន្ន សញ្ញាណនៃ “ភាពជាតំណាងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺគ្មានន័យ”)។

[43] **ឧបសម្ព័ន្ធទី២** សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះសាលាដំបូង, ២៦ មេសា ២០១៣។

រឿងលេខ០០២/០១ ជាងភាពតំណាងអោយដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ”[44]។ ការអនុវត្តនូវបទដ្ឋានច្បាប់ដែលខុសឆ្គងនេះ អង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីសន្និដ្ឋានថា ការដាក់បន្ថែមនូវមន្ទីរស-២១នេះ គឺមិន “សំខាន់ដល់លក្ខណៈវិនិច្ឆ័យនៃភាពតំណាងសមហេតុសមផលនោះទេ” ព្រោះដោយសារ “ការមិនមានការជាប់ទាក់ទងគ្នាជាក់ស្តែងណាមួយ (ខាងភូមិសាស្ត្រ ឬខាងពេលវេលា) ទៅនឹងប្រធានបទសំខាន់នៃករណីរឿង០០២/០១” (គឺ ការជម្លៀសចេញដោយបង្ខំ)[45]។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូង កំណត់ថាភាពតំណាងរបស់មន្ទីរស-២១ នៅក្នុងបរិបទនៃការជំនុំជម្រះស្តីពីការជម្លៀសចេញដោយបង្ខំក្នុងសំណុំរឿងលេខ០០២/០១ ដែលត្រូវចាត់ទុកជាមោឃភាព គឺប្រសើរជាងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើសំណុំរឿងលេខ០០២ ទាំងមូល។

២៣- អង្គជំនុំជម្រះតុលាការកំពូល បានចាត់ទុកជាមោឃៈនូវសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយទាំងស្រុង ហើយតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យពិចារណាឡើងវិញលើការបំបែកកិច្ចដំណើរការនីតិវិធី *កាលពីដើមដំបូង* ដើម្បីធ្វើការវាយតម្លៃថា “តើធ្វើយ៉ាងដូចម្តេច ដើម្បីឲ្យមានតំណាងសមហេតុសមផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងវិសាលភាពនៃសំណុំរឿងលេខ០០២/០១” និងធ្វើឲ្យ “តំណាងជាអតិបរមានៃការចោទប្រកាន់នានាដែលប្រឆាំងនឹងសហជនជាប់ចោទ”[46]។ អង្គជំនុំជម្រះសាលាដំបូងគួរពិចារណាសាជាថ្មីម្តងទៀតអំពីថាតើ ការជម្លៀសចេញដោយបង្ខំទាំងពីរលើក និងទួលពោធិ៍ជ្រៃគឺតំណាងសមហេតុសមផលរបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល ហើយ *ដែលការចោទប្រកាន់ និងទីតាំងឧក្រិដ្ឋកម្មបន្ថែមនានា* គួរតែត្រូវបានដាក់បន្ថែម ដើម្បីធ្វើឲ្យវិសាលភាពនៃសំណុំរឿងលេខ០០២/០១ទៅជាតំណាងសមហេតុសមផលដែរ ឬទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូង បានច្រានចោលមិនព្រមធ្វើការវាយតម្លៃទៅលើទីតាំងឧក្រិដ្ឋកម្មបន្ថែមនានាដែលនឹងធ្វើឲ្យសំណុំរឿងលេខ០០២/០១ ទៅជាតំណាងកាន់តែច្រើននោះទេ ដោយបានលើកឡើងថា “ខ្លួននឹងប្រឈមមុខទល់នឹងការជំទាស់នានាដែលមិនអាចជំនះបាន ក្នុងការទទួលរ៉ាប់រងឲ្យមានការជ្រើសរើសត្រឹមត្រូវ និងយុត្តិធម៌រវាងភាគីនានា ដែលស័ក្តិសមស្មើគ្នា និងដែលមានចំនួនច្រើនសម្រាប់ដាក់បញ្ចូល” ហើយមិនចង់ឲ្យរំខានដល់ “តុល្យភាពនៃការគិតពិចារណាដែលមានភាពមិនស្រួររឹងមាំ ទោះបីជាមានការឈឺចាប់” ដែលអាចនឹងមានផលប៉ះពាល់ទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី

[44] E284 សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី៩៩។

[45] E284 សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១១៦។

[46] E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌទី៤៣-៤៤។

នានា[47]។ ម្យ៉ាងទៀត អង្គជំនុំជម្រះសាលាដំបូងបានបោះបង់ចោលនូវការទទួលខុសត្រូវតាមផ្លូវច្បាប់របស់ខ្លួន ក្នុងការសម្រេច និងដាក់បញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មតំណាងមួយចំនួន ព្រោះវិធីដំណើរការលំបាក និងឈឺចាប់។

២៤- លើសពីនេះ អង្គជំនុំជម្រះសាលាដំបូងថែមទាំងមានកំហុសដោយការរក្សានូវភាពមិនច្បាស់លាស់ថាជនជាប់ចោទនឹងត្រូវដាក់ឲ្យទទួលនូវការជំនុំជម្រះក្តីជាបន្តបន្ទាប់[48] នៅពេលដែលការវាយតម្លៃរបស់ខ្លួនអំពីសុខភាពរបស់ជនជាប់ចោទ[49] និងស្ថានភាពថវិការបស់ អវតក[50] បានបង្ហឹឲ្យមានការកំណត់ថាលទ្ធភាពនៃការធ្វើសវនាការជំនុំជម្រះសម្រាប់ពេលអនាគត គឺមិនអាចធ្វើទៅកើត។ នៅក្នុងបរិបទនេះ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចពិចារណាអំពីផលវិបាកជាក់ស្តែងនៃការបំបែកកិច្ចដំណើរការនីតិវិធី- គឺថាកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទដែលទាក់ទងទៅនឹងរាល់ការចោទប្រកាន់ដែលត្រូវបានបំបែក កិច្ចដំណើរការនីតិវិធីទាំងអស់នឹងត្រូវបានបញ្ចប់ដោយប្រសិទ្ធភាព។ នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ រួមមានការដកយកវិញ ឬការបញ្ចប់ ជាផ្លូវការនូវការចោទប្រកាន់នានាដែលមកពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺមិនអាចអនុញ្ញាតឲ្យបានទេនៅក្នុងប្រព័ន្ធរបស់ អវតក[51] ក៏ប៉ុន្តែការខកខានមិនបានទទួលស្គាល់ថា ការបញ្ចប់ដោយប្រសិទ្ធភាព ទោះបីជាកើតឡើងក៏ដោយ នៅពេលដែលការចោទប្រកាន់នានាត្រូវបានផ្អាក ដោយគ្មានការកំណត់ពេល នៅក្នុងកាលៈ ទេសៈផ្សេងពីនេះ ដូចជានៅទីនេះ មិនទំនងជានឹងត្រូវចាប់ផ្តើមឡើងវិញទាល់តែសោះ។ ការវិភាគត្រង់ៗនេះត្រូវបានច្រានចោលដោយអង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសេចក្តីសម្រេចក្នុងខែកុម្ភៈ ឆ្នាំ២០១៣ របស់ខ្លួន[52] ហើយនេះគឺជាកំហុសរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនបានគោរពតាមសេចក្តីសន្និដ្ឋានខាងអង្គច្បាប់របស់អង្គជំនុំជម្រះតុលាការកំពូល។

[47] **E284** សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១១៥, ១១៩។

[48] **E284** សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១៥៥។

[49] **E284** សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១២៦, ១៣៤។

[50] **E284** សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១៤៥-១៤៦។

[51] **E284** សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី៩៨-៩៩។

[52] **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌទី៤៣ (ច្រានចោលថា "មិនសមហេតុផល" យុត្តិកម្មរបស់អង្គជំនុំជម្រះសាលាដំបូងថា "គ្មានការចោទប្រកាន់ ឬបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានបន្ត" ក្នុងទស្សនៈនៃការរកឃើញថា បញ្ហាខុសភាពរបស់ជនជាប់ចោទនឹងមិនអនុញ្ញាតឲ្យពួកគាត់ចូលរួមក្នុងវគ្គសវនាការដ៏វែងបានឡើយ។

២៥- ផ្ទុយទៅនឹងការទាមទាររបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា "ក្របខណ្ឌច្បាប់នាពេលបច្ចុប្បន្ន" របស់ អវតក ធ្វើឲ្យសញ្ញាណអំពីភាពជាតំណាង ក្លាយទៅជា "គ្មានន័យ"[53]។ យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនេះ គឺជាផ្នែក និងជាកញ្ចប់នៃ "ក្របខណ្ឌច្បាប់" របស់ អវតក ដែលអង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចអនុវត្តតាម។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ណែនាំយ៉ាងទូលំទូលាយដល់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការអនុវត្តដោយផ្ទាល់នូវទស្សនទានអំពីភាពជាតំណាងសមហេតុសមផល នៅក្នុង "យុត្តាធិការចម្រុះ*ពិសេសមួយគត់គ្មានពីរ*"[54] តួយ៉ាងដូចជា អវតក នេះ ដោយផ្អែកលើមូលដ្ឋាននៃ "បទដ្ឋានច្បាប់អន្តរជាតិដែលអាចប្រៀបធៀបគ្នាបាន"[55] ហើយបដិសេធចោលថាជា "មិនសមហេតុសមផល" នូវគោលជំហររបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនបានអនុវត្តតាមលក្ខខណ្ឌតម្រូវអំពីភាពជាតំណាងសមហេតុសមផល នៅក្នុងករណីបើសិនជា "មិនមានការចោទប្រកាន់ណាត្រូវបានកាត់ផ្តាច់ដោយសារផលវិបាកនៃ "ដីកាសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី"[56]។ អង្គជំនុំជម្រះនេះក៏បានផ្តល់ផងដែរនូវមាគ៌ាណែនាំលម្អិតស្តីពីទស្សនទាន ទាំងការផ្អាកដំណើរការនីតិវិធីជាបណ្តោះអាសន្ន និងទាំងការផ្អាកដំណើរការនីតិវិធីដោយគ្មានការកំណត់ពេល ដែលផ្សាភ្ជាប់ទៅនឹងសេចក្តីសម្រេចថ្មីៗនេះស្តីពីការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ[57]។

២៦- កំហុសខាងអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង ជាលទ្ធផលគឺបណ្តាលឲ្យអង្គជំនុំជម្រះនេះខកខានក្នុងការផ្តល់នូវការពិចារណាឲ្យបានត្រឹមត្រូវទៅលើកត្តានានាដែលពាក់ព័ន្ធ ដែលគួរបានបង្ហាញផ្លូវដល់សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន។ ឧទាហរណ៍ដូចជា សេចក្តីសម្រេចដែលរងការជំទាស់ ចែងថាការជំនុំជម្រះក្តីតូច បានកម្រិតតែត្រឹមការជម្លៀសចេញដោយបង្ខំដំណាក់កាលទី១ និងទី២ ដែលបើកឲ្យអង្គជំនុំជម្រះសាលាដំបូង "បន្តដំណើរការនៅក្នុងលក្ខណៈមួយ

---

[53] ឯកសារលេខ E284 សេចក្តីសម្រេចសម្រេចដែលរងការជំទាស់ កថាខណ្ឌទី ៩៩។

[54] ឯកសារលេខ E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌទី៤២ ។

[55] ឯកសារលេខ E163/5/1/13 សេចក្តីសម្រេចសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃសំណុំរឿងលេខ០០២/០១ត្រង់កំណត់សំគាល់លេខ ៩៥ និងកថាខណ្ឌទី៤២ , ដែលបកស្រាយវិធាន៧៣*ស្ទួន*(ឃ)របស់តុលាការ ICTY ថាជា "បទដ្ឋានគតិយុត្តិអន្តរជាតិដែលអាចប្រៀបធៀបគ្នាបាន"។

[56] ឯកសារលេខ E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ,កថាខណ្ឌទី៤៣

[57] ឯកសារលេខ E138/1/10/1/5/7 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែងជនជាប់ចោទ អៀង ធិរិទ្ធ ដោយគ្មានលក្ខខណ្ឌ, ចុះថ្ងៃទី១៤ ធ្នូ ២០១២, កថាខណ្ឌទី៣៥-៤០។

ដែលស្របទៅតាមរចនាសម្ព័ន្ធទាក់ទងនឹងពេលវេលា និងតក្កវិជ្ជា របស់ដីកាដំណោះស្រាយ"[58]។ ក៏ប៉ុន្តែនៅក្នុងកាលៈទេសៈបច្ចុប្បន្នដែលពុំមានគំរោងជាក់លាក់ក្នុងការធ្វើសវនាការជំនុំជម្រះ សម្រាប់ពេលអនាគតបន្ថែមទេ អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានផ្តល់នូវការពិចារណាទៅលើលំដាប់នៃពេលវេលានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿងលេខ០០២។ ដោយបដិសេធមិនព្រមអនុវត្តតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការជ្រើសយកនូវសវនាការជំនុំជម្រះបន្តបន្ទាប់មួយឈុត ឬមួយក៏សវនាការតែមួយដែលមានតំណាងច្រើនជាងមុន ហេតុដូចនេះ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តកំហុសខាងអង្គច្បាប់ដោយច្រំដែល ដែលធ្វើឲ្យសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីកាលពីដំបូងទៅជាគ្មានសុពលភាព។

២៧- ទោះបីជាមានការណែនាំអំពីសេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាសម្រេច ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនោះក្តី ក៏អង្គជំនុំជម្រះសាលាដំបូងបដិសេធមិនយល់ស្របតាម និងមិនទទួលស្គាល់ថា សេចក្តីសម្រេចរបស់ខ្លួនបានច្រានចោលដោយប្រសិទ្ធភាពនូវការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទក្នុងសំណុំរឿងលេខ០០២ ដែលមានបរិមាណដ៏ច្រើន ដែលក្នុងនោះរួមទាំងការចោទប្រកាន់ទាំងអស់ទៅលើខ្សែរយៈបណ្តាញនៃមន្ទីរសន្តិសុខនានា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទៀតផង ដែលនៅទីនោះ មានជនរងគ្រោះចំនួនរាប់ពាន់នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ធ្វើទារុណកម្ម និងសម្លាប់ដោយខុសច្បាប់។ ដោយសារតែលទ្ធផលនៃកំហុសនេះ ក្នុងវិសាលភាពនៃសំណុំរឿងលេខ០០២/០១ មិនត្រូវបានរួមបញ្ចូលនូវមន្ទីរសន្តិសុខណាមួយ ហើយក៏មិនបានតំណាងសមហេតុសមផលឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល ដូចលើកឡើងដោយពិស្តារដូចខាងក្រោមនេះ៖

## ខ. អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសខាងអង្គហេតុ និងអង្គច្បាប់ដោយសារការធ្វើសេចក្តីសន្និដ្ឋានថា វិសាលភាពនៃសំណុំរឿងលេខ០០២/០១ ត្រូវបានតំណាងយ៉ាងគ្រប់គ្រាន់ឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយមិនបានបន្ថែមមន្ទីរសន្តិសន្តិសុខស-២១ទេ

២៨- អង្គជំនុំជម្រះតុលាការកំពូលបានណែនាំដល់អង្គជំនុំជម្រះសាលាដំបូង ឲ្យពិចារណាទៅលើវិធាន ៧៣*ស្ទួន*(ឃ) នៃវិធានផ្ទៃក្នុងរបស់តុលាការ ICTY ដើម្បីជាការឆ្លុះបញ្ចាំងអំពី "ការប្រៀបធៀបជា

[58] ឯកសារលេខ E284 សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌទី ១១១។

មួយនឹងបទដ្ឋានច្បាប់អន្តរជាតិនានា”[59]ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី។ សេចក្តីសម្រេចដែលរងការជំទាស់មិនព្រមគោរពតាមការណែនាំច្បាស់លាស់នេះទេ ដោយបែងចែកឲ្យដាច់ពីគ្នា និងបដិសេធចោលនូវភាពជាប់ទាក់ទងនៃយុត្តិសាស្ត្ររបស់តុលាការ ICTY នៅក្នុងរឿងនេះ[60]។ នៅក្នុងសេចក្តីសន្និដ្ឋានដែលដាក់ជូនរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងមានកំហុសទាំងខាងអង្គច្បាប់ផង និងទាំងខាងអង្គហេតុផង ដោយខកខានមិនបានពិចារណាឲ្យបានត្រឹមត្រូវលើបញ្ជីដែលមិនបានរៀបរាប់អស់ អំពី “កាលៈទេសៈនានាដែលពាក់ព័ន្ធ” នៅក្នុងវិធាន៧៣*ស្ទួន*(ឃ) ដែលគួរត្រូវបានធ្វើការថ្លឹងថ្លែងនៅក្នុងការវាយតម្លៃអំពីការបំបែកកិច្ចដំណើរការនីតិវិធី នៃការចោទប្រកាន់នានា គឺថា៖ (ក) ឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ខ) លក្ខណៈ និងចំណាត់ថ្នាក់នៃឧក្រិដ្ឋកម្មទាំងនោះ (គ) ទីកន្លែងដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានចោទប្រកាន់ថាត្រូវបានប្រព្រឹត្ត (ឃ) កម្រិតនៃឧក្រិដ្ឋកម្មទាំងនោះ (ង) ជនរងគ្រោះទាំងឡាយដោយសារឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទាំងនោះ។ បន្ថែមពីលើនេះ អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការវាយតម្លៃឲ្យបានសមស្របទៅលើកត្តាចំនួនពីរ ដែលមិនបានកំណត់លេខរៀងច្បាស់លាស់នៅក្នុងវិធាន៧៣*ស្ទួន*(ឃ) ប៉ុន្តែបានឆ្លុះបញ្ចាំងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ICTY គឺថា៖ (i) អំពីរយៈពេលនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និង (ii) អំពីលក្ខណៈជាមូលដ្ឋាន ឬសេចក្តីសង្ខេបនៃករណីរឿងក្តី។ កត្តាទាំងនេះ និងការយកកត្តាទាំងនេះមកអនុវត្តចំពោះសំណុំរឿងលេខ០០២ ត្រូវបានលើកឡើងនៅក្នុងការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជូនអង្គជំនុំជម្រះសាលាដំបូងកាលពីក្នុងខែកុម្ភៈ ឆ្នាំ២០១៣[61]។

២៩- អង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីសង្កេតថា ៖ “ការអនុវត្តនូវវិធាន ៧៣*ស្ទួន*(ឃ) របស់តុលាការ ICTY គឺមានលក្ខណៈពឹងផ្អែកយ៉ាងខ្លាំងទៅលើអង្គហេតុ និងវិធីសាស្ត្រដែលមានការប្រែប្រួលយ៉ាងខ្លាំង”[62] ដែលមិនអាចឲ្យមានការធ្វើតេស្តផ្នែកច្បាប់ដែលអាចអនុវត្តបាន ដើម្បីកំណត់អំពីភាពតំណាងឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្លាយទៅជា“គ្មានន័យ”បានឡើយ[63] និងមិនយល់ព្រមទាំង

---

[59] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌទី៤២ ។

[60] E284 សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌទី ១០១-១០៧។

[61] ឯកសារលេខ E1/171.1 ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី, ថ្ងៃទី១៨ កុមភៈ ២០១៣, ទំព័រពីទី ៤៣-៥៧។

[62]ឯកសារលេខ E284 សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌទី ១០១។

[63]ឯកសារលេខ E284 សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌទី៩៩។

ស្រុងជាមួយនឹងការពិតថាការបំបែកកិច្ចដំណើរការនីតិវិធីចាំបាច់ ត្រូវរួមបញ្ចូលជាមួយនូវការវាយតម្លៃមួយយ៉ាងលម្អិត និងផ្អែកទៅតាមករណីមួយម្តងៗ-ដោយមិនមានគ្រឿងយន្តក្នុងការបោសសម្អាត ប៉ុន្តែដោយមានភាពខុសគ្នាតិចតួច មិនមានអារម្មណ៍លម្អៀង និងដោយមិនមានការគិតគូរពិចារណា។ វិធីសាស្ត្រណាមួយផ្សេងទៀតមានហានិភ័យថា នៅតែ "យកជាមាគ៌ាបាន....ដោយលក្ខណៈវិនិច្ឆ័យដែលមិនបញ្ចេញឲ្យដឹង ក្រៅតែពីទំនាក់ទំនងតាមតក្កសាស្ត្រក្នុងចំណោមការចោទប្រកាន់ជាក់លាក់តែប៉ុណ្ណោះ"[64]។

៣០- នៅខណៈដែលកត្តាពីរដំបូងគេ ដែលបានកំណត់ក្នុងវិធាន៧៣*ស្ទួន* (ឃ) "ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់" និង "ការកំណត់បទចោទ និងប្រភេទ" - មានលក្ខណៈច្បាស់លាស់សមហេតុផល សហព្រះរាជអាជ្ញាសន្និដ្ឋានថា ដំបូងតម្រូវឲ្យបទឧក្រិដ្ឋដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានបំបែក ត្រូវតែមានភាពធ្ងន់ធ្ងរស្រដៀងគ្នា និងភាពខុសគ្នានៃដីកាដំណោះស្រាយទាំងមូល។ កត្តាទីពីរតម្រូវឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានបំបែក ត្រូវដាក់បញ្ចូល បើសិនជាអាច នូវបទឧក្រិដ្ឋដែលតំណាងឲ្យប្រភេទនៃបទឧក្រិដ្ឋកម្មអន្តរជាតិស្នូលដែលត្រូវបានទទួលស្គាល់ និងបទឧក្រិដ្ឋជាតិជាធរមាន។

៣១- ករណីយុត្តិសាស្ត្ររបស់តុលាការ ICTY ផ្តល់នូវការចំរាញ់យកនូវគោលការណ៍នានាមានប្រយោជន៍ដែលបំភ្លឺអំពីកត្តាទាំងបីដែលនៅសល់។ "ទីកន្លែងដែលបទឧក្រិដ្ឋ ត្រូវបានគេចោទថាបានប្រព្រឹត្ត" តម្រូវឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានបំបែកកិច្ចដំណើរការនីតិវិធី ឆ្លុះបញ្ចាំងពីភូមិសាស្ត្រនៃឧក្រិដ្ឋកម្មនោះ នៅក្នុងដីកាដំណោះស្រាយទាំងមូល[65]។ ប្រសិនបើតំបន់មួយអាចឲ្យគេកំណត់អត្តសញ្ញាណបានថា ជាទីកន្លែងនៃរឿងក្តី ការពិត គឺថា ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តខាងក្រៅតំបន់នោះ អាចជាមូលហេតុមួយនៃការច្រានចោល[66]។ ការបែងចែកភូមិសាស្ត្រស្មើគ្នា និងសមាមាត្រនឹងទីតាំងឧក្រិដ្ឋកម្មដែលបានរក្សាទុក ហាក់ដូចជាការរក្សាទុកនូវប្រភេទជាតំណាងឲ្យដីកាបញ្ជូនរឿង

---

[64] ឯកសារលេខ E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ,កថាខណ្ឌទី៤៥ ។

[65] *រដ្ឋអាជ្ញា ទល់នឹង Vojislav Seselj*, សំណុំរឿងលេខ៖ IT-03-67, សេចក្តីសម្រេចស្តីពីការអនុវត្តវិធាន៧៣*ស្ទួន*, (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ៨ វិច្ឆិកា ២០០៦, កថាខណ្ឌទី៣០។

[66] *រដ្ឋអាជ្ញា ទល់នឹង Milutinovic*, សំណុំរឿងលេខ៖ IT-05-87, សេចក្តីសម្រេចស្តីពីការអនុវត្តវិធាន៧៣*ស្ទួន*, (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ១១ កក្កា ២០០៦, កថាខណ្ឌទី១១។

ទៅជំនុំជម្រះ[67]។ ប៉ុន្តែ ការលុបចោលទីតាំងឧក្រិដ្ឋកម្មទាំងមូលពីតំបន់ណាមួយ ដែលមិនតំណាងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានគេរកឃើញថា មិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន ៧៣*ស្ទួន* (ឃ) ដូចជា ការដកចេញនាំឲ្យជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងតំបន់ជាក់លាក់ណាមួយនោះ មិនត្រូវបានតំណាងនៅក្នុងសំណុំរឿងជារៀងរហូត[68]។

៣២- ដើម្បីកុំឲ្យច្រឡំជាមួយនឹងកត្តាទីបួន - "វិសាលភាព" នៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ - ពីកត្តាដទៃទៀត សហព្រះរាជអាជ្ញាសន្និដ្ឋានថា វិសាលភាព គឺសំដៅទៅលើកត្តាទាំងឡាយដូចជា ទំហំភាពទៀងទាត់ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម។ ការពិនិត្យឡើងវិញទៅលើករណីយុត្តិសាស្ត្ររបស់តុលាការ ICTY ផ្តល់នូវឧទាហរណ៍អនុវត្តមួយចំនួនអំពីការកាត់បន្ថយវិសាលភាព ដែលបានរកឃើញថាបានឆ្លុះបញ្ចាំងយ៉ាងគ្រប់គ្រាន់ចំពោះ "វិសាលភាព" នៃបទឧក្រិដ្ឋតាមវិធាន៧៣*ស្ទួន*(ឃ)៖ (i) ចាប់ពីបទឧក្រិដ្ឋចំនួន ១៤០ នៅក្នុងក្រុងចំនួន២៣ ដល់បទឧក្រិដ្ឋចំនួន៦៦ នៅក្នុងទីក្រុងចំនួន១៥[69](ii) ពីទីតាំងសម្លាប់មនុស្សចំនួន ២២ ទៅជា២០ ទីតាំង ដែលបានចោទប្រកាន់នៅក្នុងបទចោទមួយ[70] (iii) ពីចំនួនឧប្បត្តិហេតុនៃការលបបាញ់ចំនួន១៦ ដល់១០ និងការបាញ់ផ្លោងចំនួន១៨ ដល់១០[71] និងការកាត់បន្ថយវិសាលភាពនៃពេលវេលានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះមកត្រឹមពីរខែ ដើម្បីបញ្ចប់ "ប្រមាណមួយភាគបី" នៃការចោទប្រកាន់[72]។

---

67 *រដ្ឋអាជ្ញា ទល់នឹង StaniÈić និង Simatović*, សំណុំរឿងលេខ៖ IT-03-69-PT, សេចក្តីសម្រេច អនុលោមតាមវិធាន ៧៣*ស្ទួន*(ឃ), (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ៤ កុម្ភៈ ២០០៨, កថាខណ្ឌទី២៣។

68 *រដ្ឋអាជ្ញា ទល់នឹង Perisic*, សំណុំរឿងលេខ៖ IT-04-81-PT, សេចក្តីសម្រេចស្តីពីការអនុវត្តវិធាន៧៣*ស្ទួន*, និងវិសោធនកម្មនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ១៥ ឧសភា ២០០៧, កថាខណ្ឌទី១២។

69 *រដ្ឋអាជ្ញា ទល់នឹង Mladić*, សំណុំរឿងលេខ៖ IT-09-92-PT, សេចក្តីសម្រេច អនុលោមតាមវិធាន៧៣*ស្ទួន*(ឃ), (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ២ ធ្នូ ២០១១, កថាខណ្ឌទី៥, ១១។

70 *រដ្ឋអាជ្ញា ទល់នឹង Mladić*, សំណុំរឿងលេខ៖ IT-09-92-PT, សេចក្តីសម្រេច អនុលោមតាមវិធាន៧៣*ស្ទួន*(ឃ), (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ២ ធ្នូ ២០១១, កថាខណ្ឌទី៦, ១១។

71 *រដ្ឋអាជ្ញា ទល់នឹង Mladić*, សំណុំរឿងលេខ៖ IT-09-92-PT, សេចក្តីសម្រេច អនុលោមតាមវិធាន៧៣*ស្ទួន*(ឃ), (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ២ ធ្នូ ២០១១, កថាខណ្ឌទី៦, ១១។

72 *រដ្ឋអាជ្ញា ទល់នឹង Gotovina, Cermak និង Markac*, សំណុំរឿងលេខ៖ IT-06-90-PT, ដីកាសម្រេចអនុលោមតាមវិធាន ៧៣*ស្ទួន*(ឃ) ដើម្បីកាត់បន្ថយការបញ្ជូនរឿងទៅជំនុំជម្រះ, (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ២១ កុម្ភៈ ២០០៧, កថាខណ្ឌទី២-៤។

៣៣- ទាក់ទិននឹងការតំណាងរបស់ "ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់" ចំនួនជនរងគ្រោះ ការចាត់ជាក្រុមនៃជនរងគ្រោះ និងជាពិសេស ក្រុមជាតិពន្ធុ ត្រូវបានគេមើលឃើញថាជាការពិចារណាដែលពាក់ព័ន្ធនៅតុលាការ ICTY។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានបំបែកកិច្ចដំណើរការនីតិវិធី គឺស្វែងរកដើម្បីរក្សាទុកក្រុមជាតិពន្ធុ និងក្រុមសាសនាទាំងអស់ និងក្រុមពិសេសផ្សេងទៀតដែលជាក្រុមគោលដៅនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នោះ ហើយមិនត្រូវធ្វើឱ្យខូចខាតដល់លទ្ធភាពនៃការចោទប្រកាន់នៅក្នុងការបង្ហាញភស្តុតាងអំពីភាពរងគ្រោះនៃក្រុមជាតិពន្ធុទាំងអស់នោះឡើយ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[73]។

៣៤- ចំពោះកត្តាទាំងឡាយដែលមិនបានចែងច្បាស់លាស់នៅក្នុងវិធាន៧៣*ស្ទួន*(ឃ)ករណីយុត្តិសាស្ត្ររបស់តុលាការ ICTY កំណត់ថា ការបំបែកកិច្ចដំណើរការនីតិវិធី គួរតែធានាផងដែរថា ចិរវេលានៃបទឧក្រិដ្ឋដែលបានរក្សាទុក គឺតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដើម ដោយគិតគូរពីរចំណុច៖ ទីមួយ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានបំបែកកិច្ចដំណើរការនីតិវិធី គួរតែតំណាងសមហេតុផលឱ្យខែ ឬឆ្នាំ ដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត ហើយទីពីរ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានបំបែកកិច្ចដំណើរការនីតិវិធី គួរតែឆ្លុះបញ្ចាំងពីដំណាក់កាលគន្លឹះណាមួយនៃការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនោះ[74]។ ជាចុងក្រោយ ក្នុងរឿងក្តី *Stanišić និង Simatović*, បន្ទាប់ពី

---

[73] *រដ្ឋអាជ្ញា ទល់នឹង Vojislav Seselj*, សំណុំរឿងលេខ៖ IT-03-67, សេចក្តីសម្រេចស្តីពីការអនុវត្តវិធាន៧៣*ស្ទួន*, (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ៨ វិច្ឆិកា ២០០៦, កថាខណ្ឌទី២៥-២៦។ *រដ្ឋអាជ្ញា ទល់នឹង Ramush Haradinaj និងគូកន.*, សំណុំរឿងលេខ៖ IT-04-84-A, សេចក្តីសម្រេច អនុលោមតាមវិធាន៧៣*ស្ទួន*(ឃ), (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ២២ កុម្ភៈ ២០០៧, កថាខណ្ឌទី១១។ *រដ្ឋអាជ្ញា ទល់នឹង StaniĖić និង Simatović*, សំណុំរឿងលេខ៖ IT-03-69-PT, សេចក្តីសម្រេច អនុលោមតាមវិធាន៧៣*ស្ទួន*(ឃ), (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ៤ កុម្ភៈ ២០០៨, កថាខណ្ឌទី២៦។

[74] *រដ្ឋអាជ្ញា ទល់នឹង StaniĖić និង Simatović*, សំណុំរឿងលេខ៖ IT-03-69-PT, សេចក្តីសម្រេច អនុលោមតាមវិធាន៧៣*ស្ទួន*(ឃ), (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ៤ កុម្ភៈ ២០០៨, កថាខណ្ឌទី២៨។ *រដ្ឋអាជ្ញា ទល់នឹង Gotovina, Cermak និង Markac*, សំណុំរឿងលេខ៖ IT-06-90-PT, ដីកាសម្រេចអនុលោមតាមវិធាន៧៣*ស្ទួន*(ឃ) ដើម្បីកាត់បន្ថយការបញ្ជូនរឿងទៅជំនុំជម្រះ, (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ២១ កុម្ភៈ ២០០៧, កថាខណ្ឌទី២-៤។

*Milutinović*, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី គួរតែតំណាងសមហេតុផលឲ្យ "ប្រភេទ ឬកម្មវត្ថុជាមូលដ្ឋាននៃរឿងក្តី"[75]។

## *បទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ*

៣៥- បទឧក្រិដ្ឋនានាដែលត្រូវបានបញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ ក្នុងសេចក្តីសម្រេចដែលរងការជំទាស់ គឺមិនតំណាងឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះពេញលេញទេ។ វិសាលភាពដែលមានតែបទឧក្រិដ្ឋមួយប្រភេទក្នុងចំណោមបីប្រភេទដែលត្រូវបានចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការពង្រីកវិសាលភាពសវនាការ ដើម្បីបញ្ចូលមន្ទីរ ស-២១ នឹងបន្ថែមបទឧក្រិដ្ឋស្តីពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ[76] ហេតុនេះ នឹងបង្កើនភាពជាតំណាងនៃសវនាការទៅដល់បទឧក្រិដ្ឋពីរប្រភេទក្នុងចំណោមប្រភេទទាំងបី។

៣៦- វិសាលភាពដែលមានស្រាប់នៃសំណុំរឿង ០០២/០១ ក៏ត្រូវបានកំហិតត្រឹមតែបទល្មើសជាក់លាក់ចំនួន ៦ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានបញ្ចូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូលគឺ៖ ការជម្លៀសដោយបង្ខំ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការបាត់ខ្លួនដោយបង្ខំ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល[77]។ ការពង្រីកវិសាលភាពសវនាការទៅដល់មន្ទីរស-២១ នឹងបន្ថែមបទល្មើសស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំនួន ៥ ទៀត ដូចជា៖ ការដាក់ក្នុងមន្ទីរឃុំឃាំង[78] ការធ្វើទារុណកម្ម[79] ការធ្វើឲ្យទៅជាទាសករ[80] ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍[81] និងការរំលោភផ្លូវភេទ[82]។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូង

---

[75] *រដ្ឋអាជ្ញា ទល់នឹង StaniÈić និង Simatović*, សំណុំរឿងលេខ៖ IT-03-69-PT, សេចក្តីសម្រេច អនុលោមតាមវិធាន ៧៣*ស្ទួន*(ឃ), (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ៤ កុម្ភៈ ២០០៨, កថាខណ្ឌទី៨-៩។

[76] ឯកសារ D427 ដីកាដំណោះស្រាយ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ១៤៧៩។

[77] ឯកសារ E124/7.3 បញ្ជីឈ្មោះកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/១, វាក្យខណ្ឌ៤។

[78] ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤០២។

[79] ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤០៨។

[80] ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៣៩១។

[81] ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤២២។

មានកំហុស ដោយមិនបានធានាថា វិសាលភាពនៃសំណុំរឿង ០០២/០១ តំណាងយ៉ាងពេញលេញចំពោះបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដោយបានសន្និដ្ឋានថា បទចោទបន្ថែមដែលពាក់ព័ន្ធនឹងមន្ទីរស-២១ នឹង "បន្ថែមភាពស៊ីជម្រៅ ជាជាងទំហំនៃបណ្តុំបទល្មើសដែលមានស្រាប់នៅក្នុងសំណុំរឿង ០០២/០១"[83]។ ការធ្វើទារុណកម្ម ការដាក់ក្នុងមន្ទីរឃុំឃាំង ការរំលោភផ្លូវភេទ និងការបំពារបំពានធ្ងន់ធ្ងរ គឺជាប្រភេទបទឧក្រិដ្ឋខុសគ្នាទាំងស្រុងពីបទឧក្រិដ្ឋនានាដែលត្រូវបានកម្រិតនៅក្នុងសំណុំរឿង ០០២/០១។

## *វិសាលភាពភូមិសាស្ត្រ ទំហំបទឧក្រិដ្ឋ និង ជនរងគ្រោះ*

៣៧- អង្គជំនុំជម្រះសាលាដំបូងមានកំហុសបន្ថែមទៀតក្នុងការសន្និដ្ឋានថា ទីតាំងឧក្រិដ្ឋកម្ម ឬបទចោទនានាក្រៅពីការផ្លាស់ទីលំនៅដោយបង្ខំ "បានកើតឡើងទាំងក្នុងទីកន្លែងតែមួយ ឬប្រឆាំងនឹងក្រុមសាសនាជាក់លាក់ ឬជាតិពន្ធុជាក់លាក់ណាមួយ"[84]។

៣៨- មន្ទីរស-២១ មានសភាពផ្ទុយពីមន្ទីរនៅមូលដ្ឋាន។ អ្នកទោសនៅមន្ទីរស-២១ មកពីគ្រប់ទីកន្លែងទូទាំងប្រទេស - គ្រប់ភូមិភាគ[85] គ្រប់កងពលយោធា[86] និងគ្រប់ក្រសួង ឬមន្ទីរទាំងអស់[87]។ អ្នកទោសទាំងនោះរួមមាន បុរស និងស្រី និងមនុស្សគ្រប់វ័យរួមទាំងកុមារផងដែរ[88]។ អ្នកទោសនៅមន្ទីរស-២១

82 ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤២៦។

83 ឯកសារ E284 សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១៤៧។

84 ឯកសារ E284 សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១២។

85 ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤៣១ ["កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និង សមាជិកកងទ័ពបដិវត្តន៍កម្ពុជា ដែលត្រូវបានចាប់ខ្លួន គឺមកពីគ្រប់ភូមិភាគ និង តំបន់ស្វយ័តទូទាំងប្រទេសកម្ពុជា"]។

86 ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤២៤; ឯកសារ D288/6.68.9 ឧបសម្ព័ន្ធ ៩៖ អ្នកទោសនៅមន្ទីរស២១ ដែលមកពីកងទ័ពបដិវត្តន៍កម្ពុជា។

87 ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤២៦ ដល់ ៤៣០; ឯកសារ D288/6.68.10 ឧបសម្ព័ន្ធ ១០៖ អ្នកទោសនៅមន្ទីរ ស២១ ដែលមកពីមន្ទីររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។

88 ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤២៣; ឯកសារ D288/6.68.6 ឧបសម្ព័ន្ធ ៦៖ អ្នកទោសនៅមន្ទីរស២១ ដែលបានបញ្ជាក់អត្តសញ្ញាណថាជាស្ត្រី [មានអ្នកទោសស្ត្រីចំនួន ១.៦៩៨ នាក់នៅមន្ទីរ ស២១]; ឯកសារ D288/6.68.7 ឧបសម្ព័ន្ធ ៧៖ អ្នកទោសនៅមន្ទីរ ស២១ ដែលបានបញ្ជាក់អត្តសញ្ញាណថាជាកុមារ [មានកុមារចំនួន

តំណាងឲ្យក្រុមជាតិសាសន៍ និងជាតិពន្ធុទាំងអស់ រួមមាន ជនជាតិវៀតណាម ចាម[89] ចិន[90] និងជនជាតិភាគតិចផ្សេងៗទៀត[91]។ មានមនុស្សដែលពាក់ព័ន្ធនឹងរបបសាធារណរដ្ឋខ្មែរ[92] គ្រូបង្រៀន សិស្ស គ្រូពេទ្យ និងមេធាវី[93] និងជនបរទេសដូចជា ជនជាតិថៃ ឡាវ ឥណ្ឌា និងពួកបច្ចិមប្រទេស[94]។ អ្នកទោសជាជនជាតិវៀតណាមនៅមន្ទីរស-២១ រួមមាន ទាហាន និងគិញ្ចដែលគេចាប់ខ្លួនបាន និងយកមកធ្វើជាឈ្លើយសឹក[95] និងជនស៊ីវិលដែលមានសញ្ជាតិ និងជាតិពន្ធុជាវៀតណាម[96]។ ពុំមានទីតាំងឧក្រិដ្ឋកម្មណាមួយផ្តល់គំរូពីភាពតំណាងឲ្យជនរងគ្រោះនៃបក្សកុម្មុយនីស្តកម្ពុជា ច្រើនជាងមន្ទីរ ស-២១ ទេ។ នៅក្នុងសាលក្រមលើសំណុំរឿង ០០១ របស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់នូវភាពជាតំណាងទូលំទូលាយនៃមន្ទីរសន្តិសុខស-២១ ដោយបានថ្លែងថា ជនរងគ្រោះនៅ

---

៨៩ នាក់ជាអ្នកទោសនៅមន្ទីរ ស២១]; ឯកសារ D288/6.68.5 ឧបសម្ព័ន្ធ ៥៖ អ្នកទោសនៅមន្ទីរ ស២១ ដែលបានបញ្ជាក់អត្តសញ្ញាណថាបុរស [មានអ្នកទោសបុរសចំនួន ៥.៩៩៤ នាក់]។

89 សូមមើល *ឧទាហរណ៍* ឯកសារ, D366/7.1.82 S-21 ចម្លើយសារភាពរបស់ យី សាឡេស យ៉ាស់យ៉ា (Yi Sales Yasya)។

90 E3/1654 S-21 បញ្ជីសួរចម្លើយ, ៨ មេសា ១៩៧៨, ERN 00234246-47 [បញ្ជីឈ្មោះ "អនិកជនចិន" ៨នាក់"]។ E3/1954 បញ្ជីអ្នកទោស ស-២១, ២៣ ឧសភា ១៩៧៨, ERN 00183835-36 [បញ្ជីកំណត់អត្តសញ្ញាណ "អនិកជនចិន" ៩នាក់ ដែលបានចាប់ឃុំនៅស-២១]។

91 ឯកសារលេខ D175/3.19 S-21 បញ្ជីសម្លាប់ ចុះថ្ងៃទី២១ ឧសភា ១៩៧៨ [ ក្នុងបញ្ជីរួមមាន "ជនជាតិភាគតិចភ្នង" ៤នាក់ពីមណ្ឌលគីរី]។ឯកសារលេខ E3/2285 S-21 បញ្ជីសម្លាប់ ចុះថ្ងៃទី២១ តុលា ១៩៧៧, ត្រង់លេខ ERN 00873667-68 [លេខ 45, 46 & 48 បញ្ជាក់អត្តសញ្ញាណថាជាជនជាតិចារ៉ាយ]។ ឯកសារលេខ E3/342 បញ្ជីអ្នកទោសស-២១ ពិនិត្យជាថ្មីឡើងវិញរបស់ កសព [លេខ 945, 946, 11812 & 11821 បញ្ជាក់អត្តសញ្ញាណថាជាជនជាតិចារ៉ាយ FULRO].

92 ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤៣២; ឯកសារ D288/6.68.24 ឧបសម្ព័ន្ធ ២៤៖ អ្នកទោសនៅមន្ទីរ ស២១ ដែលបានរៀបរាប់ថាជាអតីតទាហានសាធារណរដ្ឋខ្មែរ។

93 ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤២៣; ឯកសារ D288/6.68.26 ឧបសម្ព័ន្ធ ២៦៖ អ្នកទោសនៅមន្ទីរ ស២១ ដែល ដែលបានរៀបរាប់ថាជាគ្រូបង្រៀន សាស្ត្រាចារ្យ សិស្ស គ្រូពេទ្យ មេធាវី ឬ វិស្វករ [មានចំនួន ២៧៩ នាក់]។

94 ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤៣៣។

95 ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤៣២; ឯកសារ D288/6.68.28 ឧបសម្ព័ន្ធ ២៨៖ អ្នកទោសនៅមន្ទីរ ស២១ ដែលបានរៀបរាប់ថាជាទាហានវៀតណាម [មានចំនួន ១២២ នាក់]; ឯកសារ D288/6.68.29 ឧបសម្ព័ន្ធ ២៩៖ អ្នកទោសនៅមន្ទីរ ស២១ ដែលបានរៀបរាប់ថាជាគិញ្ចវៀតណាម [មានចំនួន ១៤៤ នាក់]។

96 ឯកសារ D288/6.68.30 ឧបសម្ព័ន្ធ ៣០៖ អ្នកទោសនៅមន្ទីរ ស២១ ដែលបានបញ្ជាក់អត្តសញ្ញាណថាជាជនជាតិវៀតណាម [មានចំនួន ៧៩ នាក់]។

មន្ទីរ ស-២១ មក "ពីគ្រប់ទីកន្លែងទូទាំងប្រទេស និងពីគ្រប់ផ្នែកនៃសង្គមកម្ពុជា" ហេតុនេះគឺថា "វិសាលភាពនៃសកម្មភាពរបស់វាគ្របដណ្តប់ទូទាំងប្រទេស"[97]។

៣៩- សេចក្តីសម្រេចដែលត្រូវបានជំទាស់ក៏មានកំហុសផងដែរ ក្នុងការសន្និដ្ឋានថា "ប្រជាជនកម្ពុជាទាំងមូល" ត្រូវទទួលរងប៉ះពាល់ដោយសារការជម្លៀសដោយបង្ខំ ហើយថា ការជម្លៀសដោយបង្ខំ "ដែលជាក់ស្តែងបានប៉ះពាល់ដល់ជនរងគ្រោះទាំងអស់នៃរបបខ្មែរក្រហម"[98]។ វាជាការពិតណាស់ ដែលថាជនរងគ្រោះនៃការជម្លៀសដោយបង្ខំមានចំនួនច្រើនណាស់។ ទោះជាយ៉ាងណាក្តី អ្នកដែលត្រូវគេជម្លៀសដោយបង្ខំ គឺជាប្រជាជនកម្ពុជាដែលមកពីទីក្រុង[99]។

៤០- ឧទាហរណ៍មួយដែលសំណុំរឿង ០០២/០១ មិនតំណាងឲ្យក្រុមជនរងគ្រោះទាំងអស់ពីដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ គឺភាពជាតំណាងដល់ជាតិពន្ធុរបស់សំណុំរឿងនេះ។ ទោះបីវិសាលភាពដែលមានស្រាប់នៃសំណុំរឿង ០០២/០១ រួមមានបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនខ្មែរ និង ការជម្លៀសដោយបង្ខំដល់ជនជាតិចាមក៏ដោយ[100] តែវិសាលភាពនេះមិនបានបញ្ចូលនូវបទឧក្រិដ្ឋនានាដែលកំណត់ជាគោលដៅជាក់លាក់នៃក្រុមជាតិពន្ធុវៀតណាម ដូចជាការនិរទេសជនជាតិវៀតណាមចេញពីប្រទេសកម្ពុជាទេ[101]។ ការបន្ថែមមន្ទីរស-២១ នឹងជួយកែតម្រូវកំហុសឆ្គងនេះ ដោយបញ្ចូលបទចោទនានាដែលមានទំនាក់ទំនង ជាពិសេស ទៅនឹងអ្នកទោសវៀតណាមដែលត្រូវបានឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរសន្តិសុខស-២១។

៤១- អង្គជំនុំជម្រះសាលាដំបូងមានកំហុសបន្ថែមទៀត ដោយប្រៀបធៀបចំនួនជនរងគ្រោះពីមន្ទីរស-២១ ("យ៉ាងហោចណាស់មានចំនួន ១២.២៧៣ នាក់")[102] ទៅនឹងចំនួនមនុស្សស្លាប់សរុបក្នុងរបបកម្ពុជា

---

97 ឯកសារ E188 សាលក្រមលើសំណុំរឿង ០០១, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ២៣, ៣២៣។

98 ឯកសារ E284 សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១២, ១១៤។

99 ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌទី ១៦២ និងទី២៥០ [CPK "គោលនយោបាយរបស់ បកក ស្តីពីការឲ្យប្រជាជនជម្លៀសចេញពីទីក្រុងនិងទីប្រជុំជននានា"]។

100 ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ២៦៦, ២៦៨, ២៨១។

101 ឯកសារលេខ D427 ដីកាដំណោះស្រាយ, កថាខណ្ឌទី ៧៩៤-៧៩៦។

102 ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤២៣, ៤៦០។ គួរកត់សម្គាល់ថា នៅក្នុងសាលក្រមលើសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា នេះជា "ចំនួនអប្បបរមារបស់ជនរងគ្រោះមន្ទីរ ស២១ ប៉ុណ្ណោះ" ហើយ

ប្រជាធិបតេយ្យទាំងមូល (ពី ១,៧ ទៅ ២,២ លាននាក់)[103]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនបាន ចោទប្រកាន់ជនជាប់ចោទពីការស្លាប់ទាំងអស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬសូម្បីតែការស្លាប់ដោយអំពើហិង្សាទាំងអស់នោះដែរ (អ្នកជំនាញផ្នែកប្រជាសាស្ត្របានប៉ាន់ស្មានថា មានចំនួន ៨០០.០០០ នាក់)[104] ហើយមានកំហុសដែលធ្វើការប្រៀបធៀបចំនួនជនរងគ្រោះនៅមន្ទីរស-២១ ទៅនឹងចំនួនមនុស្សស្លាប់សរុបក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

៤២- ក្នុងការការពារភាពជាតំណាងនៃសវនាការលើការជម្លៀសប្រជាជនដោយបង្ខំនោះ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា "ការស្លាប់មនុស្សរាប់មិនអស់" បានកើតឡើងដោយសារការអត់អាហារ ការគ្មានការព្យាបាល និងតម្រូវការចាំបាច់ផ្សេងទៀត នៅក្នុងអំឡុងពេល និងបន្ទាប់ពីការជម្លៀសប្រជាជនដោយបង្ខំ[105]។ ទោះជាយ៉ាងណាសក្តិ ការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយដែលដកស្រង់នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ គឺជាផ្នែកបទចោទអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស[106]។ មានតែបទចោទពីការធ្វើមនុស្សឃាតតែមួយគត់ដែលត្រូវបានបញ្ចូលពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំ គឺជាការចោទប្រកាន់ពីកថាខណ្ឌ ១៣៧៧ នៃដីកាដំណោះស្រាយ៖ "ប្រសិនបើគោលដៅចម្បងនៃការផ្លាស់ទីលំនៅប្រជាជន និងការធ្វើការដោយបង្ខំ ពុំមែនដើម្បីសម្លាប់មនុស្សដែលជាមុខសញ្ញាទេនោះ ក៏ភស្តុតាងនៃសំណុំរឿងបង្ហាញថា **មនុស្ស**ត្រូវបានសម្លាប់ដោយ កងទ័ពខ្មែរក្រហមនៅមុនពេល នៅក្នុងពេល ឬនៅពេលទៅដល់នៃការផ្លាស់ទីលំនៅ ដំណាក់កាលទី១ និងទី៣"[107]។ ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានអនុម័តយកទម្រង់នៃការទទួលខុសត្រូវជាសហកម្មឧក្រិដ្ឋកម្មទម្រង់ទី៣ ដែលចាំបាច់ ដើម្បីផ្តន្ទាទោសជនជាប់ចោទពីការស្លាប់ដែលអាចដឹងជាមុន តែដោយអចេតនា ដែលកើតឡើងពីការជម្លៀសប្រជាជនទៅតាមផែនការនោះទេ។

---

ថា "ចំនួនជនរងគ្រោះពិតប្រាកដទំនងជាច្រើនជាងចំនួនដែលមាននៅក្នុងបញ្ជីនេះ"។ ឯកសារ E188 សាលក្រមលើសំណុំរឿង ០០១, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ១៤១, ១៤៣។

[103] ឯកសារ E284 សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១០។

[104] [បន្ថែមអត្ថបទយោង]។

[105] ឯកសារ E284 សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១០។

[106] ឯកសារ E284 សេចក្តីសម្រេចដែលត្រូវបានជំទាស់, ជើងទំព័រលេខ ២០៩; ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤៣៦។

[107] ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៣៧៧ (គូសបញ្ជាក់បន្ថែម)។

៤៣- វិសាលភាពដែលមាននៃសំណុំរឿង ០០២/០១ រួមមានបទចោទដែលកំហិតត្រឹមតែបទឧក្រិដ្ឋនៃការធ្វើមនុស្សឃាត និងមិនបានតំណាងយ៉ាងពេញលេញដល់ចំនួន និង ប្រភេទជនរងគ្រោះដែលត្រូវបានចាប់ខ្លួន ឃុំឃាំង និងសម្លាប់នៅតាមមន្ទីរសន្តិសុខនានារបស់របបកម្ពុជាប្រជាធិបតេយ្យ ហើយក៏មិនតំណាងពីទំហំ ភាពទៀងទាត់ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋទាំងនោះដែរ។ មន្ទីរ ស-២១ គឺជាទីតាំងឧក្រិដ្ឋកម្មតែមួយគត់ដែលនៅមានភស្តុតាងជាឯកសារដែលបញ្ជាក់ពីអត្តសញ្ញាណ និងចំនួនជនរងគ្រោះ[108] ហើយបើពាក់ព័ន្ធនឹងការសម្លាប់មនុស្សដែលមានការបញ្ជាក់វិញ វាជាទីតាំងសម្លាប់មនុស្សដែលសំខាន់ជាងគេនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## *វិសាលភាពពេលវេលា*

៤៤- វិសាលភាពពេលវេលានៃសំណុំរឿង ០០២/០១ ក៏មិនតំណាងឲ្យដីកាបញ្ជូនរឿងជំនុំជម្រះទាំងមូលឡើយ ដែលត្រូវបានកំហិតលំដាប់លំដោយពេលវេលាត្រឹមផ្នែកដំបូង នៃរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ។ ឧក្រិដ្ឋកម្មទាំងប៉ុន្មានដែលត្រូវបានដាក់បញ្ចូលក្នុងវិសាលភាពនាពេលបច្ចុប្បន្ន នៃសំណុំរឿង ០០២/០១ ត្រូវបានកំហិតត្រឹមការផ្លាស់ទីលំនៅប្រជាជននៅទីក្រុងភ្នំពេញដោយបង្ខំនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងនៅសប្តាហ៍បន្ទាប់មកទៀត ការសម្លាប់នៅទួលពោធិ៍ជ្រៃនៅចុងខែមេសា **ឆ្នាំ ១៩៧៥** និងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំលើកទី២ ដែលបានចាប់ផ្តើមនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ និងបានបន្តដល់ឆ្នាំបន្ទាប់មកទៀត[109]។ ចំណែកមន្ទីរសន្តិសុខ ស-២១

---

108 ឯកសារលេខ **E109/4.9** ឧបសម្ព័ន្ធទី 9 é កំណត់ហេតុអ្នកទោសស-២១, បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨០(៣)(ឃ) [ ដែលបញ្ជាក់អត្តសញ្ញាណឯកសារចំណួន 337 ដែលក្នុងនោះរួមមាន បញ្ជីអ្នកទោសស-២១, សៀវភៅបញ្ជីសួរចម្លើយ និងសៀវភៅបញ្ជីសម្លាប់], បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨០(៣)(ឃ) [ដែលបញ្ជាក់អត្តសញ្ញាណឯកសារចំនួន 337 ដែលរួមមាន បញ្ជីអ្នកទោសស-២១, សៀវភៅបញ្ជីសួរចម្លើយ និងសៀវភៅបញ្ជីសម្លាប់]

109 ឯកសារលេខ **D427**ដីកាដំណោះស្រាយ, កថាខណ្ឌ ២២៤, ២៦២ និង ៧០៥។ ឯកសារលេខ **E3/216** កំណត់ហេតុស្តីពីទស្សនកិច្ចរបស់គណៈកម្មធិការអចិន្ត្រៃយ៍ទៅកានភូមិភាគពាយ័ព្យ, ពីថ្ងៃទី២០-២៤ សីហា ឆ្នាំ១៩៧៥ គួរបានធ្វើការកត់សំគាល់ថាការចោទប្រកាន់នានានៅក្នុងដីកាដំណោះស្រាយទាក់ទងនឹងការសម្លាប់នៅទទួពោធិ៍ជ្រៃពីឆ្នាំ១៩៧៦ ដល់ ១៩៧៧ (កថា. 712-713) ត្រូវបានលប់បេញដោយអង្គជំនុំជម្រះសាលាដំបូងពីក្នុងវិសាលភាពនៃសំណុំរឿងលេខ ០០២/០១។ ឯកសារលេខ**E124/7.3** បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនិងសំណុំរឿងលេខ០០២/០១ផ្នែកទី២។

បានប្រតិបត្តិការចាប់ពីខែតុលា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩[110]។ ហេតុដូច្នេះ ការដាក់បន្ថែមមន្ទីរ ស-២១ នឹងធ្វើឲ្យការជំនុំជម្រះលើសំណុំរឿង ០០២/០១ តំណាងឲ្យរយៈពេលទាំងអស់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វានឹងធានាបានថាសំណុំរឿង០០២/០១ ឆ្លុះបញ្ចាំងនូវដំណាក់កាលដល់សំខាន់នៃឧក្រិដ្ឋកម្មក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ដោយរួមបញ្ចូលការកំណត់គោលដៅដំបូងចំពោះបុគ្គលដែលមានការពាក់ព័ន្ធនឹងរបបសាធារណរដ្ឋ[111] ការបោសសម្អាត RAK បានចាប់ផ្តើមនៅពាក់កណ្តាល ឆ្នាំ១៩៧៦[112] និងការបោសសម្អាតខ្លាំងក្លានៅភូមិភាគឧត្តរ ក្នុងឆ្នាំ១៩៧៧[113] ហើយនិងភូមិភាគបូព៌ា និងជនជាតិវៀតណាមក្នុងឆ្នាំ១៩៧៨[114]។ វាក៏នឹងធានាបានថាភស្តុតាងជាច្រើនសន្ធឹកសន្ធាប់ ដែលត្រូវបានបង្ហាញទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ រចនាសម្ព័ន្ធរដ្ឋបាលប្រព័ន្ធទាក់ទងការងារ និងគោលនយោបាយនៅក្នុងរយៈកាលពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ មានគោលបំណងជាក់លាក់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មជាក់ស្តែង [115]។

## *លក្ខណៈ ឬប្រធានបទជាសារវន្តនៃសំណុំរឿង*

៤៥- សេចក្តីសម្រេចដែលរងការជំទាស់មានការភ័ន្តច្រឡំ តាមរយៈការខកខានពុំបានពិចារណាឃើញថា "លក្ខណៈ ឬប្រធានបទជាសារវន្ត" នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ គឺជាការចោទ

---

[110] ដីកាដំណោះស្រាយ ឯកសារ D427, កថាខណ្ឌ ៤១៦។

[111] ឯកសារលេខ E3/1539 បញ្ជីអ្នកទោសស-២១, ខែមីនា ១៩៧៦ [ដែលបញ្ជាក់អត្តសញ្ញាណនៃពួកទាហាន និងមន្ត្រីរបស់លន់នល់ និងបងប្អូនសាច់ញាតិ ចំនួន១៦២នាក់ ដែលត្រូវបានសម្លាប់នៅមន្ទីស-២១].

[112] ឯកសារលេខ D288/6.68.9 ឧបសម្ព័ន្ធទី 9 é បញ្ជីអ្នកទោសស-២១ដែលមកពីកងទ័ពបដិវត្តន៍កម្ពុជា។

[113] ឯកសារលេខ D427ដីកាដំណោះស្រាយ, កថាខណ្ឌ ៤៣១ (" ចំនួនអ្នកទោសដែលមកពីអតីតភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) បានកើនឡើងដល់៣៦០នាក់សំរាប់តរយៈពេលទាំងមូល, ដោយមានការចាប់ខ្លួនជាង៨០នាក់ពីភូមិភាគឧត្តរចាស់នៅក្នុងខែកុម្ភៈ១៩៧៧")។ឯកសារលេខ D288/6.68.48 ការចាប់ខ្លួនជាង៨០នាក់ពីភូមិភាគឧត្តរចាស់ /អតីតភូមិភាគកណ្តាល។

[114] ឯកសារលេខD427 ដីកាដំណោះស្រាយ ឯកសារ D427, កថាខណ្ឌ ៤៣១ ("សំរាប់ភូមិភាគបូព៌ា, ចំនួនការចាប់ខ្លួនបានកើលដល់ 1165នាក់ ដោយមានការចាប់ខ្លួនជិត៥០០នាក់ នៅក្នុងខែមិថុនា ១៩៧៨");ឯកសារលេខ D288/6.68.46 ការចាប់ខ្លួនពីភូមិភាគបូព៌ាទៅគិតតាមខែ។ ដីកាដំណោះស្រាយ ឯកសារ D427, កថាខណ្ឌ ៤៣៣ (ចំនួនអ្នកទោសវៀតណាមកើនឡើងនៅពេលមានជម្លោះជាមួយវៀតណាមកើនឡើងដែរ)។ D288/6.68.27 ឧបសម្ពន្ធ ២៧, អ្នកទោសវៀតណាមចូលស-២១។

[115] ឯកសារ E284 សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១១៧ [ដែលបានកត់សម្គាល់ថាសហព្រះរាជអាជ្ញានៅតែអាចប្រើប្រាស់ "ភស្តុតាងជាច្រើនឲ្យអស់លទ្ធភាព ដែលមាននៅចំពោះមុខអង្គជំនុំជម្រះទាក់ទងនឹង ស២១ ក្នុងកម្រិតដែលពាក់ព័ន្ធនឹងថ្នាក់ដឹកនាំ ឬរចនាសម្ព័ន្ធទំនាក់ទំនងការងារ ឬចំណុចសំខាន់ទូទៅផ្សេងទៀតនៅក្នុងសំណុំរឿង ០០២/០១"]។

ថាប្រជាជនកម្ពុជាចំនួនរាប់សែននាក់ ត្រូវបានឃុំឃាំងដោយខុសច្បាប់ រងការធ្វើទារុណកម្ម និងត្រូវបានសម្លាប់នៅតាមបណ្តាញមន្ទីរសន្តិសុខ ដោយអនុលោមតាមគោលនយោបាយ និងសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃ ប.ក.ក។ ជនជាប់ចោទត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្មនានា នៅតាមមន្ទីរសន្តិសុខចំនួន ១១ កន្លែងខុសៗគ្នា ដែលជាទីតាំងឧក្រិដ្ឋកម្មមានបរិយាយច្រើនជាងគេនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[116] ។

៤៦- ការជំនុំជម្រះមួយតូចជាងនេះ មិនអាចត្រូវបានចាត់ទុកជាតំណាងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូលឡើយ ប្រសិនបើការជំនុំជម្រះនោះពុំដាក់បញ្ចូលមន្ទីរសន្តិសុខមួយ ក្នុងចំណោមមន្ទីរសន្តិសុខទាំងឡាយ ហើយមិនមានការសង្ស័យឡើយថាមន្ទីរស-២១ តំណាងឲ្យទីតាំងឧក្រិដ្ឋកម្មទាំងនោះច្រើនជាងគេ។ Philip Short ដែលអង្គជំនុំជម្រះទទួលស្គាល់ជាអ្នកជំនាញ និងបានកោះហៅមកផ្តល់សក្ខីកម្មនៅក្នុងការជំនុំជម្រះលើសំណុំរឿង ០០២/០១ ចាត់ទុកមន្ទីរស-២១ ជា "ចំណុចកំពូល, ជាតំណាង ជាការឆ្លុះបញ្ចាំងនៅក្នុងទម្រង់រួមនៃរដ្ឋទាសភាព" ដែល ប៉ុល ពត និង ប.ក.ក បានបង្កើតឡើង[117]។ អង្គជំនុំជម្រះសាលាដំបូងកន្លងមកធ្លាប់បានទទួលស្គាល់អំពីសារៈសំខាន់នៃមន្ទីរសន្តិសុខ ស-២១ ដោយបានគូសបញ្ជាក់នៅក្នុងសាលក្រមលើសំណុំរឿង ០០១ របស់ខ្លួនថា "មន្ទីរ ស-២១ គឺជាមន្ទីរសន្តិសុខសំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចាត់ទុកជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយរាយការណ៍ទៅថ្នាក់ដឹកនាំខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ធ្វើប្រតិបត្តិការពាសពេញប្រទេស និងទទួលកម្មាភិបាលឋានៈខ្ពស់ និងអ្នកទោសសំខាន់ៗ"[118]។

៤៧- មន្ទីរស-២១ក៏ជាទីតាំងឧក្រិដ្ឋកម្មដែលទាក់ទងស្អិតរមួតទៅនឹងជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ ផងដែរ។ ភស្តុតាងនានាដែលបញ្ជាក់អំពីទំនាក់ទំនងផ្ទាល់រវាងជនជាប់ចោទ នឹងមន្ទីរស-២១ ធ្លាប់ត្រូវបានអង្គជំនុំជម្រះសាលាដំបូងស្តាប់ ក្នុងលក្ខណៈជាផ្នែកមួយនៃចំណុចអង្គហេតុដែលត្រូវធ្វើសវនាការលើសំណុំរឿង ០០២/០១ ទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ គោលនយោបាយសហឧក្រិដ្ឋកម្មរួម រចនាសម្ព័ន្ធរដ្ឋបាល និងយោធា និងប្រព័ន្ធទំនាក់ទំនងការងារ[119]។ ភស្តុតាងនេះរួមបញ្ចូលទាំងសក្ខីកម្មរបស់ ឌុច ដែលជាប្រធានមន្ទីរស-២១ អ្នកជំនាញ David Chandler និង

---

116 ដីកាដំណោះស្រាយ ឯកសារ D427, កថាខណ្ឌ ៩១៥-៦៨៥។

117 ឯកសារ E3/9 Philip Short, *ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់* ជាភាសាអង់គ្លេស ENG 00396573 (ទំព័រ ៣៦៥)។

118 ឯកសារ E188 សាលក្រមសំណុំរឿង ០០១, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ២៣។

119 ឯកសារ E284 សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១១៧។

មេដឹកនាំនានានៃ ប.ក.ក មកពីតំបន់ទាំងឡាយ និងកងទ័ពបដិវត្តកម្ពុជា ដែលបញ្ជាក់អំពីទំនួលខុសត្រូវរបស់មជ្ឈិមបក្សចំពោះការសម្រេចទាំងឡាយ និងគោលនយោបាយនានាទាក់ទងនឹងមន្ទីរស-២១ និងការចាប់ខ្លួនខ្មាំង[120] ព្រមទាំងឯកសារមកពីមន្ទីរស-២១ ដែលមានចំណារដែលបញ្ជាក់អំពីការដឹងឮ និងការចូលរួមរបស់ នួន ជា និងមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យផ្សេងៗ[121]។ ប្រការសំខាន់បំផុត មន្ទីរស-២១ ស្ថិតក្រោមការគ្រប់គ្រងរបស់ នួន ជា អស់មួយរយៈក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយនៅគ្រប់ដំណាក់កាលនៃរបបនេះ ស-២១ គឺជាមន្ទីរសន្តិសុខតែមួយគត់នៅក្នុងប្រទេសដែលបានរាយការណ៍ផ្ទាល់ទៅ "ថ្នាក់កំពូលរបស់បក្ស"[122]។ នួន ជា ត្រូវបានដីកាបញ្ជូនរឿងទៅជំនុំជម្រះចោទប្រកាន់ថាបានបញ្ជាដោយផ្ទាល់ ឲ្យមានការសម្លាប់អ្នកទោសនៅមន្ទីរស-២១[123]។

៤៨- អង្គជំនុំជម្រះសាលាដំបូងបានភ័ន្តច្រឡំ នៅក្នុងការខកខានមិនបានពិនិត្យពិចារណាអំពីទំនាក់ទំនងស្អិតរមួតរវាងជនជាប់ចោទ និងទីតាំងឧក្រិដ្ឋកម្មនេះ ដែលជាកត្តាសំខាន់មួយដែលធ្វើឲ្យមានភាពចាំបាច់ក្នុងការ<u>មិន</u>បំបែកមន្ទីរស-២១ ចេញពីបទចោទនានាដែល នួន ជា និង ខៀវ សំផន នឹងត្រូវបានចោទប្រកាន់។ ជាការបរាជ័យយ៉ាងធ្ងន់ធ្ងរនៅក្នុងការស្វែងរកយុត្តិធម៌ ប្រសិនបើការជំនុំជម្រះមួយនេះប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់ទាំងនេះ មិនរួមបញ្ចូលមន្ទីរសន្តិសុខមួយដែលបានធ្វើរបាយការណ៍ផ្ទាល់ទៅពួកគាត់ ហើយពិតជាមិនអាចនិយាយបាន ដោយអនុលោមតាមវិធាន៨៩*ស្ទួន២* ថា "ផលប្រយោជន៍នៃយុត្តិធម៌" តម្រូវឲ្យមានការបំបែកទីតាំងឧក្រិដ្ឋកម្មដ៏សំខាន់មួយនេះឡើយ។

---

[120] ឯកសារ**E163/5/1/1.2** ឧបសម្ព័ន្ធទី I: គំរូតំណាងនៃភស្តុតាងសក្ខីកម្មនិង ឯកសារភស្តុតាងដែលបានបង្ហាញជាភស្តុតាងនៅក្នុងសំណុំរឿងលេខ 002/01។ ឯកសារលេខ **E163/5/1/1** បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសំរេចទាក់ទងទៅវិសាលភាពនៃសំណុំរឿងលេខ នឹង 002/01, ចុះថ្ងៃទី ៧ វិច្ឆិកា ឆ្នាំ ២០១២, ពីកថាខណ្ឌទី. 77-80។ E163/5/1/10 ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ នួន ជា អំពីបណ្តឹងសាទុក្ខពាក់ព័ន្ធ នឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ០០២/០១ ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ២៣។

[121] សូមមើល E3/1565 ចម្លើយសារភាពរបស់ គង់ គៀន ហៅ អ៊ឹង វ៉េត នៅមន្ទីរ ស-២១ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៧៧ ERN KH 00017305, ERN EN 00822048[ចំណារ " ផ្ញើផ្ទាល់ជូនបងនួន" កំណត់អត្តសញ្ញាណដោយ ឌុច ថា ជាអក្សរ សុន សេន និង ចំណារបន្ថែមទៀត "ចំណារដែលផ្ញើទៅសមមិត្ត ម៉ុក" កំណត់អត្តសញ្ញាណដោយ ឌុច ថាជាអក្សរដៃរបស់ នួន ជា, E3/1705 ចំលើយសារភាពរបស់កែគីមហួតហៅសុទនៅថ្ងៃទី២៩ មេសា ១៩៧៨, ERN KH 00014150, ERN EN 00242282 [មានចំណារ "ខៀវ សំផន ហៅ ហែម"] ។

[122] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ 422, 952, 959-961, 972-973, 1062, 1183, 1185; សាលក្រមលើសំណុំរឿង ០០១ ឯកសារ **E188**, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ២៣។

[123] ដីកាដំណោះស្រាយ ឯកសារ **D427**, កថាខណ្ឌ ៩៧០, ៩៧២-៩៧៣។

## *សវនាការពាក់ព័ន្ធនឹងមន្ទីរស-២១ កាលពីពេលមុន*

៤៩- នៅក្នុងការសម្រេចថាតើអង្គជំនុំជម្រះគួរជំនុំជម្រះ នួន ជា និង ខៀវ សំផន អំពីបទចោទអ្វីខ្លះនៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានភ័ន្តច្រឡំបន្ថែមទៀតនៅត្រង់ចំណុចដែលខ្លួនបានសម្អាងលើអង្គហេតុដែលខ្លួនធ្លាប់បានធ្វើការជំនុំជម្រះ ឌុច ប្រធានមន្ទីរស-២១[124]។ ការជំនុំជម្រះលើសំណុំរឿង ០០១ ផ្តោតលើការទទួលខុសត្រូវរបស់ប្រធានគុកចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តនៅទីកន្លែងដែលគាត់ធ្វើប្រតិបត្តិការ។ បទចោទនៅក្នុងសំណុំរឿង ០០២ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន ពាក់ព័ន្ធនឹងបញ្ហាមួយដែលខុសពីបទចោទនៅក្នុងសំណុំរឿង០០១ និងដែលមានសារៈសំខាន់ជាងសំណុំរឿង ០០១ ដែល នួន ជា និង ខៀវ សំផន ជាអ្នកទទួលខុសត្រូវចំពោះការសម្រេច និងគោលនយោបាយទាំងឡាយដែលបាននាំឲ្យមានការចាប់ខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់មនុស្សចំនួន ជាង ១២.០០០ នាក់នៅមន្ទីរស-២១។ ដូចដែលបានបញ្ជាក់ពីខាងលើ មន្ទីរស-២១ ជាតំណាងល្អបំផុតនៃឧក្រិដ្ឋកម្មស្នូល ដែលជនជាប់ចោទត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើសំណុំរឿង ០០២ <u>ហើយ</u> ជាទីតាំងឧក្រិដ្ឋកម្មដែលទាក់ទងស្និតរមួតទៅនឹងមេដឹកនាំជាន់ខ្ពស់ទាំងនោះ។ អង្គជំនុំជម្រះសាលាដំបូងគួរបានកំហិតការវិភាគរបស់ខ្លួនត្រឹមថាតើមន្ទីរ ស-២១ តំណាងឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរ ឬយ៉ាងណា ហើយថាតើជាផលប្រយោជន៍នៃយុត្តិធម៌ដែរឬយ៉ាងណា ក្នុងការបំបែក (និងបញ្ចប់ប្រកបដោយប្រសិទ្ធភាព) នូវបទចោទទាំងឡាយប្រឆាំងនឹងជនជាប់ចោទទាក់ទងនឹងមន្ទីរសន្តិសុខមួយដែលបានរាយការណ៍ផ្ទាល់ទៅពួកគាត់។ វាជាការភ័ន្តច្រឡំរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការពិនិត្យពិចារណាអំពីសំណុំរឿងដទៃទៀតប្រឆាំងនឹងជនជាប់ចោទផ្សេងៗនៅក្នុងការវាយតម្លៃនេះ។

៥០- ការភ័ន្តច្រឡំអំពីអង្គច្បាប់ និងអង្គហេតុ ដូចមានរៀបរាប់នៅក្នុងផ្នែក IV.ក និង IV.ខ ធ្វើឲ្យមោឃៈសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាវិសាលភាពមានស្រាប់នៃសំណុំរឿង ០០២/០១ គឺតំណាងឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូលយ៉ាងសមស្រប និងតម្រូវឲ្យមានការដាក់បញ្ចូលមន្ទីរស-២១ ដើម្បីបញ្ចៀសបរាជ័យក្នុងការស្វែងរកយុត្តិធម៌។ សេចក្តីសម្រេចដែលត្រូវ

---

[124] សេចក្តីសម្រេចដែលត្រូវបានជំទាស់ ឯកសារ E284 កថាខណ្ឌ ១១២ ("អង្គជំនុំជម្រះសាលាដំបូងក៏ត្រូវពិចារណានូវការស្នើសុំដាក់បញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នូវទីតាំងឧក្រិដ្ឋកម្មតែមួយគត់ដែល អ.វ.ត.ក បានវិនិច្ឆ័យរួចមកហើយមកទល់នឹងពេលបច្ចុប្បន្ននេះ ថាតើវាចាំបាច់ដែរ ឬយ៉ាងណា")។ *សូមមើលផងដែរ* ឯកសារ E163/5/1/13/1 ការណែនាំដល់ភាគីនានាដោយសារតែមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣, កថាខណ្ឌ ៣(iv)។

រងការជំទាស់ទទួលស្គាល់យ៉ាងច្បាស់ថាអង្គជំនុំជម្រះតុលាការកំពូលមាន "យុត្តាធិការនៃការកែតម្រូវ" ដែលអាចបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូង "ដាក់បន្ថែមមន្ទីរស-២១"[125]។

## គ. អង្គជំនុំជម្រះសាលាដំបូងបានភ័ន្តច្រឡំនៅក្នុងការសន្និដ្ឋានថាការដាក់បន្ថែមមន្ទីរស-២១ នឹងធ្វើឲ្យសវនាការអូសបន្លាយពេលយូរ

៥១- សេចក្តីសម្រេចដែលរងការជំទាស់សន្និដ្ឋានថាការដាក់បន្ថែមមន្ទីរស-២១ នឹងធ្វើឲ្យសវនាការលើសំណុំរឿង ០០២/០១ អូសបន្លាយពេលយូរ និង "ប៉ះពាល់ដល់លទ្ធភាពរបស់អង្គជំនុំជម្រះក្នុងការចេញសាលក្រមឲ្យបានទាន់ពេលវេលាក្នុងសំណុំរឿង០០២/០១" មុនពេលជនជាប់ចោទដែលនៅសេសសល់ ស្លាប់ ឬបាត់បង់សមត្ថភាព[126]។ យ៉ាងណាមិញ ដូចដែលបង្ហាញដូចខាងក្រោមនេះ មិនមានមូលដ្ឋានសមស្របណាមួយដើម្បីសន្និដ្ឋានថាពេលវេលាដ៏ខ្លីនៃសវនាការបន្ថែម ចាំបាច់ដើម្បីដាក់បញ្ចូលមន្ទីរស-២១ ទៅក្នុងសំណុំរឿង០០២/០១ នឹងបង្កើនហានិភ័យខ្ពស់ដែលថាអង្គជំនុំជម្រះសាលាដំបូងមិនអាចចេញសាលក្រម មុនពេលជនជាប់ចោទស្លាប់ ឬបាត់បង់សមត្ថភាពឡើយ។ ការភ័ន្តច្រឡំអំពីអង្គហេតុទាំងនេះ និងការភ័ន្តច្រឡំនៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង បានប៉ះពាល់ជាខ្លាំងដល់ប្រយោជន៍របស់សហព្រះរាជអាជ្ញា តាមរយៈការរារាំងប្រកបដោយប្រសិទ្ធភាព មិនឲ្យសហព្រះរាជអាជ្ញាចោទប្រកាន់ជនជាប់ចោទចំពោះបទចោទសំខាន់ៗ និងធ្ងន់ធ្ងរបំផុតនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២។

### *i. សេចក្តីសន្និដ្ឋានថា ការដាក់បញ្ចូលមន្ទីរស-២១ នឹងមាន "ផលប៉ះពាល់មិនច្បាស់លាស់អំពីរយៈពេលនៃកិច្ចដំណើរការនីតិវិធី"*

៥២- អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសម្រេចថា ផលប៉ះពាល់អំពីរយៈពេលនៃកិច្ចដំណើរការនីតិវិធី ប្រសិនបើមន្ទីរ ស២១ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ០០២/០១ មានលក្ខណៈ "មិនច្បាស់លាស់" និង "អាចប្រឈមនឹងការពន្យារពេលកិច្ចដំណើរការនីតិវិធីដ៏យូរ ឬដោយគ្មានពេលកំណត់"[127]។

---

125 សេចក្តីសម្រេចដែលត្រូវបានជំទាស់ ឯកសារ E284 កថាខណ្ឌ ៩៥។

126 សេចក្តីសម្រេចដែលត្រូវបានជំទាស់ ឯកសារ E284 កថាខណ្ឌ ១៣៧។

127 ឯកសារ E284 សេចក្តីសម្រេចដែលរងការជំទាស់ ផ្នែក ៤.៣.៣ & កថាខណ្ឌ ១៣៨។

៩៣- នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានដាក់កាលវិភាគសម្រាប់សវនាការដែលបានស្នើឡើង ដែលរួមមានផែនការដាក់លាក់សម្រាប់ការបញ្ចប់កិច្ចដំណើរការនីតិវិធីឲ្យបានឆាប់រហ័ស។ អនុលោមតាមកាលវិភាគនេះ ពេលវេលាសម្រាប់សវនាការបន្ថែម ដែលបណ្តាលមកពីការដាក់ បញ្ចូល មន្ទីរស-២១ នឹងត្រូវបានកម្រិតត្រឹមរយៈពេលមួយខែ[128]។ សហព្រះរាជអាជ្ញាបានស្នើឡើងនូវរយៈពេលអតិបរមា ១៥ថ្ងៃ សម្រាប់ការធ្វើសក្ខីកម្មរបស់សាក្សី រួមមាន រយៈពេល ១១ថ្ងៃ សម្រាប់សាក្សី មន្ទីរស-២១ ចំនួន ៥នាក់ ដែលត្រូវបានស្នើសុំរួចហើយកាលពីលើកមុនដោយសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី នួន ជា និង "ការកំណត់រយៈពេលចំនួន ០៤ថ្ងៃ ទុកសម្រាប់សាក្សីក្រោយៗ ដែលមេធាវីការពារក្តី ឬដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំ ហើយដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាចាំបាច់"[129]។

៩៤- ការសម្រេចអំពីចំនួនសាក្សីទាក់ទិននឹងមន្ទីរស-២១ ដែលនឹងផ្តល់សក្ខីកម្ម និងរយៈពេលនៃការផ្តល់សក្ខីកម្មរបស់ពួកគាត់ គឺជាបញ្ហាស្ថិតនៅក្នុងការត្រួតពិនិត្យរបស់អង្គជំនុំជម្រះសាលាដំបូង។ ដូច្នេះ ជាកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបោះបង់ចោលនូវអំណាច និងការទទួលខុសត្រូវរបស់ខ្លួនដើម្បីកំណត់នូវកាលវិភាគឆាប់រហ័សសម្រាប់ការស្តាប់សាក្សីទាក់ទិននឹងមន្ទីរស-២១ និងក្នុងការសន្និដ្ឋានថា ផលប៉ះពាល់អំពីរយៈពេលនៃកិច្ចដំណើរការនីតិវិធី គឺ "មិនច្បាស់លាស់" ឬ មិនប្រាកដ[130]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់រយៈពេលសម្រាប់ស្តាប់សាក្សី ទាក់ទិននឹងទីកន្លែងឧក្រិដ្ឋកម្មទួលពោធិ៍ជ្រៃ ត្រឹមពីរថ្ងៃកន្លះ[131] ហើយមិនមានហេតុផលឡើយដែលអង្គជំនុំជម្រះមិនអាចកំណត់កាលវិភាគឆាប់រហ័ស និងច្បាស់លាស់សម្រាប់ស្តាប់សក្ខីកម្មសាក្សីទាក់ទិននឹងមន្ទីរស-២១នោះ។

---

128 ឯកសារ E273 កាលវិភាគសម្រាប់សវនាការស្នើឡើងដោយសហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៩-១០។ ឯកសារ E273.1 ឧបសម្ព័ន្ធក៖ កាលវិភាគសម្រាប់សវនាការស្នើឡើងដោយសហព្រះរាជអាជ្ញាសម្រាប់ដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២។

129 ឯកសារ E273 កាលវិភាគសម្រាប់សវនាការស្នើឡើងដោយសហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៩។

130 ឯកសារ E284 សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៣៩។

131 ឧបសម្ព័ន្ធ៖ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163)" ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ១០ E163/5 សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៨ ខែ តុលាឆ្នាំ ២០១២ កថាខណ្ឌ ៣។ E1/186.1 ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ - ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៣ E1/187.1

៩៥- អង្គជំនុំជម្រះសាលាដំបូង មិនអាចសន្និដ្ឋានដោយសមហេតុផលឡើយថា ចំនួនសាក្សីច្រើន នឹងជាការចាំបាច់ ដោយសារតែការដាក់បញ្ចូលមន្ទីរស-២១ ជាទីកន្លែងឧក្រិដ្ឋកម្មនោះ។ សេចក្តីសម្រេចដែលរងការជំទាស់ ទទួលស្គាល់ថា មាន "ភស្តុតាងជាច្រើននៅចំពោះមុខអង្គជំនុំជម្រះ ទាក់ទងនឹង ស-២១"[132]។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសន្និដ្ឋានកាលពីលើកមុនថា ចំនួនសាក្សីបន្ថែម ពីរ ឬបីនាក់ នឹងតម្រូវឱ្យមានចាំបាច់ (ប្រសិនបើមាន) ប្រសិនបើមន្ទីរស-២១ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២/០១៖ "អង្គជំនុំជម្រះសាលាដំបូងពិចារណាល្អិតល្អន់ ក្នុងការឯកភាពទៅលើចំណុចបន្ថែម ដែលបានស្នើសុំខាងលើនេះ ប៉ុន្តែយោងតាមសក្ខីកម្មរបស់ កាំង ហ្គេកអ៊ាវ នាពេលបច្ចុប្បន្ន (បន្ថែមពីលើភស្តុតាងទាំងអស់នៅតាមទីតាំងឧក្រិដ្ឋកម្ម ដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ទាក់ទិននឹងប្រធានបទទាំងនេះ និងដែលអាចទទួលយកបានបន្ទាប់ពីមានសេចក្តីសម្រេច E96/7) អង្គជំនុំជម្រះយល់ឃើញថា មិនមានភាពចាំបាច់ក្នុងការស្តាប់សក្ខីកម្មរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមទៀត ដើម្បីបញ្ជាក់អំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១ និងនៅជើងឯកឡើយ។ សាក្សីបន្ថែមទាំងអស់ដែលសហព្រះរាជអាជ្ញាបានស្នើសុំកោះហៅលើបញ្ហានេះ គឺជាអ្នកបំពេញមុខងារនៅមន្ទីរស-២១ ក្រោមបង្គាប់របស់ កាំង ហ្គេកអ៊ាវ និងទំនងជាមិនមានលទ្ធភាពបញ្ជាក់អំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ ក្នុងសំណុំរឿង ០០២/០១ បានឡើយ"[133]។

៩៦- សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ឌុច គឺជាសាក្សីសំខាន់តែម្នាក់គត់ ប្រសិនបើមន្ទីរស-២១ ត្រូវបានដាក់បញ្ចូលនោះ ផ្អែកដោយផ្នែកទៅលើសេចក្តីសម្រេចរបស់ខ្លួន ដែលអនុញ្ញាតឱ្យប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សី ដោយមិនចាំបាច់មានវត្តមានរបស់សាក្សីនៅសវនាការឡើយ ប្រសិនបើកំណត់ហេតុស្តាប់ចម្លើយទាំងនោះមិនពាក់ព័ន្ធនឹងអំពើ និងសកម្មភាពរបស់

---

ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ - ថ្ងៃទី ២ ខែ ឧសភាឆ្នាំ២០១៣ ។ E1/188.1 ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ - ថ្ងៃទី ៣ ខែ ឧសភាឆ្នាំ២០១៣ ។

132 ឯកសារ **E284** សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១១៧។

133 ឯកសារ **E218.1** ឧបសម្ព័ន្ធភ្ជាប់ទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163)" ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ១១។

ជនជាប់ចោទ[134]។ លទ្ធផលនៃការសម្រេចនោះគឺថា សវនាការអំពីមន្ទីរស-២១ ប្រឆាំងនឹងជនជាប់ចោទបច្ចុប្បន្ននេះ នឹងតម្រូវឲ្យមានសាក្សីរស់តិចជាងការជំនុំជម្រះលើរឿងក្តី០០១ ប្រឆាំងនឹង ឌុច ដែលនៅពេលនោះអតីតកម្មាភិបាលគុក និងអ្នកជាប់ឃុំឃាំងជាច្រើនបានផ្តល់សក្ខីកម្មដោយផ្ទាល់ ទាក់ទិននឹងអំពើ និងសកម្មភាពរបស់ ឌុច ។ ដោយសារតែសាក្សីដែលដឹងអំពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទ ទាក់ទិននឹងមន្ទីរស-២១ បានផ្តល់សក្ខីកម្មរួចហើយ នៅក្នុងសវនាការសំណុំរឿង ០០២/០១ សវនាការអំពីភ័ស្តុតាង ទាក់ទិននឹងទីកន្លែងឧក្រិដ្ឋកម្មនោះ អាចត្រូវបានបញ្ចប់ដោយមានសក្សីបន្ថែមតិចតួចប៉ុណ្ណោះ។ សេចក្តីសម្រេចដែលរងការជំទាស់ ខកខានមិនបានលើកឡើង ឬផ្តល់នូវសេចក្តីពន្យល់ណាមួយអំពីសេចក្តីសន្និដ្ឋានមុនៗរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មន្ទីរស-២១ អាចត្រូវបានដាក់បញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ដោយមិនចាំបាច់មានសាក្សីបន្ថែមច្រើនឡើយ។ ដូច្នេះប្រការនេះមិនសមហេតុផលយ៉ាងច្បាស់ក្រឡែត ដោយផ្អែកតែទៅលើមូលដ្ឋានតែមួយនោះ។

៩៧- មានការកត់សម្គាល់ផងដែរថា ក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការខែសីហា ឆ្នាំ២០១២ ភាគីទាំងអស់តម្រូវឲ្យជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងអំពីថាតើ ខ្លួនបានស្នើសុំសាក្សីបន្ថែម ដែរ ឬទេ ប្រសិនបើមន្ទីរស-២១ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ០០២/០១។ ក្នុងការឆ្លើយតប មេធាវីការពារក្តីរបស់ ខៀវ សំផន មេធាវីការពារក្តីរបស់ អៀង សារី និងដើមបណ្តឹងរដ្ឋប្បវេណី មិនបានស្នើសុំសាក្សី ទាក់ទិននឹងមន្ទីរស-២១ ឡើយ[135]។ មានតែមេធាវីការពារក្តីរបស់ នួន ជា ប៉ុណ្ណោះដែលបានស្នើសុំសាក្សី ទាក់ទិននឹងមន្ទីរស-២១ បន្ថែមទៅលើសាក្សីចំនួន ៥នាក់ ដែលសហព្រះរាជអាជ្ញាបានស្នើសុំ។ ដូចដែលបានកំណត់នៅក្នុងបណ្តឹងសាទុក្ខកាលពីមុនរបស់សហព្រះរាជអាជ្ញា ភាពចាំបាច់នៃសាក្សីទាំងនេះមិនត្រូវបានផ្តល់យុត្តិកម្មដោយមេធាវីការពារក្តី នួន ជា ឡើយ ហើយភ័ស្តុតាងរបស់សាក្សីដែលបានស្នើសុំទាំងនោះ មានភាពច្រំដែលជាច្រើន ឬមិនពាក់ព័ន្ធទៅនឹងបញ្ហាសំខាន់ៗនៅក្នុង

---

134 ឯកសារ E96/7 សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២១-២២។

135 ឯកសារ E236 បុគ្គលនានាដែលភាគីស្នើសុំមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ (ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម) កថាខណ្ឌ ៧។

ការចោទប្រកាន់ពាក់ព័ន្ធនឹងមន្ទីរស-២១ ប្រឆាំងនឹងជនជាប់ចោទទាំងនេះ[136]។ អង្គជំនុំជម្រះសាលាដំបូងអាចពិនិត្យឡើងវិញលើសាក្សីជាង ៥០០នាក់ ដែលបានស្នើឡើងដោយមេធាវីការពារក្តី នួន ជា[137] សម្រាប់ការជំនុំជម្រះលើសំណុំរឿង ០០២/០១ និងជ្រើសរើសសាក្សីចំនួន២០នាក់ ដែលសក្ខីកម្មរបស់ពួកគាត់មានសារៈសំខាន់ចាំបាច់សម្រាប់ "វចនាសម្ព័ន្ធដំណាក់កាលទី១ ឬបញ្ហាជម្លៀសដោយបង្ខំ[138]។ អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះត្រូវបានតម្រូវឲ្យធ្វើដូចគ្នាផងដែរ ទាក់ទិននឹងសាក្សីមន្ទីរស-២១ បន្ថែមចំនួន ២៧នាក់ ដែលបានស្នើសុំដោយមេធាវីការពារក្តី នួន ជា។

៥៨- អង្គជំនុំជម្រះសាលាដំបូងមានកំហុសបន្ថែមទៀត ក្នុងវិសាលភាពដែលអង្គជំនុំជម្រះបានផ្អែកទៅលើតម្រូវការក្នុងការបញ្ជាក់អំពីការទទួលយកឯកសារ ទាក់ទិននឹងមន្ទីរស-២១ ចំនួន ២០០ ទៅ ២៥០ ឯកសារបន្ថែមទៀត ជាមូលដ្ឋានដើម្បីបដិសេធមិនដាក់បញ្ចូលទីកន្លែងឧក្រិដ្ឋកម្មនោះ[139]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកចម្លើយសារភាព និងបញ្ជីឈ្មោះអ្នកទោសមន្ទីរស-២១ ចំនួនប្រហែល ៦០០នាក់ រួចហើយ បន្ទាប់ពីមេធាវីការពារក្តីត្រូវបានផ្តល់ឱកាសឲ្យធ្វើការជំទាស់ទៅនឹងឯកសារទាំងនោះ ហើយសវនាការត្រូវបានធ្វើឡើង ដែលក្នុងពេលសវនាការនោះ ភាគីបានទាញហេតុផលអំពីភាពអាចទទួលយកបាន និងភាពពាក់ព័ន្ធនៃឯកសារទាំងនោះ[140]។ ឯកសារបន្ថែមទាក់ទិន

---

[136] ឯកសារ E163/5/1/1 បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចស្តីពីវិសាលភាពនៃការ ជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៦១-៦៥។

[137] E9/4/4.4 ឧបសម្ព័ន្ធ កៈ បញ្ជីឈ្មោះសាក្សីដែលភាគីមានបំណងស្នើសុំឲ្យកោះហៅ - ក្រុមមេធាវីការពារលោក នួន ជា ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១១[ស្នើសាក្សីចំនួន៥២៧នាក់ដែលត្រូវកោះហៅដោយអង្គជំនុំជម្រះសាលាដំបូង] E9/4/4.2 ឧបសម្ព័ន្ធ ខៈ បញ្ជីឈ្មោះអ្នកជំនាញដែលភាគីមានបំណងស្នើសុំឲ្យកោះហៅ-- ក្រុមមេធាវីការពារលោក នួន ជា ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១១ [ស្នើសាក្សីជំនាញចំនួន១៣នាក់ដែលត្រូវកោះហៅដោយអង្គជំនុំជម្រះសាលាដំបូង]។

[138] E131/1.1 ឧបសម្ព័ន្ធ កសម្ងាត់៖ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២[ស្នើសាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៥នាក់ដែលត្រូវជ្រើសរើសដោយអង្គជំនុំជម្រះសាលាដំបូង ដែលក្នុងនោះ១៧នាក់ស្នើឡើងដោយមេធាវី នួន ជា]។ ការបញ្ជាក់ជាបឋមអំពីបុគ្គលដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងអំឡុង សវនាការលើចំណុចអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងសំណុំរឿង ០០២/០១, ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១២, កថាខណ្ឌ ១ [សាក្សីអាទិភាពដែលជ្រើសរើសដោយអង្គជំនុំជម្រះសាលាដំបូងដើម្បីផ្តល់សក្ខីកម្មទាក់ទងនិងការជម្លៀសដោយបង្ខំ ដែលក្នុងនោះ៣នាក់ស្នើដោយ នួន ជា]។

[139] ឯកសារ E284 សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៣៨, ១៤៤។

[140] ឯកសារ E185/1 សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា

នឹងមន្ទីរស-២១ ដែលនៅសេសសល់ គឺជាប្រភេទឯកសារដែលដូចគ្នាបេះបិទទៅនឹងឯកសារដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណា និងបានទទួលយករួចហើយ[141]។

៥៩- សេចក្ដីសម្រេចដែលរងការជំទាស់ក៏មានកំហុសផងដែរ ក្នុងការបញ្ជាក់ថា សហព្រះរាជអាជ្ញាបានស្នើសុំរយៈពេល០៤ថ្ងៃ សម្រាប់សវនាការលើឯកសារទាក់ទិននឹងមន្ទីរស-២១ បន្ថែមទៅលើរយៈពេល ១៥ថ្ងៃ សម្រាប់សវនាការស្ដាប់សក្ខីកម្មសាក្សី[142]។ រយៈពេល០៤ថ្ងៃ នៅក្នុងកាលវិភាគសម្រាប់សវនាការស្នើឡើងដោយសហព្រះរាជអាជ្ញា គឺសម្រាប់បញ្ហាទាក់ទិននឹងឯកសារដែលនៅសេសសល់ទាំងអស់ក្នុងសំណុំរឿង ០០២/០១ ដែលភាគច្រើនបំផុតនៃឯកសារទាំងនោះ មិនពាក់ព័ន្ធទៅនឹងមន្ទីរស-២១ ឡើយ ហើយពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងការជំទាស់របស់មេធាវីការពារក្ដីទៅនឹងឯកសារដែលមិនមានបកប្រែជាបីភាសារបស់ អ.វ.ត.ក[143]។ ការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងមិនយល់អំពីកាលវិភាគដែលស្នើឡើងដោយសហព្រះរាជអាជ្ញានោះ អាចដោយសារតែអង្គជំនុំជម្រះបានដាស់តឿនសហព្រះរាជអាជ្ញាចំពោះការដាក់ផែនការ និងបានបដិសេធមិនស្ដាប់ភាគី ស្ដីអំពីបញ្ហាកាលវិភាគដែលសំណើនោះបានលើកឡើង[144]។

---

និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២។ ឯកសារ **E185/1.3** ឧបសម្ព័ន្ធ គ é ឯកសារដែលបានស្នើឡើងដោយសហព្រះរាជ អាជ្ញា។

141 បញ្ជីឯកសារសម្រាប់សវនាការរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៨០(៣)(ឃ) ដែលរួមមានឯកសារបញ្ជីអ្នកទោស ស-២១ ចំនួន ៣៣៧ និងចម្លើយសារភាពរបស់មន្ទីរស-២១ចំនួន៤៦៤ ដែលមានប្រហែលជា៦០០ឯកសារដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងបានទទួលយកហើយ ។ **E109/4.9** ឧបសម្ពន្ធទី៩ បញ្ជីអ្នកទោស ស-២១ **E109/4.10** ចម្លើយសារភាពនៅមន្ទីរស-២១។

142 ឯកសារ **E284** សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៣៩។

143 ឯកសារ **E273** កាលវិភាគសម្រាប់សវនាការស្នើឡើងដោយសហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១១។

144 ឧបសម្ពន្ធ៣ អ៊ីម៉េលពីមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ ជូនគូភាគី, ១៨ មេសា ២០១៣ (បានបញ្ជាក់ថាការដាក់ឯកសាររបស់សហព្រះរាជអាជ្ញា "មិនទាន់ដល់ពេល និងមិនអាចចាត់ចែងបាន" និងបានបង្គាប់ទៅភាគីផ្សេងៗទៀតមិនឲ្យឆ្លើយតបឡើយ)។ E1/176.1ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ - ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០១៣ ទំព័រទី៧។

### ii. *ការសម្អាងទៅលើភ័ស្តុតាងផ្អែកវេជ្ជសាស្ត្រប៉ែបប៉ាន់ស្មាន*

៦០- អង្គជំនុំជម្រះសាលាដំបូងក៏មានកំហុសឆ្គងផងដែរ នៅពេលដែលអង្គជំនុំជម្រះសម្អាងទៅលើចម្លើយរបស់សាស្ត្រាចារ្យ John Campbell ថា "វានឹងមិនមានការភ្ញាក់ផ្អើលឡើយ ប្រសិនបើជនជាប់ចោទមិនអាចនៅរស់តទៅទៀតក្នុងរយៈពេល ០៦ ខែខាងមុខនោះ"[145] ដើម្បីគាំទ្រដល់ការសន្និដ្ឋានដែលថាការបន្ថែមទីរស-២១ នឹងធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពរបស់អង្គជំនុំជម្រះ ក្នុងការសម្រេចបានសាលក្រមមុនពេលជនជាប់ចោទស្លាប់ ឬអសមត្ថភាព។

៦១- សេចក្តីសម្រេចទៅលើបញ្ហាសំខាន់បែបនេះ ត្រូវតែសម្អាងទៅលើសម្អាងហេតុ និងអង្គហេតុ ជាជាងការប៉ាន់ស្មាន ឬការព្រួយបារម្ភថា ជនជាប់ចោទអាចនឹងស្លាប់ក្នុងរយៈពេល ០៦ ខែទៀត។ នៅពេលសហព្រះរាជអាជ្ញាសួរដេញដោលអំពីចម្លើយថា ០៦ ខែនោះ សាស្ត្រាចារ្យ Campbell បានព្រមានកុំយកតួលេខ ០៦ ខែ "ត្រង់ពេក" គាត់បានបញ្ជាក់ថា គាត់ "មិនយកបញ្ហារយៈពេល ០៦ ខែមកដាក់នៅក្នុងបញ្ហាបុរេវិនិច្ឆ័យនោះទេ" គាត់មិនអាចនិយាយថា "គាត់នឹងអាចរស់នៅបានរយៈពេលប៉ុន្មានឆ្នាំទៀតដែរ" ហើយគាត់នឹងមិនភ្ញាក់ផ្អើលទេ ប្រសិនបើ នួន ជា អាចរស់នៅបាន ០៦ ខែទៀតនោះ[146]។ ការទទួលស្គាល់របស់សាស្ត្រាចារ្យ Campbell បានបង្ហាញច្បាស់ហើយថា រយៈពេល ០៦ ខែ ដែលគាត់លើកយកមកនិយាយពីមុនមិនមានន័យទេ គ្រាន់តែជាការប៉ាន់ស្មាន និងតាមការយល់ឃើញផ្ទាល់ខ្លួនប៉ុណ្ណោះ ហើយថាមិនមានមូលដ្ឋានបែបសត្យានុម័តណាមួយ ដើម្បីសន្និដ្ឋានថាអាយុកាលជាមធ្យមរបស់ នួន ជា មានត្រឹមតែ ០៦ ខែទៀតនោះទេ។ នៅក្នុងកាលៈទេសៈទាំងនេះ ជាកំហុសឆ្គងរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្អាងទៅលើចម្លើយដែលអ្នកជំនាញមិនចង់ការពារ ឬគាំទ្រ និងបានបោះបង់ចោលវិញពេលគេសួរដេញដោលនោះទេ។

៦២- អង្គហេតុបែបសត្យានុម័ត ដូចដែលបានសន្និដ្ឋាននៅក្នុងរបាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញនានាដែលបានពិនិត្យ នួន ជា (រួមទាំងសាស្ត្រាចារ្យ Campbell) គឺថា ជំងឺតៀ្បតសរសៃឈាមបេះដូងមាន

[145] សេចក្តីសម្រេចដែលត្រូវបានជំទាស់ ឯកសារ E284 កថាខណ្ឌ ១២៨។

[146] ប្រតិចារឹក ឯកសារ E1/175.1 ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ៧៥ ដល់ ៧៦ និងទំព័រ ៧៩ ដល់ ៨០ (ភាសាអង់គ្លេស)។

សភាពនឹងនរ ចាប់តាំងពីគាត់ត្រូវបានឃុំខ្លួននៅ អ.វ.ត.ក ពីឆ្នាំ២០០៧ មក[147] ហើយថា មិនមានជំងឺដែលគំរាមកំហែងដល់ជីវិតភ្លាមៗ ឬស្ថានភាពសុខភាពដែលបុរេវិនិច្ឆ័យរយៈពេល ០៦ ខែ អាចយកមកធ្វើជាសម្អាងបានឡើយ[148]។ របាយការណ៍ជាលាយលក្ខណ៍អក្សរដែលសាស្ត្រាចារ្យ Campbell បានរៀបចំប៉ុន្មានថ្ងៃមុនពេលផ្តល់សក្ខីកម្ម[149] ពុំមានបុរេវិនិច្ឆ័យទាល់តែសោះ កុំថាឡើយដល់ទៅបញ្ជាក់ថា នួន ជា អាចរស់បានត្រឹមតែ ០៦ ខែទៀតនោះ។

៦៣- បុរេវិនិច្ឆ័យជាលាយលក្ខណ៍ត្រូវបានផ្តល់ដោយវេជ្ជបណ្ឌិត Antoine Lafont នាយកផ្នែកបច្ចេកទេសអន្តរាគមន៍ខាងបេះដូង នៅមន្ទីរពេទ្យ Georges Pompidou ក្នុងទីក្រុងប៉ារីស៍ ដែលបានពិនិត្យ នួន ជា រៀងរាល់ ០៦ ខែម្តង ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១០។ បុរេវិនិច្ឆ័យរបស់វេជ្ជបណ្ឌិត Lafont កាលពីខែ តុលា ឆ្នាំ២០០៧ បានលើកឡើងថា៖ "វាជាការលំបាកក្នុងការព្យាករណ៍ពីអនាគត ប៉ុន្តែតាមរយៈពន្លឺដែលចេញពីរបាយការណ៍លម្អិតនេះ អ្នកជំងឺបច្ចុប្បន្នមានស្ថានភាពជំងឺថេរនៅដដែលមិនដុនដាប។ ជំងឺលើសឈាមត្រូវបានព្យាបាល ជំងឺសរសៃឈាមមានលក្ខណៈថេរនៅដដែរមិនដុនដាបគួរឲ្យកត់សម្គាល់តាំងពី១២ឆ្នាំ ... ហើយសំណល់រោគបណ្តាលមកពីគ្រោះថ្នាក់ដាច់សរសៃឈាម គឺយូរយារណាស់ហើយ"[150]។ បុរេវិនិច្ឆ័យរបស់គាត់នៅខែមិថុនា ឆ្នាំ២០០៩ បានសរសេរថា៖ "ដូចបានពន្យល់

---

[147] របាយការណ៍អ្នកជំនាញថែទាំសុខភាពមនុស្សចាស់លើ នួន ជា ឯកសារ E62/3/4 ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ១២ ("ត្រូវបានតាមដានព្យាបាលយ៉ាងល្អប្រសើរ និងជំងឺឿតសរសៃឈាមបេះដូងដែលមានភាពនឹងនរ ហើយពេលបច្ចុប្បន្ន មិនមានរោគសញ្ញាអ្វីទេ"); ការពិនិត្យតាមដានបន្តលើរបាយការណ៍ទាក់ទងនឹង លោក នួន ជា ឯកសារ E62/3/13 ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១១ កថាខណ្ឌ ៧ ដល់ ៩; របាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញទាក់ទងនឹងលោក នួន ជា, ឯកសារ E256/4 ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៩ ("ជំងឺបេះដូង និងសរសៃឈាមរបស់គាត់មានភាពនឹងនរ។ É ពុំមានការប្រែប្រួលច្បាស់លាស់ណាមួយចំពោះស្ថានភាពបេះដូង និងសរសៃឈាមរបស់ នួន ជា ចាប់តាំងពីសាស្ត្រាចារ្យ Campbell បានពិនិត្យ នួន ជា ចុងក្រោយ នៅឆ្នាំ ២០១១"); សេចក្តីសម្រេចដែលត្រូវបានជំទាស់ ឯកសារ E284 កថាខណ្ឌ ១២៧; ប្រតិចារឹក ឯកសារ E1/175.1 ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ៦៥ (ភាសាអង់គ្លេស) ("សម្ពាធឈាមនេះអាចចាត់ទុកថាល្អសម្រាប់មនុស្សដែលមានអាយុដូចនេះ") និងទំព័រ ៧០ ដល់ ៧៣ (ភាសាអង់គ្លេស)។

[148] ប្រតិចារឹក ឯកសារ E1/175.1 ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ៦៦ (ភាសាអង់គ្លេស) ("ពុំមានសញ្ញាបង្ហាញពីការវិវត្តលើបញ្ហាបេះដូង សួត ឬជំងឺបេះដូង និងសរសៃឈាមដែលជាដើមចមនៃបញ្ហាផ្សេងទៀតឡើយ" ហើយមុខងារតម្រងនោម "មានលក្ខណៈនឹងនរល្អ"); របាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញទាក់ទងនឹងលោក នួន ជា ឯកសារ E256/4 ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៨ ដល់ ១៥។

[149] របាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញទាក់ទងនឹងលោក នួន ជា ឯកសារ E256/4 ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣។

[150] របាយការណ៍ស្តីពីកោសលវិច័យពេទ្យរបស់លោក នួន ជា ឯកសារ D24/VII ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៧ ផ្នែកទី ៣។

យ៉ាងច្បាស់រួចមកហើយ វាជាការលំបាកក្នុងការព្យាករណ៍ពីអនាគត តែពាក់ព័ន្ធនឹងការពិនិត្យសុខភាពដែលបានធ្វើឡើងកាលពី១៨ខែមុនឃើញថា វិបល្លាសរបស់អ្នកជំងឺមិនត្រឹមតែមានភាពប្រក្រតីប៉ុណ្ណោះទេ តែការពិនិត្យសុខភាពចុងក្រោយបង្ហាញពីការរីកចំរើនចំពោះស្ថានភាពសុខភាពទូទៅរបស់គាត់"[151]។ វេជ្ជបណ្ឌិត Lafont ក៏បានធ្វើការសន្និដ្ឋានស្រដៀងគ្នាអំពីស្ថិរភាពនៃស្ថានភាពរបស់ នួន ជា នៅក្នុងរបាយការណ៍របស់ខ្លួននាខែធ្នូ ឆ្នាំ២០០៩ និងខែកក្កដា ឆ្នាំ២០១០[152]។

៦៤- អង្គជំនុំជម្រះសាលាដំបូងមានកំហុសបន្ថែមទៀតក្នុងការចេញសេចក្តីសម្រេចបែបនេះ ដោយបដិសេធមិនដេញដោលទៅលើទិន្នន័យបែបសត្បានុម័ត និងវិទ្យាសាស្ត្រ ស្តីពីអាយុកាលជាមធ្យមដែលសហព្រះរាជអាជ្ញាបានស្នើសុំ ក្នុងអំឡុងពេលដែលសាស្ត្រាចារ្យ Campbell បានផ្តល់សក្ខីកម្ម[153]។ (ឯកសារចម្លង ២ ច្បាប់ដែលសហព្រះរាជអាជ្ញាបានដាក់ជូនភ្ជាប់មកជាមួយនូវ ឧបសម្ព័ន្ធ ៤ និង ៥)។ ផ្ទុយពីចម្លើយបែបប៉ាន់ស្មានរបស់សាស្ត្រាចារ្យ Campbell ដែលអង្គជំនុំជម្រះសាលាដំបូងបានដកស្រង់ និងយកមកសម្អាងនោះ ភាគរយជាក់ស្តែងដែលថាមនុស្សប្រុសចំណាស់អាយុ ៨៦ ឆ្នាំ នឹងស្លាប់ក្នុងរយៈពេល ១ ឆ្នាំទៀត មានកម្រិតទាបណាស់ (ត្រឹមតែពី ១២% ទៅ ១៦% ប៉ុណ្ណោះ) និងអាយុកាលជាមធ្យមរបស់មនុស្សប្រុសក្នុងវ័យនេះ គឺពី ៣ ទៅ ៥ ឆ្នាំ[154]។

---

151 របាយការណ៍វេជ្ជសាស្ត្ររបស់វេជ្ជបណ្ឌិត Antoine Lafont ឯកសារ B27/I ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ២ ដល់ ៣។

152 របាយការណ៍ត្រួតពិនិត្យវេជ្ជសាស្ត្ររបស់លោក នួន ជា ឯកសារ B41/I ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩; របាយការណ៍វេជ្ជសាស្ត្ររបស់ នួន ជា ឯកសារ B48/I ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១០។

153 ប្រតិចារឹក ឯកសារ E1/175.1 ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ៧៧ ដល់ ៧៩ (ភាសាអង់គ្លេស)។

154 **ឧបសម្ព័ន្ធ៤** តារាងបង្ហាញពីជីវិតរស់នៅរបស់ប្រជាជន នូវ៉ែលសេឡង់៖ ឆ្នាំ ២០០៥ ដល់ ២០០៧ ទំព័រ ៧១ [អាយុកាលជាមធ្យមរបស់មនុស្សប្រុសជនជាតិ Maori អាយុ ៨៦ ឆ្នាំ គឺ ៤,២៦ ឆ្នាំ និងលទ្ធភាពស្លាប់ក្នុងរយៈពេលមួយឆ្នាំ គឺ ១៦,៣%]; **ឧបសម្ព័ន្ធ ៥** របាយការណ៍ស្ថិតិជាតិសំខាន់ៗ ៖ តារាងបង្ហាញពីជីវិតរស់នៅរបស់ប្រជាជនអាមេរិក ឆ្នាំ ២០០៨ ៖ ទំព័រ ២៥ [អាយុកាលជាមធ្យមរបស់មនុស្សប្រុសជាតិអាមេរិកអាហ្វ្រិចអាយុ ៨៦ ឆ្នាំ គឺ ៥,៥ ឆ្នាំ ហើយលទ្ធភាពស្លាប់ក្នុងរយៈពេលមួយឆ្នាំ គឺ ១២,៣%], ទំព័រ ១៣ [អាយុកាលជាមធ្យមរបស់មនុស្សប្រុសជនជាតិអាមេរិក ៨៦ ឆ្នាំ គឺ ៥,៣ ឆ្នាំ ហើយលទ្ធភាពស្លាប់ក្នុងរយៈពេលមួយឆ្នាំ គឺ ១១,៥%]។ តួលេខមុនៗបានដកស្រង់ចេញពីទិន្នន័យប្រជាពលរដ្ឋដែលអាយុកាលជាមធ្យមពីកំណើតមានចាប់ពី ៧០ ទៅ ៧៥ ឆ្នាំ។ ទិន្នន័យដែលយកមកប្រើនេះបានមកពីទិន្នន័យដើមទសវត្សរ៍ឆ្នាំ ១៩៥០ ក្នុងប្រទេសនូវ៉ែលហ្សេឡង់ នៅពេលអាយុកាលជាមធ្យមចាប់ពីពេលកើតរបស់មនុស្សប្រុសជនជាតិ Maori គឺមានតែ ៥៤ ឆ្នាំប៉ុណ្ណោះ អាយុកាលជាមធ្យមនៃជនជាតិ Maori អាយុ ៨៥ ឆ្នាំ គឺនៅតែ ៣,៤ ឆ្នាំដដែល។ **ឧបសម្ព័ន្ធ៤**, តារាងបង្ហាញពីជីវិតរស់នៅ ៖ ឆ្នាំ ២០០៥ ដល់ឆ្នាំ ២០០៧ ទំព័រ ១៤។

៦៥- ការពិត ទិន្នន័យស្ដីពីអាយុកាលជាមធ្យមមិនមែនជាការធានាពីរយៈពេល ដែលមនុស្សម្នាក់អាចរស់នៅបាននោះទេ។ តែចំពោះការវាយតម្លៃពីកម្រិតហានិភ័យដែលកើតឡើងដោយសារការអូសបន្លាយសវនាការពី ១ ខែ ទៅ ២ ខែនោះ ភ័ស្តុតាងបែបសត្យានុម័តបានបង្ហាញច្បាស់ថា ការអូសបន្លាយសវនាការរយៈពេលខ្លី នឹងមិនបង្កើនហានិភ័យនៃការស្លាប់របស់ជនជាប់ចោទមុនពេលប្រកាសសាលក្រមនោះទេ។ ផ្ទុយទៅវិញ ទោះបីឱកាសរស់នៅមួយឆ្នាំទៀតនោះ មានកម្រិតខ្ពស់នោះក៏ដោយ តែភាពប្រហែលដែលថា មនុស្សអាយុ ៨៦ ឆ្នាំ អាចនឹងរស់នៅរហូតដល់សវនាការលើកទីពីរដ៏វែងដែលមិនអាចចាប់ផ្តើមរហូតដល់ឆ្នាំ២០១៥[155] មានកម្រិតទាបណាស់។

៦៦- សហព្រះរាជអាជ្ញាសូមលើកឡើងផងដែរថា ការប្រៀបធៀបមួយចំនួនដែលបានលើកឡើង នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ជាការខុសឆ្គង។ ឧទាហរណ៍ យោបល់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា ស្ថានភាពបច្ចុប្បន្នគឺអាចប្រៀបធៀបបានជាមួយ *រឿងក្តី Milošević* ជាការមិនត្រឹមត្រូវទាល់តែសោះ[156] ដោយសារនៅទីនេះ សហព្រះរាជអាជ្ញាគ្រាន់តែស្នើសុំអូសបន្លាយសវនាការត្រឹមមួយខែ (មិនមែន ២ ឆ្នាំទេ) ហើយរឿងក្តីនេះពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែមួយប៉ុណ្ណោះ (ផ្ទុយពីដីកាបញ្ជូនរឿងទៅជំនុំជម្រះចំនួន ៣ ដាច់ពីគ្នា ប្រឆាំងនឹង *Milošević* ដែលរដ្ឋអាជ្ញាបានស្នើឲ្យជំនុំជម្រះជាមួយគ្នា)។ ការណ៍ដែលសេចក្តីសម្រេចដែលរងការជំទាស់ យោងទៅលើការស្លាប់របស់ អៀង សារី ក៏មិនត្រឹមត្រូវដែរ[157]។ អៀង សារី ស្លាប់ដោយសារ "ជំងឺស្ទះសរសៃឈាមបេះដូងដែលមិនអាចធ្វើឲ្យប្រសើរឡើងវិញ បណ្តាលមកពីការស្ទៀតសរសៃចិញ្ចឹមបេះដូងដែលមានជាយូរមកហើយ"[158] ជាស្ថានភាពបេះដូងដែលវិវត្តន៍កាន់តែអាក្រក់ទៅៗ តាំងពីការជាប់ឃុំឃាំងនៅអ.វ.ត.ក[159]។ ផ្ទុយទៅវិញ ដូចបានលើកឡើងពិស្តារខាងលើរួចមកហើយ ស្ថានភាពបេះដូងរបស់ នួន ជា នៅស្ថិតស្ថេរតាំងពីឆ្នាំ២០០៧ មកម្ល៉េះ ហើយមិនមានសញ្ញាណថា គាត់នឹងគាំងបេះដូងទេ[160]។

---

155 សេចក្តីសម្រេចដែលត្រូវបានជំទាស់ E284 ទំព័រ ៧១ (ជើងទំព័រ ២៧០)។

156 សេចក្តីសម្រេចដែលត្រូវបានជំទាស់ E284 កថាខណ្ឌ ១៣៦។

157 សេចក្តីសម្រេចដែលត្រូវបានជំទាស់ E284 កថាខណ្ឌ ១២៩។

158 សេចក្តីសម្រេចដែលត្រូវបានជំទាស់ E284 កថាខណ្ឌ ២២៥។

159 កំណត់ត្រាវេជ្ជសាស្ត្របង្ហាញថា ការដង្ហក់របស់ អៀង សារី កាន់តែមានសភាពធ្ងន់ធ្ងរឡើងពីពេលមួយទៅពេលមួយផ្អែកលើបទដ្ឋានរបស់សមាគមបេះដូងទីក្រុងញូវយ៉ក (NYHA) ពីបញ្ហាបេះដូងដំណាក់កាល II (ស្រាល) នៅឆ្នាំ ២០០៧ ទៅដំណាក់កាលទី III (មធ្យម) នៅឆ្នាំ ២០១១ ឬឆ្នាំ ២០១២ ទៅដំណាក់កាលទី IV (ធ្ងន់ធ្ងរ) នៅឆ្នាំ ២០១៣ ៖ របាយការណ៍វេជ្ជសាស្ត្រពីមន្ទីរពេទ្យកាល់ម៉ែត្រ ឯកសារ A100/I ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧, ទំព័រ ១ (ដំណាក់កាល

### *iii. អង្គជំនុំជម្រះសាលាដំបូងមិនអាចពន្លឿនកិច្ចដំណើរការនីតិវិធីបាន*

៦៧- ជាកំហុស និងជាការបំពានឆន្ទានុសិទ្ធិដែរ ដែលដកមន្ទីរស-២១ ចេញ ដោយសម្អាងទៅលើពេលវេលា ឬ ការពន្យារពេលដែលពាក់ព័ន្ធនឹងការជំនុំជម្រះទៅលើទីតាំងឧក្រិដ្ឋកម្មនោះ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងមិនបានប្រើប្រាស់ថ្ងៃសម្រាប់សវនាការដែលមានស្រាប់ ដូចដែលអង្គជំនុំជម្រះនេះបានណែនាំ[161]។ អង្គជំនុំជម្រះសាលាដំបូងកម្របើកសវនាការនៅថ្ងៃសុក្រណាស់ ទោះបីការបើកសវនាការនៅថ្ងៃនោះ ត្រូវធ្វើឡើងដើម្បីប៉ះប៉ូវដល់ថ្ងៃឈប់សម្រាក ការសម្រាកមិនធ្វើសវនាការ ឬការពន្យារពេលក៏ដោយ។ អង្គជំនុំជម្រះបានលុបចោលសក្ខីកម្មរបស់សាក្សីមួយចំនួន បន្ទាប់ពីមានសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី[162] និងមិនបានបន្តកិច្ចដំណើរការនីតិវិធីជំនុំជម្រះទេ រហូតដល់អស់រយៈពេល ១០ ថ្ងៃ បន្ទាប់ពីការប្រកាសផ្ទាល់មាត់នូវសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួនដែលត្រូវបានកែសម្រួលជាថ្មី ទោះបីការធ្វើកូដកម្មរបស់មន្ត្រីបកប្រែភាសាត្រូវបានដោះស្រាយ ហើយជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ និងអាចចូល

---

ទី II នៃការដង្ហក់ផ្អែកលើ NYHA); របាយការណ៍វេជ្ជសាស្ត្រពីមន្ទីរពេទ្យកាល់ម៉ែត្រ ឯកសារ A134/I ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៨ (ដំណាក់កាលទី II នៃការដង្ហក់ផ្អែកលើ NYHA); របាយការណ៍វេជ្ជសាស្ត្រពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ឯកសារ E11/68.1, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ (កត់សម្គាល់ឃើញថា ការដង្ហក់របស់ អៀង សារី កាន់តែធ្ងន់ធ្ងរឡើងពីដំណាក់កាល II ផ្អែកលើនៅឆ្នាំ ២០០៩ ដល់ដំណាក់កាល III ផ្អែកលើ NYHA នៅឆ្នាំ ២០០៩); របាយការណ៍វេជ្ជសាស្ត្រពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ឯកសារ E11/117/I, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៣ (ការដង្ហក់របស់អៀង សារី មានការវិវត្តពីតំណាក់កាលទី III ផ្អែកលើ NYHA នៅឆ្នាំ ២០១១ ទៅដំណាក់កាលទី IV ផ្អែកលើ NYHA)។

160 *សូមមើល ឧទាហរណ៍* របាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញទាក់ទងនឹងលោក ឯកសារ E256/4 ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣, កថាខណ្ឌ ៩; របាយការណ៍វេជ្ជសាស្ត្រពីវេជ្ជបណ្ឌិត Lafont ឯកសារ B48/I ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១០ ទំព័រ ១ ("ពុំមានដង្ហក់")។

161 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ឯកសារ E163/5/1/13 កថាខណ្ឌ ៥១ ("ជាការតម្រូវថា អ.វ.ត.ក ដំណើរការជារៀងរាល់ថ្ងៃដែលខ្លួនអាចធ្វើទៅបាន ដើម្បីធានាបាននូវការសម្រេចជាស្ថាពរលើបទចោទដែលសេសសល់ឱ្យបានឆាប់ដែលអាចធ្វើទៅបាន")។

162 E264/1 ការកំណត់កាលបរិច្ឆេទរបស់អ្នកជំនាញ Philip Short និង Elizabeth Becker និងការពន្យារពេលស្តាប់សក្ខីកម្មសាក្សីពាក់ព័ន្ធនឹងអង្គហេតុ រហូតដល់មានសេចក្តីសម្រេចថ្មីអំពីការបំបែកកិច្ចដំណើរការនិតិវិធីសវនាការ, ថ្ងៃទី ២៦ កុម្ភៈ ២០១៣, កថាខណ្ឌ ៣ និង ៥។

វួមវិញបានក៏ដោយ[163]។ សវនាការចំនួន ១១ ថ្ងៃដែលសហព្រះរាជអាជ្ញាបានស្នើឡើង ដើម្បីស្តាប់សក្ខីកម្មសាក្សីសំខាន់ ៥ រូបពីមន្ទីរស-២១ អាចនឹងកំណត់កាលបរិច្ឆេទបាននៅក្នុងពេលវេលាដែលមានស្រាប់សម្រាប់សំណុំរឿង ០០២/០១ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពិតជាបានខិតខំប្រឹងប្រែងដើម្បីបង្កើនចំនួនថ្ងៃស្តាប់សក្ខីកម្មសាក្សីមែននោះ[164]។

៦៨- ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការកំណត់កាលបរិច្ឆេទចំនួន១៥ថ្ងៃ សម្រាប់ស្តាប់សក្ខីកម្មរបស់សាក្សី នឹងតម្រូវឱ្យចំណាយរយៈពេលជាមធ្យមគឺ ២,៥ ខែ (*ពោលគឺ* ៧៥ ថ្ងៃប្រក្រតិទិន)[165] ឬ "ចន្លោះពី ២ ទៅ ៤ ខែ"[166] គឺជាកំហុសឆ្គងច្បាស់ណាស់។ ប្រសិនបើវាសុក្រឹត្យនោះ (តែមិនសុក្រឹត្យទេ) ជាការទទួលស្គាល់ដោយភ្ញាក់ផ្អើលពីភាពមិនមានប្រសិទ្ធភាពរបស់អង្គជំនុំជម្រះ។ តាមសភាពជាក់ស្តែង មិនមានមូលហេតុដែលជឿថា ចំនួន១៥ ថ្ងៃនៃការផ្តល់សក្ខីកម្មនោះ នឹងត្រូវការរយៈពេលលើសពី ១ ខែ ដើម្បីបញ្ចប់ទេ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពិតជាដំណើរការការងារយ៉ាងឆាប់រហ័សមែននោះ។ ប្រសិនបើសំណូមពរដែលបានស្នើសុំក្នុងបណ្តឹងសាទុក្ខនេះ ត្រូវបានទទួលយកនោះ ការស្តាប់សក្ខីកម្មរបស់សាក្សីទាក់ទងនឹងមន្ទីរស-២១ នឹងធ្វើឡើងនៅខែ សីហា ឬខែកញ្ញា ឆ្នាំ២០១៣។ នៅខែសីហា ឆ្នាំ២០១៣ តុលាការមានថ្ងៃធ្វើការចំនួន ២២ ថ្ងៃ។ ក្នុងខែកញ្ញា ឆ្នាំ២០១៣ តុលាការមាន២០ថ្ងៃ។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវការប្រើប្រាស់តែថ្ងៃធ្វើការរបស់តុលាការចំនួន ៧៥% ប៉ុណ្ណោះ ដើម្បីបញ្ចប់សក្ខីកម្មចំនួន ១៥ ថ្ងៃ ក្នុងខែណាមួយ ក្នុងចំណោមខែទាំងពីរនេះ។

៦៩- សុខភាពរបស់ នួន ជា និង ខៀវ សំផន ទំនងជាមិនបណ្តាលឱ្យមានការពន្យារណ៍ពេលស្តាប់សក្ខីកម្មសាក្សីទាំងនេះទេ។ មកទល់នឹងពេលបច្ចុប្បន្ននេះ ការពន្យារណ៍ពេលសវនាការភាគច្រើនដែលកើត

---

163 ប្រតិចារឹក ឯកសារ E1/176.1, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ៦ ដល់ ៨ (ភាសាអង់គ្លេស)។

164 សហព្រះរាជអាជ្ញាបានស្នើឱ្យមានការកែសម្រួលជាច្រើនដងចំពោះកម្មវិធីធ្វើសវនាការដែលត្រូវបានធ្វើឡើងដើម្បីសន្សំ ឬបង្កើនចំនួនថ្ងៃដែលអាចធ្វើសវនាការបាន ប៉ុន្តែសំណើទាំងនេះមិនត្រូវបានអង្គជំនុំជម្រះសាលាដំបូងអនុវត្តតាមឡើយ។ កម្មវិធីអង្គជំនុំជម្រះដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ឯកសារ E273, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ២ (ជើងទំព័រ ៣) កថាខណ្ឌ ៣, ១១។

165 សេចក្តីសម្រេចដែលត្រូវបានជំទាស់ ឯកសារ E284 កថាខណ្ឌ ១៤០ (ជើងទំព័រ ២៣៩)។

166 សេចក្តីសម្រេចដែលត្រូវបានជំទាស់ ឯកសារ E284 កថាខណ្ឌ ១៤១។

ឡើងដោយសារសុខភាពរបស់ជនជាប់ចោទ គឺដោយសារ អៀង សារី តែម្តង[167]។ ចន្លោះពីខែវិច្ឆិកា ឆ្នាំ២០១១ ដល់ ខែឧសភា ឆ្នាំ២០១៣ នួន ជា និង ខៀវ សំផន ម្នាក់ៗ ធ្វើឱ្យសវនាការត្រូវពន្យារពេលតែម្តងគត់ដោយសារសុខភាពរបស់ពួកគេ[168]។ ចាប់តាំងពីពេលដែលសវនាការលើសំណុំរឿង ០០២/០១ បានបន្តដំណើរការវិញនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ មក (បន្ទាប់ពីមានការពន្យារណ៍ពេលយ៉ាងយូរដោយសារមានកត្តានានាជាច្រើនដូចជា ជំងឺ និងមរណភាពរបស់ អៀង សារី កូដកម្មពីសំណាក់មន្ត្រីបកប្រែភាសានៅ អ.វ.ត.ក និងការលុបចោលកិច្ចដំណើរការនីតិវិធីដោយអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីមានសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី) មិនមានថ្ងៃណាមួយត្រូវបានខាតបង់ដោយសារសុខភាពរបស់ជនជាប់ចោទណាម្នាក់ទេ ហើយ តុលាការបានដំណើរការស្តាប់សក្ខីកម្មរបស់សាក្សីចំនួន ១៦ ថ្ងៃមកហើយ។ ហេតុនេះ ពុំមានហេតុផលណាមួយដែលរំពឹង ឬសន្មតថា អង្គជំនុំជម្រះសាលាដំបូងមិនអាចដំណើរការឱ្យបានឆាប់រហ័ស ក្នុងការស្តាប់សក្ខីកម្មរបស់សាក្សីពីមន្ទីរស-២១ និងមិនអាចបញ្ចប់សក្ខីកម្មទាំងនោះក្នុងរយៈពេល ៤ សប្តាហ៍នោះទេ។

៧០- ទម្លាប់នៃការអនុវត្តដែលជាឧបសគ្គដ៏ចំបង នៅក្នុងការបញ្ចប់សវនាការដែលមានរយៈពេល១៥ ថ្ងៃសម្រាប់ខែនិមួយៗ គឺការកំណត់ពេលជំនុំជម្រះរយៈពេល៤ថ្ងៃ (ដែលបានកាត់បន្ថយមកត្រឹមបីថ្ងៃក្នុងមួយសប្តាហ៍ក្នុងមួយពេល) និងជាពិសេស ចំនួនពេលវេលាដ៏ច្រើននៃការឈប់សម្រាករបស់តុលាការក្នុងរយៈពេលយូរដែលបានកំណត់ពេលដោយអង្គជំនុំជម្រះសាលាដំបូង។ ជាឧទាហរណ៍មួយអំពីចំណុចនេះ សេចក្តីសម្រេចដែលរងការជំទាស់ថ្លែងថា "ការកំណត់ពេល១៥ថ្ងៃ នៃការផ្តល់សក្ខីកម្មរបស់សាក្សី នឹងត្រូវការរហូតដល់ពេញមួយឆ្នាំ២០១១ និងឆ្លងចូលដល់ខែកុម្ភៈ ឆ្នាំ២០១២

---

[167] សុខភាពរបស់អៀង សារី គឺជាមូលហេតុនាំឱ្យមានការអាក់ខានដល់កម្មវិធីជំនុំជម្រះក្នុងអំឡុងសប្តាហ៍ពីថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២ (ប្រតិចារឹក ឯកសារ E1/74.1 ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២) និងរយៈពេលពីថ្ងៃទី ១២ ដល់ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១២ (មើលប្រតិចារឹក ឯកសារ E1/125.1 ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២) និងគឺជាបុព្វហេតុមួយនៃបុព្វហេតុនានាដែលនាំដល់ការលុបចោលនៃការធ្វើសវនាការក្នុងរយៈពេលពីរសប្តាហ៍ដំបូងក្នុងខែ មេសា ឆ្នាំ ២០១៣ (ប្រតិចារឹក ឯកសារ E1/174.1 ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣)។

[168] សេចក្តីសម្រេចដែលត្រូវបានជំទាស់ ឯកសារ E284 កថាខណ្ឌ ១៣១ [កត់សម្គាល់ថា នួន ជា ត្រូវបានបញ្ជូនទៅសម្រាកនៅមន្ទីរពេទ្យក្នុងរយៈពេលភាគច្រើនបំផុតពីថ្ងៃទី ១៣ ខែ មករា ដល់ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដើម្បីព្យាបាលជំងឺរលាកបំពង់ក និងថា ខៀវ សំផន ក៏ត្រូវបានបញ្ជូនទៅសម្រាកនៅមន្ទីរពេទ្យក្នុងអំឡុងពេលដូចគ្នានេះ ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៣]។

(ប្រហែលបីខែ)"[169] ប៉ុន្តែខកខានមិនបានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូង (ក)បានប្រើការឈប់សម្រាករបស់តុលាការរយៈពេលវែងចំនួនពីរលើក នៅក្នុងអំឡុងពេលនេះទេ - មួយគឺចាប់ពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១ ដល់ថ្ងៃទី៩ ខែមករា ឆ្នាំ២០១២ និងមួយទៀតចាប់ពីថ្ងៃទី១៧ ខែកុម្ភៈ ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១២[170] ហើយនិង (ខ) ការជ្រើសយកការប្រើប្រាស់ថ្ងៃសវនាការយ៉ាងហោចណាស់៩ថ្ងៃ នៃថ្ងៃសម្រាប់សវនាការលើឯកសារទាំងអស់ដែលមានចំនួន២៨ថ្ងៃ និងការចំណាយពេលកន្លះថ្ងៃសម្រាប់ការអានការចោទប្រកាន់ក្នុងដីកាដំណោះស្រាយ[171]។ ដើម្បីផ្តល់នូវរូបភាពពេញលេញអំពីថ្ងៃដំណើរការនិតិវិធីសវនាការដល់អង្គជំនុំជម្រះ សហព្រះរាជអាជ្ញាសូមដាក់ជូននូវឧបសម្ព័ន្ធ... តារាងរូបភាពដែលបង្ហាញអំពីចំនួនថ្ងៃសវនាការដែលបានធ្វើក្នុងខែនីមួយៗ (ការផ្តល់សក្ខីកម្មរបស់សាក្សី, ការដាក់បញ្ចូលឯកសារផ្សេងៗ ឬដំណើរការនិតិវិធីសវនាការលើអង្គសេចក្តី) និងមូលហេតុដែលតិចជាង១៥ថ្ងៃដែលបានបំពេញ(ឧទាហរណ៍ កាលវិភាគសម្រាប់វិស្សមកាលរបស់តុលាការ ជម្ងឺរបស់ជនជាប់ចោទ)។

៧១- ទោះបីជាផ្អែកលើ "រយៈពេល ៧.៣ ថ្ងៃ ជាមធ្យមក្នុងមួយខែសម្រាប់ថ្ងៃសវនាការ" ទោះបីជាការយល់ច្រឡំដែលបានលើកយោងក្នុងសេចក្តីសម្រេចដែលរងការជំទាស់[172] ដែលស្មើនឹងចំនួនមួយតិចជាងពីរថ្ងៃនៃថ្ងៃធ្វើសក្ខីកម្មក្នុងនិមួយៗក៏ដោយ ក៏សវនាការស្តាប់សាក្សី ស-២១ ក៏នឹងត្រូវបញ្ចប់តែក្នុងរយៈពេលពីរខែប៉ុណ្ណោះ។ ដូចបានធ្វើការបង្ហាញខាងលើមូលហេតុជាចំបងសម្រាប់រយៈពេលជាធម្យមក្នុងកម្រិតទាបនេះ គឺមិនមែនដោយសារមូលហេតុសុខភាពរបស់ជនជាប់ចោទ ឬកត្តាផ្សេងទៀតហួសពីការគ្រប់គ្រងបានរបស់អង្គជំនុំជម្រះសាលាដំបូងទេ ប៉ុន្តែជាបញ្ហាដែលស្ថិតនៅក្រោមការត្រួតត្រារបស់ខ្លួន ដូចជាការកំណត់ពេលសម្រាប់ការឈប់សម្រាករបស់តុលាការ និងចំនួនថ្ងៃបើកសវនាការក្នុងមួយសប្តាហ៍របស់ខ្លួនតែប៉ុណ្ណោះ។

៧២- ចំនួនខែបន្ថែមនៃពេលវេលាសម្រាប់សវនាការលើ ស-២១ មិនអាចឲ្យគេពិចារណាបានចំពោះការពន្យារពេល ជាក់ស្តែងណាមួយ នៅក្នុងសវនាការដែលបានប្រើពេលអស់មួយឆ្នាំកន្លះមកហើយ ហើយដែលគេរំពឹង ទុកថាអង្គជំនុំជម្រះសាលាដំបូងអាចនឹងត្រូវការពេលរហូតដល់៨ខែ ដើម្បីនឹងចេញ

---

[169] E284 សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១៤០។

[170] E1/23.1 ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ - ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១១

[171] សូមមើល E1/27.1 ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ - ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១១ ទំព័រទី១។

[172] E284 សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១៤០។

សាលក្រមនោះឡើយ[173]។ អង្គជំនុំជម្រះសាលាដំបូងក៏នៅត្រូវការដើម្បីវាយតម្លៃអំពីរយៈពេលបន្ថែមផ្សេងៗទៀត ដែលពាក់ព័ន្ធទៅនឹង ស-២១ ទាក់ទងនឹងរយៈពេលសរុបនៃសវនាការលើសំណុំរឿង ០០២/១ ហើយអង្គជំនុំជម្រះនេះមានកំហុសនៅក្នុងការសន្និដ្ឋានថា ការបន្ថែម ស-២១ នឹងធ្វើឲ្យ "ខូចដល់លទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការចេញសាលក្រមក្នុងសំណុំរឿង០០២/១ ឲ្យបានទាន់ពេលវេលា"។

## *iv. ការពិចារណាអំពីការគ្រប់គ្រងសវនាការ*

៧៣- អង្គជំនុំជម្រះសាលាដំបូងក៏មានកំហុសដែរ ដែលពឹងផ្អែកលើ "ការពិចារណាអំពីប្រសិទ្ធភាព និងប្រសិទ្ធិផលនៃការគ្រប់សវនាការ" តាមរយៈការច្រានចោល ស-២១។ សេចក្ដីអះអាងនៅក្នុងសេចក្ដីសម្រេចដែលរងការជំទាស់ថា ការជំនុំជម្រះគួរបញ្ចប់ដោយ "ផ្អែកលើមូលដ្ឋាននៃបរិវេណដែលបានគេបានស្គាល់ និងយល់រួចហើយដោយគូភាគីទាំងអស់ចាប់ពីដើមដំបូង"[174] ដោយមើលរំលងថា គូភាគីបានដំណើរការអស់រយៈពេលសឹងតែមួយឆ្នាំដំបូងនៃសវនាការ ដោយពុំមានការសម្រេចជាក់លាក់អំពីវិសាលភាពរបស់វាទេ និងដោយមានការយល់ថា អង្គជំនុំជម្រះសាលាដំបូង "អាចសម្រេចក្នុងពេលណាមួយដើម្បីដាក់បញ្ចូលទៅក្នុងសវនាការលើកទីមួយនេះ នូវផ្នែកបន្ថែមនៃដីកាដំណោះស្រាយក្នុងសំណុំរឿង០០២"[175]។ សេចក្ដីណែនាំដំបូងរបស់អង្គជំនុំជម្រះសាលាដំបូង ដល់គូភាគីនៅពេលបើកធ្វើសេចក្ដីសន្និដ្ឋានបើកសវនាការនោះ គឺថា ថ្វីបើមានដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចុះខែកញ្ញា ឆ្នាំ២០១១ក៏ដោយ "ក៏ជនជាប់ចោទត្រូវតែប្រឈមមុខនឹងការចោទប្រកាន់ទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២"[176]។ ភាគីទាំងអស់បានរៀបចំសម្រាប់សវនាការលើវិសាលភាពនៃសំណុំរឿង០០២ អស់រយៈពេលជាងមួយឆ្នាំចាប់ពីខែកញ្ញា ឆ្នាំ២០១០ (ពេលចេញដីកាបញ្ជូលរឿងទៅជំនុំជម្រះ) ដល់ខែកញ្ញា ឆ្នាំ២០១១ (ពេលចេញដីកាបំបែកកិច្ចដំណើរការនីតិវិធីដំបូង)។ តាមរយៈនេះ ភាគីបានស្នើរួចហើយនូវសាក្សីសម្រាប់សវនាការ ក្នុង

---

[173] E284 សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី៧១ (កំណត់សំគាល់ចុងទំព័រ២៧០)។

[174] E284 សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១៤៥។

[175] E124 ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, ២២ កញ្ញា ២០១១, កថាខណ្ឌទី៦។

[176] E131 ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២, ១៨ តុលា ២០១១។

ប្រធានបទនៃសំណុំរឿង០០២ទាំងអស់[177] ហើយបានកំណត់អត្តសញ្ញាណភស្តុតាងសម្រាប់សវនាការក្នុងវិសាលភាពសំណុំរឿង០០២ ទាំងមូល[178]។

៧៤- អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើការស្នាក់ស្នើររបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY "ដើម្បីពង្រីកវិសាលភាពនៃការជំនុំជម្រះក្តី ក្នុងករណីមេធាវីការពារក្តីរបស់ជនជាប់ចោទបានបន្តដំណើរការដោយផ្អែកលើមូលដ្ឋានថា ភស្តុតាងនឹងមិនត្រូវបានបង្ហាញជូនទេពាក់ព័ន្ធទៅនឹងឧប្បត្តិហេតុខ្លះៗ"[179]។ ក៏ប៉ុន្តែដូចដែលបានកត់សម្គាល់ខាងលើ ជនជាប់ចោទដែលនៅទីនេះ ត្រូវបានផ្តល់ជូននូវព័ត៌មានជាប្រចាំថាឧក្រិដ្ឋកម្មបន្ថែម អាចនឹងត្រូវបានដាក់បន្ថែមពីលើសំណុំរឿងលេខ០០២/០១ទៀត ហើយថាភស្តុតាងនៅក្នុងសវនាការនេះអាចត្រូវបានយកទៅធ្វើជាមូលដ្ឋានសម្រាប់ការជំនុំជម្រះក្តីនានានៅពេលអនាគត។ ជាបន្ថែមលើនេះ ភស្តុតាងសំខាន់ដែលទាក់ទងនឹងមន្ទីរស-២១ ត្រូវបានបង្ហាញជូននៅក្នុងទូទាំងសវនាការលើសំណុំរឿងលេខ០០២/០១ទាំងមូល (មានចំនួន១២ថ្ងៃនៃថ្ងៃផ្តល់សក្ខីកម្ម ដោយប្រធានមន្ទីរស-២១ ឌុច) ដូចដែលបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់[180]។ ហេតុដូចនេះ ករណីរឿងនេះបានត្រៀមលក្ខណៈញែកដាច់ដោយឡែកពីគ្នា ពីករណីរឿងក្តីនៅតុលាការ ICTY ដែលបានលើកមកធ្វើជាសម្អាងដោអង្គជំនុំជម្រះសាលាដំបូង[181] ហើយដែលអាចនឹងពុំមានការព្រួយបារម្ភទេថា ជនជាប់ចោទមិនត្រូវបានគេធ្វើការជូនព័ត៌មានបានគ្រប់គ្រាន់ ស្តីពីទីតាំងឧក្រិដ្ឋកម្មស-២១។

---

[177] E9/4 បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា ដោយយោងតាមវិធាន ៨០ រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១,២,៣,៣ក, ៤, និង ៥, ថ្ងៃទី ២៨ មករា ២០១១។ E9/4.1 ឧបសម្ព័ន្ធ១: សំណើបង្គាប់ឱ្យសាក្សីចូលបង្ហាញខ្លួនក្នុងសវនាការ។ E9/4/6 បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ, ថ្ងៃទី២១ កុម្ភៈ ២០១១។ E9/4/6.2 ឧបសម្ព័ន្ធ១: សំណើបញ្ជីឈ្មោះសាក្សី ខៀវ សំផន។

[178] E9/31 បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា សម្រាប់សវនាការ ស្របតាមវិធាន ៨០(៣), ថ្ងៃទី១៩ មេសា ២០១១។ E9/29 បញ្ជីឈ្មោះឯកសារ, ថ្ងៃទី១៩ មេសា ២០១១។ E9/29.2 ឧបសម្ព័ន្ធ: បញ្ជីឯកសារ និងភស្តុតាង ខៀវ សំផន។

[179] E284 សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១៤៣។

[180] E284 សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១១៧។

[181] អង្គជំនុំជម្រះសាលាដំបូងលើកសំអាងតែករណីរឿងមួយតែប៉ុណ្ណោះ ដើម្បីគាំទ្រដល់ជំហររបស់ខ្លួន អំពីករណីរឿងក្តីរបស់ *Dragomir Miloševiæ*។ ក្នុងករណីនេះ ខាងអយ្យការខកខានក្នុងការធ្វើសេចក្តីសន្និដ្ឋានបន្ថែមអំពីករណីបទឧក្រិដ្ឋនានា (criminal incidents) ដែលបានកើតឡើង ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែ, និងដោយគ្រាន់តែបានយោងទៅលើព្រឹត្តិហេតុទាំងនោះ នៅក្នុងសារណាមុនការជំនុំជម្រះក្តី។ ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង *Dragomir Miloševiæ* សំណុំរឿងលេខ IT-98-29/1-T ។ សេចក្តីសម្រេចលើញត្តិរបស់អយ្យការ អនុលោមតាមវិធាន ៧៣ ស្ទួន (ច) (អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY ) ចុះថ្ងៃទី០៣ មេសា ២០០៧, កថាខណ្ឌទី ១៣។

៧៥- នៅក្នុងខណៈដែលអង្គជំនុំជម្រះសាលាដំបូងថ្លែងថាជិតឈានចូលទៅដល់ "ការកំណត់សម្រេចចុងបញ្ចប់ហើយ"លើការផ្តត់ផ្តង់ភ័ស្តុភាងអំពីថា តើសវនាការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០១ នឹងត្រូវបញ្ចប់[182] តាមរបៀបដូចម្តេចនោះ ឥឡូវនេះបីខែហើយបន្ទាប់ពីសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងនេះ ហើយដែលភាគីនានានៅមិនទាន់បានទទួលនៅឡើយនូវកាលវិភាគ ឬផែនការណាមួយដែលជូនដំណឹងអំពីថា តើពេលណាទើបអង្គជំនុំជម្រះសាលាដំបូងគ្រោងនឹងបញ្ចប់សក្ខីកម្មរបស់សាក្សី ការបង្ហាញអត្តសញ្ញាណរបស់សាក្សីដែលនៅសេសសល់ដែលនឹងត្រូវផ្តល់សក្ខីកម្ម ហើយតើពេលណា សេចក្តីសន្និដ្ឋានចុងក្រោយនឹងត្រូវកំណត់កាលវិភាគ ហើយតើពេលណាទើបដល់ពេលត្រូវធ្វើដីកាសន្និដ្ឋានស្តាពរជាលាយលក្ខណ៍អក្សរ។ នៅក្នុងកាលៈទេសៈដែលអង្គជំនុំជម្រះសាលាដំបូងកំពុងតែចាត់ចែង និងរៀបចំផែនការសវនាការដោយផ្អែកលើមូលដ្ឋានមួយសប្តាហ៍ម្តង អង្គជំនុំជម្រះនេះមិនអាចបញ្ជាក់អះអាងបានទេថាបញ្ហាផ្តត់ផ្តង់ភស្តុភារគួបផ្សំជាមួយការដាក់បន្ថែមនូវមន្ទីរស-២១គឺជាការធ្វើយុត្តិកម្មអំពីការដកមន្ទីរស-២១ ចេញពីការជំនុំជម្រះក្តី។ ជាងនេះទៅទៀត ផ្ទុយពីសេចក្តីសម្រេចដែលរងការជំទាស់[183] គ្មានមេធាវីការពារក្តី ឬភាគីផ្សេងទៀតណាមួយបានប្រកែកជំទាស់ថា ការផ្លាស់ប្តូរទៅលើវិសាលភាពនៃការជំនុំជម្រះក្តី "នៅដំណាក់កាលក្រោយនេះមិនមែនជាការត្រឹមត្រូវទាល់តែសោះ"។ តាមពិតគឺជាជំហររបស់ក្រុមមេធាវីការពារជនជាប់ចោទ នួន ជា និង អៀង សារី នៅឯសវនាការស្តីការបំបែកកិច្ចដំណើរការនីតិវិធី កាលពីខែកុម្ភៈ ឆ្នាំ២០១៣ ដែលថាវិសាលភាពនៃការជំនុំជម្រះក្តីគួរបានពង្រីកបន្ថែមដើម្បីដាក់បញ្ចូលនូវរាល់ឧក្រិដ្ឋកម្មនានា<u>ទាំងអស់</u>ក្នុងសំណុំរឿងលេខ០០២ ហើយគឺមិនមែនភាគីណាមួយតែម្នាក់ឯងគាំទ្រឱ្យវិលត្រឡប់មករកវិសាលភាពដើម នៃសំណុំរឿងលេខ០០២/០១នោះឡើយ[184]។

### ឃ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការស្នើឱ្យមានសវនាការជាវគ្គៗ ដោយសារអាយុនិងសុខភាពរបស់ជនជាប់ចោទ

[182] E284 សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១៤៤។

[183] E284 សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១៤៨។

[184] E284 សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី៥១-៥៤។ E1/172.1 ប្រតិចារិកសវនាការ, ថ្ងៃទី២០ កុម្ភៈ ២០១៣, ទំព័រទី ៨០-៨១ [សំណើរបស់សហព្រះរាជអាជ្ញា បានធ្វើការកត់សម្គាល់ថា គ្រប់ភាគីបានឯកភាពថា អង្គជំនុំជម្រះសាលាដំបូងមិនគួរត្រឡប់ទៅរកការបំបែកកិច្ចដំណើរការនីតិវិធីដើមនោះទេ, ហើយថា អង្គជំនុំជម្រះជម្រះគួរតែបន្តកិច្ចដំណើរការនីតិវិធីដោយផ្អែកលើមូលដ្ឋានដែលមានការជំនុំជម្រះតែមួយ, ហើយថាការជំនុំជម្រះតែមួយត្រូវមានលក្ខណៈជាតំណាងច្រើន។

៧៦- សេចក្តីសម្រេចដែលរងការជំទាស់ ដាក់បញ្ចូលឧបសម្ព័ន្ធមួយ នៅពេលធ្វើការសន្និដ្ឋានចុងក្រោយ ដោយអះអាងថា នឹងបង្ហាញ "ផែនការបណ្តោះអាសន្នសម្រាប់សវនាការនាពេលអនាគតលើផ្នែកដែលនៅសល់នៃសំណុំរឿងលេខ០០២"[185]។ ដូចមូលហេតុដែលបានជំរាបខាងលើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងចេញផែនការដូច្នេះ ដោយហេតុថា នៅពេលធ្វើការសន្និដ្ឋានទាក់ទងនឹង អាយុ និងសុខភាពរបស់ជនជាប់ចោទ តម្រូវឱ្យអង្គជំនុំជម្រះនេះជ្រើសរើសយកសវនាការតែមួយដែលតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

៧៧- នៅក្នុងការអធិប្បាយពីជម្រើសនៃផែនការច្បាស់លាស់គ្រប់គ្រាន់សម្រាប់ការជំនុំជម្រះ លើបទចោទទាំងមូលនៅក្នុងសេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះនេះ បានថ្លែងថា៖

*"អ.វ.ត.ក មានកាតព្វកិច្ចក្នុងការធានាថា កិច្ចដំណើរការនីតិវិធីត្រូវធ្វើឡើងតាមពេលវេលាសមស្រប។ ប៉ុន្តែ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងដែលចេះតែកើតមាននេះ ក្នុងការបង្កើតនូវផែនការសម្រាប់ការជំនុំជម្រះដែលនៅសេសសល់នាពេលអនាគត ក្នុងសំណុំរឿង ០០២ បណ្តាលឱ្យមានការភ័ន្តច្រឡំដល់ភាគីនានា ហើយបាន "ដឹកកប់" យ៉ាងមានប្រសិទ្ធិភាពនូវបទចោទដែលនៅសេសសល់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងនោះចោល។ ខណៈដែលអង្គជំនុំជម្រះសាលាដំបូងប្រកាសពីចេតនារបស់ខ្លួន ក្នុងការចាប់ផ្តើមសំណុំរឿងបន្តទៀតក្នុងពេលឆាប់ៗនោះ ក្រោយពីការបញ្ចាក់លើភ័ស្តុតាងក្នុងសំណុំរឿង ០០២/១ ក្នុងឆ្នាំ២០១៣ ហើយថា កិច្ចដំណើរការនីតិវិធីបន្តបន្ទាប់នេះ អាចចាប់ផ្តើមមុនពេលការបញ្ចប់នៃបណ្តឹងសាទុក្ខនានាក្នុងសំណុំរឿង ០០២/១ នោះ មានការបារម្ភជាក់ស្តែងជាច្រើនដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលពុំទាន់បានដោះស្រាយ ដែលអាចរារាំងដល់ការជំនុំជម្រះក្តីនាពេលអនាគតតាមពេលវេលាសមស្រប។ ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការប៉ះពាល់ផលប្រយោជន៍នេះកើតចេញពីការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបញ្ជាក់ពីផែនការសម្រាប់ការជំនុំជម្រះនាពេលអនាគត ក្នុងសំណុំរឿង០០២[186]។*

[185] E284 សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី១០១-១៥៥ (ទំព័រទី៧១-៧៤)។

[186] E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ, កថាខណ្ឌ ៤៧។ (សេចក្តីយោងខាងក្នុងត្រូវបានលុបចេញ)។

៧៨- អង្គជំនុំជម្រះនេះបានបញ្ជាក់យ៉ាងច្បាស់ថាអ្វីដែលបានតម្រូវនោះ គឺមិនគ្រាន់តែព័ត៌មានអំពីថាតើបទចោទប្រកាន់អ្វីខ្លះគួរត្រូវដាក់បញ្ចូលនៅក្នុងការជំនុំជម្រះក្តីនាពេលអនាគតនោះទេ ក៏ប៉ុន្តែមានការពន្យល់ផងដែរអំពីថា តើធ្វើដូចម្តេច "ដើម្បីឲ្យកិច្ចដំណើរការនីតិវិធីជាបន្តបន្ទាប់ទៅទៀតអាចចាប់ផ្តើមបាននៅមុនការដាក់បញ្ចូលនូវបណ្តឹងសាទុក្ខណាមួយនៅក្នុងសំណុំរឿងលេខ០០២/០១" ដែលហេតុដូចនេះកើតឡើងនៅក្នុង "ពេលវេលាសមស្រប"ណាមួយ។ សេចក្តីសម្រេចដែលរងការជំទាស់មានកំហុស ដោយខកខានមិនបានលើកឡើងអំពីបញ្ហានេះដោយជាក់ស្តែងតាមបែបណាមួយ។ លេខយោងជើងទំព័រដើម្បីធ្វើផែនការសម្រាប់ពេលអនាគតចែងថា "សំណុំរឿងលេខ០០២/០២ នឹងចាប់ត្រូវផ្តើម តាមកាលៈទេសៈដែលអនុញ្ញាតឲ្យ លុះត្រាតែមានការណែនាំផ្ទុយពីនេះ នៅក្រោយពេលធ្វើសេចក្តីសន្និដ្ឋានលើសំណុំរឿងលេខ០០២/០១"ហើយបន្ទាប់មកគ្រោងថា "សាលក្រមសាលាដំបូងមួយនៅក្នុងសំណុំរឿងនេះអាចនឹងចេញតាមក្រោយ ក្នុងរយៈពេលប្រមាណជា៨ខែក្រោយពីការធ្វើសេចក្តីសន្និដ្ឋានលើការស្តាប់ភស្តុតាងនៅក្នុងសំណុំរឿងលេខ០០២/០១ (គឺនៅក្នុងអម្លុងនៃត្រីមាសទី១ឆ្នាំ២០១៤)"ហើយសាលដីកាមួយ លើបណ្តឹងសាទុក្ខជាយថាហេតុណាមួយ នឹងចេញនៅ១៨ខែក្រោយមកទៀត (គឺថា នៅចុងឆ្នាំ២០១៥)"[187]។ ក៏ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងមិនបានបញ្ជាក់ថាតើការថ្លែងរបស់ខ្លួនដែលថា សំណុំរឿងលេខ០០២/០១ នឹងត្រូវចាប់ផ្តើម "បន្ទាប់ពីការបញ្ចប់សំណុំរឿងលេខ០០២/០១" គឺជាសេចក្តីយោងទៅលើសេចក្តីសន្និដ្ឋានលើភស្តុតាង, ការចេញសាលក្រមមួយរបស់សាលាដំបូងលើ ឬសេចក្តីសន្និដ្ឋានលើបណ្តឹងសាទុក្ខ។ ហើយក៏មិនបានលើកឡើងបញ្ហាទាក់ទងនឹងច្បាប់ស្តីពីលទ្ធភាពក្នុងការចាប់ផ្តើមធ្វើសវនាការជំនុំជម្រះក្តីលើកទីពីរ នៅមុនការធ្វើសេចក្តីសន្និដ្ឋានលើបណ្តឹងសាទុក្ខណាមួយនៅក្នុងសំណុំរឿងលេខ០០២/០១ដែរ។

៧៩- សហព្រះរាជអាជ្ញាសូមជូនជាយោបល់ដើម្បីពិចារណាថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពន្យល់ថាតើ ធ្វើដូចម្តេចទើបការជំនុំជម្រះក្តីនាពេលអនាគតដែលជាសម្មតិកម្មអាចនឹងកើតឡើងនៅក្នុងរង្វង់ "ពេលវេលាដ៏សមស្របណាមួយ"បាន គឺជាការបញ្ជាក់បន្ថែមថា គម្រោងសម្រាប់អនាគតនៃការជំនុំជម្រះក្តីណាមួយបែបនេះ នៅឆ្ងាយមើលមិនឃើញ និងស្នើថាជម្រើសតែមួយគត់ដែលអាចឲ្យធ្វើទៅបានដែលមានស្រាប់សម្រាប់អង្គជំនុំជម្រះសាលាដំបូងនោះគឺ ការជំនុំជម្រះក្តីតែមួយលើកគត់ដែលតំណាងសមហេតុសមផលអោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើសំណុំរឿងលេខ០០២។

---

[187] E284 សេចក្តីសម្រេចដែលរងការជំទាស់, ទំព័រទី៧១ (កំណត់ជើងទំព័រលេខ ២៧០)។

## V. សំណើសុំជំរុញឲ្យបានលឿននូវសវនាការលើបណ្តឹងសាទុក្ខ

៨០- អង្គជំនុំជម្រះនេះបានតឿនដល់ អវតក ទាំងមូលសុំឲ្យ "ប្រើប្រាស់នូវថ្ងៃដែលមានអាចធ្វើបានដើម្បីធានាថាការកំណត់សំរេចជាស្ថាពរមួយលើការចោទប្រកាន់ទាំងប៉ុន្មានដែលនៅសេសសល់ត្រូវធ្វើឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន"[188]។ រីឯវិធាន១០៨(ស្ទួនបី)(ខ)នៃវិធានផ្ទៃក្នុង បានកំណត់អំពីរយៈពេលរហូតដល់ទៅបីខែសំរាប់ការចេញសេចក្តីសង្ខេបអំពីមូលហេតុ ហើយឲ្យពន្យារពេលបានត្រឹមមួយខែនៅក្នុងករណីពិសេស គ្មានអ្វីរាំងដល់អង្គជំនុំជម្រះនេះមិនឲ្យចេញជាសេចក្តីសម្រេចសង្ខេបមួយនៅក្នុងរង្វង់ក្របខណ្ឌពេលវេលាដែលខ្លីជាងនេះនោះឡើយ។

៨១- ឥឡូវនេះគឺអស់រយៈពេលជាងបីខែទៅហើយ ចាប់តាំងពីអង្គជំនុំជម្រះនេះបានដាក់ចេញនូវសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗអំពីការបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួនកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣មក និងរយៈពេលពីរសប្តាហ៍ ចាប់តាំងពីការចេញសេចក្តីសម្រេចដែលរងការជំទាស់របស់អង្គជំនុំជម្រះសាលាដំបូងមក ។ សវនាការលើសំណុំរឿងលេខ០០២/០១បានចាប់ផ្តើមធ្វើជាបន្តទៅទៀត ក៏ប៉ុន្តែទាក់ទងនឹងការចោទប្រកាន់នានាពាក់ព័ន្ធនឹងអង្គហេតុដូចដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់តែប៉ុណ្ណោះ។ ដោយហេតុថា វិសាលភាពនៃការបំបែកកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ននេះមានលក្ខណៈដូចគ្នានឹងវិសាលភាព នៃការបំបែកកិច្ចដំណើរការនីតិវិធីកាលពីខែកញ្ញា ឆ្នាំ២០១១ នោះ សេចក្តីថ្លែងកន្លងមករបស់ អង្គជំនុំជម្រះ សាលាដំបូងបានបញ្ជាក់ថានៅក្នុងសំណុំរឿងលេខ០០២/០១ អាចនឹងឈានទៅរកការបិទនាពេលអនាគតឆាប់ៗនេះហើយ។ នៅក្នុងអនុស្សរណៈមួយចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា៖

"*នៅខណៈពេលដែល អ.ជ.ត.ក ចេញ[សេចក្តីសម្រេចលើបណ្តឹងសាទុក្ខអំពីការបំបែកកិច្ចដំណើរការនីតិវិធី] អង្គជំនុំជម្រះសាលាដំបូងកំពុងតែជិតឈានដល់ការបញ្ចប់សំណុំរឿងលេខ០០២/០១។ មានការប៉ាន់ប្រមាណថា <u>មានតម្រូវការចំនួនថ្ងៃសវនាការ បន្តិចបន្តួចថែមទៀត ជាមួយនឹងវត្ថុមានជនជាប់ចោទទាំងបីនាក់</u>(ការសង្កត់ន័យបន្ថែមដោយការគូសបន្ទាត់ពីក្រោម) ដើម្បីបញ្ចប់សវនាការលើភ័ស្តុតាងនៅក្នុងការជំនុំជម្រះលើកដំបូង*"[189]។

---

[188] E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ, កថាខណ្ឌ ៥១។

[189] E163/5/1/13/1 ការណែនាំដល់ភាគីនានា ដោយសារតែមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល, កថាខណ្ឌទី៣ (iii).

៨២- នៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កាលៈទេសៈបច្ចុប្បន្នផ្តល់ការអនុញ្ញាតឱ្យចេញសេចក្តីសម្រេចសង្ខេបជាប្រញ៉ាប់មួយបាន ដោយផ្អែកលើមូលដ្ឋាននៃការប្រញ៉ាប់។ ការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងលេខ០០២ត្រូវបានដាក់ឱ្យធ្វើសារណាយ៉ាង ទូលំទូលាយនិងឱ្យធ្វើការពិនិត្យឡើងវិញ លើបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះ នេះ។បណ្តឹងសារទុក្ខភ្លាមៗ ត្រូវបានរៀបចំឡើងនិងដាក់នៅចំពោះមុខអង្គជំនុំជម្រះនេះ ដោយសហព្រះរាជអាជ្ញា នៅក្នុងរយៈពេល១៤ថ្ងៃ ដែលជារយៈពេលតែពាក់កណ្តាលនៃរយៈពេលដែលកំណត់ឱ្យ នៅក្នុងវិធាន១០៧(១)នៃវិធានផ្ទៃក្នុង តែប៉ុណ្ណោះ។តាមរយៈដីកាបង្គាប់ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣របស់អង្គជំនុំជម្រះនេះ នៅពេលនេះគួរតែកុំឱ្យមាន "ការរឹតបណ្តឹងនិងបើកឱ្យអាចចូលទៅពិនិត្យមើលបានភ្លាមៗនូវសំណុំរឿងលេខ០០២ទាំងមូល"[190]។ អនុលោមតាមវិធាន១០៨(ស្ទួនបី)(ខ)នៃវិធានផ្ទៃក្នុងរយៈពេលកំណត់ចំនួនបីខែសម្រាប់ការចេញសេចក្តីសម្រេចដោយសង្ខេប គឺនឹងដល់ពេលផុតកំណត់នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ ដែលអាចឱ្យពន្យារពេលរហូតដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៣បាន។ ទោះបីជាមិនមានការផ្តល់ជូននូវកាលវិភាគសម្រាប់ការធ្វើសវនាការដល់ភាគីនានារហូតមកទល់ពេលនេះក៏ដោយ ក៏ការរំពឹងទុករបស់សហព្រះរាជអាជ្ញាគឺថាការដាក់សារណាបញ្ចប់ការដេញដោល ដោយបណ្តាភាគីនានាអាចត្រូវដល់ពេលកំណត់នៅក្នុងខែសីហា ឆ្នាំ២០១៣។

៨៣- សហព្រះរាជអាជ្ញា ទទួលស្គាល់ថា កំហុសឆ្គងនានារបស់អង្គជំនុំជម្រះសាលាដំបូង "នៅតែងាយទទួលរងនូវការពិនិត្យពិច្ច័យនិងអន្តរាគមន៍តាមរយៈបណ្តឹងសាទុក្ខ" សូម្បីតែនៅក្រោយសេចក្តីសន្និដ្ឋាននៅក្នុងសំនុំរឿងលេខ០០២/០១ក៏ដោយ[191]។ ទោះជាយ៉ាងណាក្តី នៅក្នុងកាលៈទេសៈបច្ចុប្បន្ន គឺជាផលប្រយោជន៍ដ៏ធំធេងដល់គ្រប់ភាគីទាំងអស់ បើសិនជាអាចមានលទ្ធភាពទទួលបាននូវការសម្រេចលើបណ្តឹងងសាទុក្ខនៅត្រឹមដើមឬពាក់កណ្តាលខែកក្កដា ឆ្នាំ២០១៣នេះ ប្រយោជន៍ដើម្បីថាបើសិនជាបណ្តឹងសាទុក្ខត្រូវបានទទួលជោគជ័យនោះ ការកែតម្រូវទៅតាមលទ្ធផលណាមួយទៅលើកាលវិភាគនៃការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០១ អាចធ្វើឡើងបាននៅមុនពេលដាក់សារណាបិទការសួរដេញដោល។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូលសុំឱ្យសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗនេះដោយផ្អែកលើមូលដ្ឋាននៃការប្រញ៉ាប់និងដោយឆាប់រហ័ស។ ហើយប្រសិនជាមានការចាំបាច់ត្រូវចេញជាសេចក្តីសម្រេចមួយដែលមានការបញ្ជាក់

[190] **E238/9/1/4** ដីកាបង្គាប់ឱ្យអនុវត្តភ្លាមៗតាមវិធាន ១០៨ នៃវិធានផ្ទៃក្នុង, ថ្ងៃទី១២ មីនា ២០១៣។

[191] **E163/5/1/13/3** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំការបង្គាប់ជាបន្ទាន់ទៅអង្គជំនុំជម្រះសាលាដំបូងឱ្យចេញសេចក្តីសម្រេចដែលមានសំអាងហេតុស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ , ថ្ងៃទី០៨ ឧសភា ២០១៣, ត្រង់កថាខណ្ឌទី៥។

មូលហេតុ ដោយសង្ខេប និងសេចក្តីសម្រេច ដែលមានការបញ្ជាក់មូលហេតុពេញលេញទាំងស្រុងមួយធ្វើតាមក្រោយ។

## VI. ដំណោះស្រាយផ្លូវច្បាប់ដែលបានស្នើសុំ

៨៤- អាស្រ័យដោយមូលហេតុដូចបានលើកឡើងខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះតុលាការកំពូល ៖

១) **ទទួលយក និងពិចារណា**លើបណ្តឹងសាទុក្ខភ្លាមៗដោយផ្អែកលើមូលដ្ឋាននៃការប្រញ៉ាប់ និងដោយឆាប់រហ័ស។

២) **កែប្រែ**នូវសេចក្តីសម្រេចដែលរងការជំទាស់ដើម្បីដាក់បញ្ចូលនូវ **មន្ទីរសន្តិសុខស-២១** នៅក្នុងវិសាលភាពនៃការជំនុំជម្រះលើសំណុំរឿងលេខ០០២/០១ និងសូមណែនាំដល់អង្គជំនុំជម្រះសាលាដំបូងឲ្យបើកសវនាការស្តាប់ភស្តុតាងនេះ ដោយគ្មានការអូសបន្លាយពេលវេលាតទៅទៀត។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY** សហព្រះរាជអាជ្ញា | | [signature] Andrew Cayley QC |